គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# ការរួមចំណែករបស់អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ឆ្នាំ២០១២

## ឱកាស និង ការប្រឈម



ការសិក្សាស្រាវជ្រាវនេះគាំទ្រដោយៈ
គណៈកម្មាធិការសហប្រត្តិការដើម្បីកម្ពុជា

ឧសភា ២០១៣

Promoting NGO Solidarity and Cooperating Since 1990

**រក្សាសិទ្ធិ:**

© រាល់យោបល់ទាំងនេះជារបស់អ្នកនិពន្ធ និងទទួលបានពីអ្នកផ្តល់ចម្លើយផ្សេងៗ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈនិងគំនិតរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ឡើយ។ សូមលើកទឹកចិត្តក្នុងការបោះពុម្ព ឬការផលិតឡើងវិញដែលមានការទទួលស្គាល់ស្នាដៃរបស់អ្នកនិពន្ធ និងអង្គការ CCC។

# បុព្វកថា

អង្គការសង្គមស៊ីវិល ស្វែងរកនូវការទទួលស្គាល់យ៉ាងសមស្រប និងត្រឹមត្រូវ ពីការចូលរួមចំណែករបស់ខ្លួនដល់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងរួមគ្នា អស់រយៈពេលជាង៣០ឆ្នាំ គឺជាព្រឹត្តិការណ៍ដ៏សំខាន់នាំឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា រាប់លាននាក់។ ពេលវេលា មិនបានធ្វើឲ្យតួនាទីសំខាន់របស់អង្គការសង្គមស៊ីវិល ថយចុះឡើយ ដូចដែលរបាយការណ៍នេះ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា សង្គមស៊ីវិល នៅតែជាកម្លាំងដ៏សំខាន់នៅក្នុងសង្គមកម្ពុជា។

ក្នុងការរៀបចំធ្វើការស្រាវជ្រាវ សម្រាប់របាយការណ៍នេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) បានសន្យាបន្តដំណើរការវិភាគ និងវាយតម្លៃ ដែលកាលពីមួយឆ្នាំកន្លងទៅ ដំណើរការនេះ នាំឲ្យមានការបោះពុម្ពផ្សាយនូវរបាយការណ៍ ស្តីពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្នាំ២០១១។ ការស្រាវជ្រាវនេះ ក៏មានគោលបំណងដើម្បីពង្រឹងទាំងបរិមាណ និងគុណភាព នូវតួនាទីរបស់អង្គការសង្គមស៊ីវិលឲ្យកាន់តែមានតម្លៃធំធេងជាងមុន នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ការស្រាវជ្រាវនេះ ក៏មានគោលបំណងជំរុញឲ្យមានការពិភាក្សា និងការពិចារណាផងដែរ ក្នុងចំណោមរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ អំពីរបៀបលើកកម្ពស់ឲ្យមានបរិយាកាសអំណោយផលឲ្យបានល្អបំផុត ដែលអង្គការសង្គមស៊ីវិល អាចមានសិទ្ធិចូលរួមធ្វើជាតួអង្គអភិវឌ្ឍន៍សំខាន់។

របាយការណ៍ថ្មីរបស់យើង គឺជាជំហានឆ្ពោះទៅមុខទៀត ក្នុងទិសដៅនេះ។ ប្រធានបទស្តីពី "ឱកាស និងបញ្ហាប្រឈម" ធ្វើឲ្យយើងមានការប្តេជ្ញាចិត្តដោយស្មោះត្រង់ ក្នុងការកំណត់អត្តសញ្ញាណ និងវាយតម្លៃ ពីការលំបាកដែលអង្គការសង្គមស៊ីវិលជួបប្រទះ ក្នុងឆ្នាំ ២០១២។ បញ្ហាប្រឈមរួមមាន ការកាត់បន្ថយហិរញ្ញវត្ថុ បញ្ហាគណនេយ្យភាព និងការប្រែប្រួលប្រព័ន្ធសេដ្ឋកិច្ច។ ស្របពេលគ្នានេះដែរ បើមើលពីធនធាន និងសមិទ្ធផលរបស់អង្គការសង្គមស៊ីវិល យើងនឹងឃើញឱកាសក្នុងការប្រើប្រាស់ចំណុចខ្លាំងដែលមានស្រាប់។

ការស្រាវជ្រាវនេះ មានគោលបំណងវាស់វែងការប្រតិបត្តិរបស់សង្គមស៊ីវិល ទៅលើទំហំនៃកិច្ចខិតខំប្រឹងប្រែង ការគាំទ្រដែលទទួលបាន ចំនួនពិតប្រាកដនៃអ្នកទទួលផល និងសិទ្ធិអំណាច និងចំនួននៃអ្នកដែលត្រូវបានជ្រើសរើសឲ្យធ្វើការងារ។ ការសិក្សាស្រាវជ្រាវរបស់យើង ក៏បានចោទសួរពីគណនេយ្យភាពរបស់អង្គការសង្គមស៊ីវិល ចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល។ ការដឹកនាំរបស់អង្គការ CCC ឲ្យមានអភិបាលកិច្ចល្អ នៅកម្ពុជា ត្រូវបានអ្នកដែលគេចវេះពីបញ្ហានេះ ចាត់ទុកថា ជាអ្នកបង្កបញ្ហា ប៉ុន្តែ ចំពោះអ្នកជឿជាក់លើសារសំខាន់ និង

ភាពចាំបាច់ នៃតម្លៃស្នូលទាំងនេះ ចាត់ទុកអង្គការ CCC ជាអ្នកផ្តល់ដំណោះស្រាយតែមួយគត់ចំពោះវិស័យនេះ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការពិនិត្យពិច័យ។ អង្គការ CCC ជឿជាក់ថាការទទួលស្គាល់ជាទូទៅ លើទំហំ និងវិសាលភាពនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលតំណាងឲ្យអ្នកក្រីក្រ និងអ្នកងាយទទួលរងគ្រោះបំផុត មានសារសំខាន់ណាស់ ចំពោះអនាគតសង្គមស៊ីវិល នៅកម្ពុជា។ នៅពេលដែលចំណាប់អារម្មណ៍នៃជំនួយអន្តរជាតិ មានការផ្លាស់ប្តូរជាការសំខាន់ជាងពេលណាៗទាំងអស់ដែលថា បញ្ហាប្រឈមចំពោះភាពដែលអាចជឿទុកចិត្តបាន នៃវិស័យអង្គការសង្គមស៊ីវិល ត្រូវបានឆ្លើយតបដោយយុត្តិធម៌ និងត្រឹមត្រូវ ពោលគឺដោយផ្អែកលើការណ៍ពិត ជាជាងរឿងអរិជ្ជមានដែលមិនពាក់ព័ន្ធ។

ហេតុដូច្នេះហើយ អង្គការ CCC បានធ្វើរបាយការណ៍អំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ដែលបង្ហាញពីការប្តេជ្ញាចិត្តបន្តឲ្យមានការគាំទ្រ និងសហប្រតិបត្តិការ ក្នុងផ្នែកសង្គមស៊ីវិល។ យើងសូមថ្លែងអំណរគុណចំពោះក្រុមហ៊ុន ដំរីស្រាវជ្រាវនិងផ្តល់ប្រឹក្សា ក្រុមការងារអង្គការ CCC និងអ្នកផ្តល់ចម្លើយ ក្នុងជំរឿន ឆ្នាំ២០១២ នេះ ជាពិសេសអ្នកដែលចំណាយពេលវេលាឆ្លើយតបនឹងសំណួរជាច្រើននៃការធ្វើអង្កេត។ ជាគុណប្រយោជន៍ដ៏ឧត្តមទាំងសហគមន៍អង្គការសង្គមស៊ីវិល និងអ្នកដែលទទួលការបម្រើការងានេះ យើងទទូចឲ្យក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ និងសហការីនៅគ្រប់ថ្នាក់ របស់អង្គការសង្គមស៊ីវិល ចំណាយពេលវេលាចូលរួមការអង្កេត និងជំរឿនបន្ទាប់របស់យើងខ្ញុំ និងសហការគ្នា ដើម្បីពង្រឹងប្រសិទ្ធភាពសហគមន៍អង្គការសង្គមស៊ីវិល ព្រមទាំងគាំទ្រ និងផ្តល់សិទ្ធិអំណាចដល់ប្រជាជនកម្ពុជា ឲ្យសម្រេចបាននូវសក្តានុពលរបស់ខ្លួន។



**សឿង សារឿន**

នាយកប្រតិបត្តិ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ អាចបញ្ចប់ទៅបាន ដោយសារមានកិច្ចខិតខំប្រឹងប្រែងរបស់មនុស្ស ជាច្រើន អស់រយៈពេលជាច្រើនខែ។ សូមថ្លែងអំណរគុណចំពោះបុគ្គលិកទាំងអស់របស់អង្គការ CCC ដែលបានធ្វើការសម្របសម្រួល និងត្រួតពិនិត្យការសិក្សាឆ្នាំ២០១២នេះ ជាពិសេស លោក លន់ បូរិទ្ធី អតីតនាយកប្រតិបត្តិ របស់អង្គការ CCC ដែលមានឆន្ទៈដោះស្រាយបញ្ហា ប្រឈមនៃជំរឿន និងការសិក្សាស្រាវជ្រាវ របស់អង្គការសង្គមស៊ីវិល ដោយធ្វើឲ្យមាន ដំណើរការចាប់ផ្តើមឡើង រហូតដល់ចុងបញ្ចប់។ សូមថ្លែងអំណរគុណផងដែរចំពោះ លោក សឿង សារឿន បច្ចុប្បន្នជានាយកប្រតិបត្តិរបស់អង្គការ CCC លោក ជេន សុជឿន អ្នក ឯកទេសសិក្សាស្រាវជ្រាវ កញ្ញា ឆោម ចរិយា មន្ត្រីសិក្សាស្រាវជ្រាវ លោក Dr. Rowan Martin Hughes ទីប្រឹក្សាគ្រប់គ្រងផ្នែកចំណេះដឹង និងក្រុមការងារអង្គការ CCC ទាំងអស់ ចំពោះការ ចូលរួមផ្តល់ព័ត៌មាន និងការឆ្លើយតបដ៏មានតម្លៃ។ លោក កែវ ផល្លា បានផ្តល់ទិន្នន័យ សម្រាប់ ជំរឿន និងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុម ដើម្បីធានាឲ្យការសិក្សានេះ មានភាពត្រឹមត្រូវ និងចប់ដោយបរិបូរណ៍។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិក ក្រុមគណៈទីប្រឹក្សាស្រាវជ្រាវ ដែល សម្របសម្រួលដោយអង្គការ CCC ចំពោះការត្រួតពិនិត្យ និងការឆ្លើយតប លើវិធីសាស្ត្រ ស្រាវជ្រាវ រួមទាំងយោបល់លើសេចក្តីព្រាងបញ្ជីសំណួរ និងរបាយការណ៍។

ការសិក្សានេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនដំរីស្រាវជ្រាវនិងផ្តល់ប្រឹក្សា លោក Ian Ramage នាយកផ្នែកស្រាវជ្រាវ និងលោក កែវ គឹមហ៊ិត ប្រធានផ្នែកស្រាវជ្រាវ បានធ្វើការ ដោយឥតនឿយហត់ ដើម្បីគ្រប់គ្រងសមាសភាពទាំងអស់នៃការសិក្សាឆ្នាំ២០១២ នេះ និងបាន ទាក់ទងជាមួយនឹងអង្គការ CCC។ ប្រធានក្រុមស្រាវជ្រាវនៃជំរឿននេះគឺ លោកស្រី សាំង រតនៈសោភា និងលោក កែវ គឹមហ៊ិត។ ប្រធានក្រុមស្រាវជ្រាវនៃការសិក្សាស្រាវជ្រាវនេះគឺ លោក គៀន សាលី លោក សួស កាម៉ៅ និងលោក កែវ គឹមហ៊ិត។ លោក សាលី និង លោក គឹមហ៊ិត ក៏បានធ្វើសម្ភាសន៍ដៃគូអភិវឌ្ឍន៍ និងធ្វើផែនទីរាជរដ្ឋាភិបាល សម្រាប់របាយការណ៍ ស្ថាពរនេះផងដែរ។ កញ្ញា Psyche Amor Lao បានរៀបចំបង្កើតទិន្នន័យ ត្រួតពិនិត្យ ការបញ្ចូល ទិន្នន័យ ធ្វើការវិភាគទិន្នន័យ និងបានសរសេរផ្នែកជាច្រើននៃរបាយការណ៍នេះ។ លោក Jonh Paul Nicewinter បានបញ្ចូលទិន្នន័យបន្ថែម និងបានសរសេររបាយការណ៍ និងបទបង្ហាញ ភាគច្រើន។

សូមថ្លែងអំណរគុណចំពោះសមាជិកនីមួយៗនៃក្រុមជំរឿន ក្រុមការងារប្រមូលទិន្នន័យ និងក្រុមបញ្ចូលទិន្នន័យ ចំពោះការងារយ៉ាងសកម្ម និងការប្តេជ្ញាចិត្តធ្វើការស្រាវជ្រាវដែលមានគុណភាពខ្ពស់។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណចំពោះអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារចំនួនជាង ១.៤០០ ដែលបានលះបង់ពេលវេលារបស់ខ្លួន ដើម្បីធ្វើការជាមួយនឹងក្រុមស្រាវជ្រាវ។ ការចូលរួមនេះ មានសារសំខាន់ណាស់ និងបានចូលរួមចំណែកឲ្យមានការយល់ដឹងយ៉ាងពិស្តារអំពីវិស័យអង្គការសង្គមស៊ីវិល។ យើងមានសេចក្តីសង្ឃឹមថា ការឆ្លើយតបយ៉ាងមានតម្លៃនេះនឹងត្រូវបានប្រើប្រាស់ប្រកបដោយស្ថាបនា សម្រាប់ការអភិវឌ្ឍន៍ប្រទេស និងប្រជាជនកម្ពុជាឲ្យកាន់តែប្រសើរ។

# មាតិកា


បុព្វកថា ........ 1

សេចក្តីថ្លែងអំណរគុណ ........ 3

សន្ទានុក្រមនៃប្រភេទអង្គការ ........ 6

អក្សរកាត់ ........ 8

សេចក្តីសង្ខេប ........ 10

សេចក្តីផ្តើម ........ 17

សាវតា ........ 19

វិធីសាស្រ្ត ........ 23

លទ្ធផលជំរឿនអង្គការសង្គមស៊ីវិល ........ 31

បុគ្គលិក ........ 50

ហិរញ្ញវត្ថុ ........ 60

សកម្មភាពការងារ ........ 66

ការសម្របសម្រួល និងសហប្រតិបត្តិការ ........ 78

អភិបាលកិច្ច ........ 84

សហប្រតិបត្តិការនាពេលអនាគត ........ 87

អនុសាសន៍របស់អង្គការសង្គមស៊ីវិល ........ 90

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 95

ឯកសារយោង ........ 101

ឧបសម្ព័ន្ធ១ ........ 102

ឧបសម្ព័ន្ធ ២ ........ 104

ឧបសម្ព័ន្ធ ៣ ........ 134

# សន្ទានុក្រមនៃប្រភេទអង្គការ

**សមាគម** ៖ សមាគមគឺជាអង្គការដែលត្រូវបានបង្កើតឡើង ភាគច្រើន ដោយមនុស្សមួយក្រុម ដើម្បីបម្រើ ឬបំពេញសេចក្តីត្រូវការបន្ថែមទៀតរបស់ក្រុមខ្លួន។ ជាធម្មតា សមាគម មានសមាជិកស្ម័គ្រចិត្ត ដែលចូលរួមក្នុងសមាគមជាផ្លូវការ ដើម្បីចែករំលែកនូវសេវាកម្ម ធនធាន បទពិសោធន៍ ឬសមត្ថភាពធ្វើការចរចាក្នុងនាមអង្គភាពតែមួយ។ ដូចគ្នានឹងអង្គការមិនមែនរដ្ឋាភិបាល សមាគមគឺជាស្ថាប័នមិនរកប្រាក់ចំណេញ ទោះបីជាសមាជិករបស់ខ្លួន អាចចូលរួមក្នុងសកម្មភាពរកប្រាក់ចំណេញ ក៏ដោយ។ ទោះបីជាសមាគមអន្តរជាតិ មានវត្តមាននៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែ សមាគមទាំងនោះ មិនមានភាពខុសគ្នាទៅនឹងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិទេ នៅពេលដែលចុះបញ្ជីនៅក្រសួងការបរទេសកម្ពុជា (MOFA)។ ដូច្នេះហើយ ក្នុងបរិបទនៃរបាយការណ៍នេះ សមាគម គឺសំដៅលើសមាគមក្នុងស្រុក និងបានចុះបញ្ជីជាមួយនឹងក្រសួងមហាផ្ទៃ (MOI)។

**អង្គការនៅតាមសហគមន៍** (CBO) ៖ អង្គការនៅតាមសហគមន៍ ជាទូទៅបង្កើតឡើងដោយក្រុម ឬសហគមន៍ណាមួយ (សហគមន៍តាមតំបន់ ឬ "សហគមន៍មានផលប្រយោជន៍") ដើម្បីធ្វើឲ្យរីកចម្រើនដល់ផលប្រយោជន៍រួមជាក់លាក់ណាមួយ ជាទូទៅមានលក្ខណៈជាទ្រង់ទ្រាយតូចៗ។ ជាធម្មតា អង្គការនៅតាមសហគមន៍ មានសមាជិកបាត់បង់ផលប្រយោជន៍ដោយផ្ទាល់ ហើយជាទូទៅ ប្រតិបត្តិដោយប្រមូលផ្តុំ និងតំណាងឲ្យសហគមន៍ ជាមួយរាជរដ្ឋាភិបាល (មូលដ្ឋាន និង/ឬ ថ្នាក់ជាតិ) ដៃគូផ្តល់ជំនួយ/អភិវឌ្ឍន៍ ក្រុមហ៊ុនឯកជន ឬអង្គភាពផ្សេងទៀត ទាក់ទងនឹង បញ្ហាសង្គម វប្បធម៌ សេដ្ឋកិច្ច សាសនា ឬបរិស្ថាន។ អង្គការនៅតាមសហគមន៍ជាច្រើន មិនបានជ្រើសរើសបុគ្គលិកទទួលបានបៀវត្សរ៍នោះទេ ហើយបំពេញការងារដោយស្ម័គ្រចិត្ត ដែលអាចមានសណ្ឋានផ្សេងគ្នា ពីអង្គការមិនមែនរដ្ឋាភិបាល។

**អង្គការសង្គមស៊ីវិល** (CSO) ៖ មាននិយមន័យបែបទ្រឹស្តីជាច្រើន ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង អង្គការសង្គមស៊ីវិល គឺជាអង្គការដែលកើតឡើងហួសពីដែនរបស់រដ្ឋ (ស្ថាប័នរាជរដ្ឋាភិបាល) ឯកជន (បណ្តាញគ្រួសារ) និងទីផ្សារ (អង្គភាពរកប្រាក់ចំណេញ) ហើយដែលមានរចនាសម្ព័ន្ធផ្លូវការ និងភ្ជាប់នឹងរបៀបវារៈមិនរកប្រាក់ចំណេញ ដោយជាទូទៅ អតិរេកហិរញ្ញវត្ថុ ត្រូវវិនិយោគត្រលប់មកអង្គការវិញ ដើម្បីធ្វើឲ្យគោលដៅមានការរីកចម្រើនទៅមុខ។ ត្រូវចាត់ទុកថា ជាអង្គការសង្គមស៊ីវិល អង្គការនោះត្រូវតែអាចប្រតិបត្តិ ស្វ័យអភិបាលកិច្ចឯករាជ្យ។ ជាទូទៅ ពាក្យអង្គការសង្គមស៊ីវិល ត្រូវបានចាត់ទុកថាជាពាក្យរួមដែលរាប់បញ្ចូល

ទាំងក្រុមអង្គការសង្គមស៊ីវិលផ្លូវការ និងក្រៅផ្លូវការ រួមមានអង្គការនៅតាមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល សមាគម។ល។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងគោលបំណងនៃការបែងចែកឲ្យខុសពីគ្នា នៅក្នុងរបាយការណ៍នេះ អង្គការសង្គមស៊ីវិល គឺជាពាក្យទូទៅ ដែលសំដៅទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ចំណែកអង្គការនៅតាមសហគមន៍ ត្រូវបានកំណត់អត្តសញ្ញាណដោយឡែកពីនេះ។

**អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ** (INGO) ៖ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានប្រតិបត្តិការ នៅក្នុងប្រទេសលើសពីមួយ ទោះជាតាមរយៈប្រតិបត្តិការពហុអន្តរជាតិ ការចុះបញ្ជីនៅបរទេស ឬគ្រាន់តែមានស្ថាបនិកជាជនបរទេស ស្ថិតនៅក្នុងប្រទេសដែលមានមូលដ្ឋានប្រតិបត្តិការនោះ។ ហេតុដូច្នេះ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួន មានប្រតិបត្តិការដូចអង្គការក្នុងស្រុកដែរ។ នៅក្នុងបរិបទនៃរបាយការណ៍នេះ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គឺជាអង្គការដែលបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះ មានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងការបរទេស ។

**អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** (LNGO) ៖ ប្រភេទនៃអង្គការមិនមែនរដ្ឋាភិបាលនេះ ត្រូវបានបង្កើតឡើង និងមានប្រតិបត្តិការតែនៅក្នុងប្រទេសណាមួយប៉ុណ្ណោះ។ អង្គការនេះ អាចស្ថិតនៅថ្នាក់ជាតិ ដោយមានតំណាងនៅក្នុងខេត្ត/ស្រុក (ជួនកាលហៅថា អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ) ឬអាចជាអង្គការដែលមានមូលដ្ឋាននៅក្នុងតំបន់/ស្រុក ដោយផ្តោតលើតែតំបន់ណាមួយ។ នៅក្នុងបរិបទនៃរបាយការណ៍នេះ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានប្រតិបត្តិការតែនៅក្នុងប្រទេសកម្ពុជា ដឹកនាំដោយជនជាតិកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ (MOI)។

**អង្គការមិនមែនរដ្ឋាភិបាល** (NGO) ៖ អង្គការមិនមែនរដ្ឋាភិបាល (ជួនកាលមានឈ្មោះថាអង្គការមិនរកប្រាក់ចំណេញ) គឺជាអង្គការសង្គមស៊ីវិល ដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងជាក់លាក់ណាមួយ ឬច្រើន ជាញឹកញាប់មាន គោលដៅផ្នែកសង្គម ដូចជា ការកាត់បន្ថយភាពក្រីក្រ កិច្ចការពារ ឬលើកកម្ពស់សិទ្ធិរបស់ជនក្រីក្រ ការពារបរិស្ថាន ឬធ្វើការអភិវឌ្ឍន៍សហគមន៍។ អង្គការនេះ មិនមែនជារបស់រដ្ឋ ឬរាជរដ្ឋាភិបាលទេ ទោះបីអង្គការនេះ អាចសហការជាមួយរាជរដ្ឋាភិបាល (ជួនកាលយ៉ាងជិតស្និទ្ធ និង/ឬរយៈពេលវែង) ប្រសិនបើពួកគេមានគោលបំណង និងគោលដៅរួមគ្នា។

# អក្សរកាត់

| | |
|---|---|
| ADA | សម្ព័ន្ធភាពអភិវឌ្ឍន៍អាស៊ី |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BCC | ការប្រាស្រ័យទាក់ទងដើម្បីឲ្យមានការផ្លាស់ប្តូរឥរិយាបថ |
| CBO | អង្គការនៅតាមសហគមន៍ |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CHRAC | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| COSECAM | សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ច (ផ្លូវភេទ) លើកុមារក្នុងប្រទេសកម្ពុជា |
| CRDB | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| CSES | ការធ្វើអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| ECPAT | គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារនៅកម្ពុជា |
| GADC | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| IDPoor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| INGO | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| KHR | ប្រាក់រៀល (៤.០០០រៀល = ១ដុល្លារ) |
| LANGO | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| LNGO | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MEDiCAM | អង្គការសមាជិកភាពនៃអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពក្នុងផ្នែកសុខាភិបាលកម្ពុជា |
| MOFA | ក្រសួងការបរទេស |
| MOI | ក្រសួងមហាផ្ទៃ |
| MOU | អនុស្សរណៈយោគយល់គ្នា |
| NEP | ភាពជាដៃគូអប់រំ នៃអង្គការក្រៅរដ្ឋាភិបាល |
| NGO GPP | អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ នៃអង្គការមិនមែនរដ្ឋាភិបាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGOCRC | សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ODA | ហិរញ្ញប្បទានផ្ទាល់ពីបរទេស |
| UN | អង្គការសហប្រជាជាតិ |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា |
| US$ | ដុល្លារអាមេរិក (មួយដុល្លារ ស្មើនឹង ៥.០០០រៀល) |
| UXO | យុទ្ធភណ្ឌមិនទាន់ផ្ទុះ |
| VCS | ប្រព័ន្ធវិញ្ញាបនប័ត្រស្ម័គ្រចិត្ត |

# សេចក្តីសង្ខេប


របាយការណ៍នេះ បង្ហាញលទ្ធផលនៃសិក្សាអំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០១២ ដែលរៀបចំដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)។ ការសិក្សានេះមានគោលបំណង ដើម្បីស្វែងយល់ ពីលក្ខណៈរបស់អង្គការសង្គមស៊ីវិលកម្ពុជានិងព្យាយាមរិះរកមធ្យោបាយនានាដែលមានឥទ្ធិពលលើការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។

អង្គការ CCC បានធ្វើជំរឿន និងការសិក្សាលើអង្គការសង្គមស៊ីវិលជាលើកដំបូងក្នុងឆ្នាំ ២០១១ ដើម្បីស្វែងយល់ពីរបៀបដែលអង្គការសង្គមស៊ីវិល បានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ការសិក្សាឆ្នាំ២០១២នេះ បន្តពីការសិក្សាស្រាវជ្រាវ ឆ្នាំ២០១១ ពិនិត្យលើបញ្ហាដូចគ្នាជាច្រើន ទាក់ទងនឹងឥទ្ធិពលរបស់អង្គការសង្គមស៊ីវិល លើបញ្ហាមួយចំនួនរួមមាន អត្ថប្រយោជន៍សេដ្ឋកិច្ច អ្នកទទួលផល និងការងារ។ ការសិក្សា ឆ្នាំ២០១២ នេះ រួមមានការវិភាគលើទិន្នន័យជំរឿនលម្អិត និងការកើនឡើងអ្នកទទួលផល របស់អង្គការសង្គមស៊ីវិល ព័ត៌មានលម្អិតអំពីគម្រោង សហប្រតិបត្តិការ និងអភិបាលកិច្ច។ សូចនាករណ៍ ដែលត្រូវបានបន្ថែមទៅក្នុងការសិក្សាឆ្នាំ២០១២នេះ រួមមាន និន្នាការជ្រើសរើសបុគ្គលិក ការរំពឹងទុកអំពីមូលនិធិសម្រាប់ឆ្នាំ២០១៣ ចំនួនមូលនិធិរបស់អង្គការសង្គមស៊ីវិល ដែលផ្តល់ទៅ ឲ្យអង្គការសង្គមស៊ីវិលផ្សេងទៀត ព្រមទាំងការស្វែងយល់ និងភាពស្របគ្នា ជាមួយគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ជាងនេះទៀត បន្ថែមគំនិតយោបល់របស់ថ្នាក់ដឹកនាំអង្គការ អំពីឱកាសនៃសហប្រតិបត្តិការនាពេលអនាគត ព្រមទាំងសេចក្តីសង្ខេបអំពីការពិភាក្សាបែប គុណភាពជាមួយនាយកអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ដែលត្រូវបានជ្រើសរើស។

ការសិក្សាឆ្នាំ២០១២នេះ ត្រូវបានកែលម្អដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រនិងបង្កើតឲ្យមានការប៉ាន់ប្រមាណកាន់តែហ្មត់ចត់ អំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ឧទាហរណ៍ សំណាកនៃការសិក្សាសម្រាប់ ឆ្នាំ២០១២ ត្រូវបានជ្រើសរើសដោយចៃដន្យ ក្នុងចំណោមអង្គការសង្គមស៊ីវិលបើកដំណើរការ ដើម្បីផ្តល់ទិន្នន័យតំណាងបន្ថែម។ ការធ្វើបែបនេះ នាំឲ្យការសិក្សានេះគ្របដណ្តប់អង្គការ សង្គមស៊ីវិលក្នុងខេត្តចំនួន២០ និងរាជធានីភ្នំពេញ។

ការសិក្សាឆ្នាំ២០១២ បានរួមបញ្ចូលជំរឿនលើអង្គការសង្គមស៊ីវិលដែលបានចុះបញ្ជីក្នុងប្រទេសកម្ពុជា (ជាមួយក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស) ដើម្បីបញ្ជាក់ពីស្ថានភាពរបស់អង្គការសង្គមស៊ីវិល ព្រមទាំងធ្វើបច្ចុប្បន្នភាពសកម្មភាពការងារ និងព័ត៌មានដទៃទៀតរបស់

អង្គការ។ ក្នុងជំរឿនឆ្នាំ២០១២នេះ អង្គការសង្គមស៊ីវិលចំនួន ១.៣១៥ បានបញ្ជាក់ ស្ថានភាពរបស់ខ្លួនថា បើកដំណើរការ (បានទទួលមូលនិធិ ឬមិនទទួលបានមូលនិធិ)។ ក្នុងចំណោមអង្គការសង្គមស៊ីវិលទាំងនេះ មានអង្គការក្នុងស្រុកចំនួន ៦៧០ អង្គការអន្តរជាតិចំនួន ៣២១ និងសមាគមចំនួន ៣២៤។ ក្នុងចំណោម អង្គការសង្គមស៊ីវិលបើកដំណើរការចំនួន ១.៣១៥ នេះ មាន ៨៥,៩% (ស្មើនឹង១.១៣០ អង្គការ) គឺមានគម្រោងដែលទទួលបានមូលនិធិ និងបានអនុវត្តក្នុង ឆ្នាំ២០១២។

ការធ្វើជំរឿនឆ្នាំ២០១២នេះ ក៏បានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនូវការយល់ឃើញនៅក្នុងសហគមន៍អភិវឌ្ឍន៍ ជាពិសេសគោលបំណងក្នុងការផ្លាស់ប្តូរអង្គការសង្គមស៊ីវិល ពីអង្គការអន្តរជាតិ ទៅជាអង្គការក្នុងស្រុក (ចំនួន១៥ អង្គការ)។ នេះឆ្លុះបញ្ចាំងអំពីការយល់ឃើញដែលថា ការផ្តល់ជំនួយតាមរយៈអង្គការក្នុងស្រុក គឺមានប្រសិទ្ធភាព (បើប្រៀបធៀបការចំណាយ) កសាងសមត្ថភាពបុគ្គលិកក្នុងស្រុក និងធានាឲ្យមានការចូលរួមសកម្មរបស់សហគមន៍នៅក្នុងគម្រោង។

របាយការណ៍នេះក៏មានរួមបញ្ចូលនូវការបង្ហាញពី របកគំហើញចេញពីការអង្កេតដែលត្រូវបានធ្វើឡើងក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន ២៧១ ជ្រើសរើសដោយចៃដន្យ ចេញពីជំរឿននេះ។ ការសិក្សានេះមានគោលបំណងផ្តល់នូវទស្សនៈ និងការយល់ដឹង ច្បាស់លាស់ពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា ក្នុងឆ្នាំ២០១២។

**ស្ថានភាពទូទៅនៃអង្គការសង្គមស៊ីវិល**: ក្នុងឆ្នាំ ២០១២ មានអង្គការសង្គមស៊ីវិលបើកដំណើរការចំនួន ១.៣១៥ នៅក្នុងប្រទេសកម្ពុជា ដែលក្នុងចំណោមនេះ មានអង្គការចំនួន ១.១៣០ (ស្មើនឹង ៨៥.៩%) មានមូលនិធិ។ អង្គការសង្គមស៊ីវិលទាំងនេះ បានអនុវត្តគម្រោង ប្រហែល ៤.០០០ក្នុងឆ្នាំ២០១២ ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនចំនួន ១,៣ លាននាក់ ជាពិសេសតាមរយៈការងារក្នុងវិស័យអប់រំ សុខាភិបាល និងកសិកម្ម។ អង្គការសង្គមស៊ីវិលទាំងនេះ បានប្រើប្រាស់មូលនិធិប្រហែលពី ៦០០-៧០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ និងផ្តល់ការងារដោយផ្ទាល់ដល់មនុស្សចំនួនប្រហែល ៤៣.០០០ នាក់។

**បុគ្គលិក** : អង្គការសង្គមស៊ីវិលបានធ្វើការចូលរួមចំណែកយ៉ាងច្រើនដល់ការងារសរុបក្នុងប្រទេសកម្ពុជា។ លទ្ធផលនៃការសិក្សានេះ បង្ហាញថា អង្គការសង្គមស៊ីវិលផ្តល់ការងារដល់បុគ្គលិកប្រហែល ៤៣.០០០ នាក់ ក្នុងឆ្នាំ២០១២ ដែលក្នុងចំណោមនេះ មាន ២៤.០០០ នាក់ គឺជាបុគ្គលិកទទួលបានបៀវត្សរ៍ និងមាន ៤២% គឺជាស្ត្រី។ ក្នុងចំណោមបុគ្គលិកទទួលបៀវត្សរ៍ទាំងអស់មានបុគ្គលិកបរទេសប្រហែល ១.១០០នាក់ (តិចជាងម្នាក់ក្នុងមួយអង្គការ)និងបុគ្គលិកជាជនពិការចំនួន ៨០០ នាក់។

ការសិក្សាឆ្នាំ២០១២នេះ ក៏បានបង្ហាញពីនិន្នាការក្នុងការជ្រើសរើស និងរក្សាបុគ្គលិក នៅក្នុងអង្គការសង្គមស៊ីវិល។ ភាគច្រើននៃអ្នកដែលត្រូវបានជ្រើសរើសថ្មី មានការអប់រំកម្រិតឧត្តមសិក្សា (បរិញ្ញាបត្រ ឬក្រោយបរិញ្ញាបត្រ) ខណៈដែលបុគ្គលិកភាគច្រើនដែលបានលាឈប់ការងារពីអង្គការសង្គមស៊ីវិល ផ្លាស់ទៅកាន់វិស័យឯកជន ដោយធ្វើជាបុគ្គលិកទទួលបានបៀវត្សរ៍ ឬជាម្ចាស់អាជីវកម្ម។ ការសិក្សានេះ បានបង្ហាញពីការកើនឡើងសុទ្ធ នូវចំនួនអ្នកដែលបានចូលធ្វើការងារក្នុងអង្គការសង្គមស៊ីវិល ក្នុងឆ្នាំ២០១២។

**ហិរញ្ញវត្ថុ** : ការសិក្សាឆ្នាំ២០១២នេះ បានរាយការណ៍ពីការផ្តល់មូលនិធិ គិតជាមធ្យម ចំនួន ៥៧១.៣៧០ ដុល្លារអាមេរិក ក្នុងអង្គការសង្គមស៊ីវិលមួយ នៅក្នុងសំណាកនេះ (ចំនួន ២០០ អង្គការ)។ ដើម្បីបង្ហាញចំនួនថវិកានេះ ជាទ្រង់ទ្រាយធំ យើងអាចនិយាយបានថា អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា មានថវិកាសរុបចំនួនប្រហែលពី ៦០០ ទៅ ៧០០ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២ ដោយផ្តល់មូលនិធិដល់ការអនុវត្តន៍គម្រោង និង សកម្មភាពអង្គការ។ ក្នុងចំណោមថវិកាទាំងនេះ មូលនិធិ ៧២,៤% ចំណាយទៅលើគម្រោងដោយផ្ទាល់។

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ បានផ្តល់មូលនិធិដល់អង្គការសង្គមស៊ីវិលភាគច្រើន (៤១,២% ស្មើនឹង ៩៨ អង្គការ) ដោយមូលនិធិបន្ថែមភាគច្រើន បានមកពីទីភ្នាក់ងារពហុភាគី អំណោយឯកជន និងមូលនិធិផ្ទាល់ខ្លួនរបស់អង្គការសង្គមស៊ីវិល (ប្រាក់ចំណូល ដែលរកបាន)។ អង្គការសង្គមស៊ីវិល បានឆ្លុះបញ្ចាំងពីបរិយាកាសវិជ្ជមាននៅក្នុងវិស័យនេះ សម្រាប់ឆ្នាំខាងមុខ ទាក់ទងនឹងមូលនិធិ ដោយអង្គការភាគច្រើនជឿជាក់ថា ការផ្តល់មូលនិធិ នឹងមានការកើនឡើង ឬស្ថិតនៅដដែល ដូចគ្នានឹងឆ្នាំ២០១២។

**សកម្មភាព**: ៨៧,៨% នៃអង្គការសង្គមស៊ីវិលដែលត្រូវធ្វើសម្ភាសន៍បានអនុវត្តគម្រោងក្នុងឆ្នាំ២០១២ ដោយគិតជាមធ្យម អង្គការសង្គមស៊ីវិលនីមួយៗ មានគម្រោងចំនួន ៣,៥។ គម្រោងប្រហែល ៤.០០០ ត្រូវបានអនុវត្តក្នុងឆ្នាំ២០១២ ដែលក្នុងនោះអ្នកទទួលផលមានចំនួនជាង ១.៣០០.០០០ នាក់ (ចំនួននេះជាការប៉ាន់ស្មានកម្រិតទាបប៉ុណ្ណោះ ហើយចំនួនពិតប្រាកដអាចនឹងខ្ពស់ជាងនេះច្រើន)។ អង្គការសង្គមស៊ីវិល បានរាយការណ៍អំពីការកំណត់គោលដៅក្រុមទទួលផលផ្សេងៗគ្នាចំនួន១៣ក្រុម ហើយក្រុមគោលដៅចម្បង គឺកុមារ (២៣,២%)។

នៅក្នុងការសិក្សានេះ អង្គការសង្គមស៊ីវិល បានរាយការណ៍អំពីការធ្វើការងារលើវិស័យចម្បងផ្សេងៗគ្នាចំនួន ១៩។ វិស័យសំខាន់បំផុតចំនួនបួន គឺ ការអប់រំ និងការបណ្តុះបណ្តាល (៣២,១% នៃអង្គការសង្គមស៊ីវិល) កសិកម្ម និងសុខភាពសត្វ (៩,៦%) សុខាភិបាល អាហារូបត្ថម្ភ និងមេរោគអេដស៍/ជំងឺអេដស៍(៩,៦%) ព្រមទាំងសុខុមាលភាព និងសិទ្ធិកុមារ (៦,៦%)។ យោងទៅតាមអង្គការសង្គមស៊ីវិល តម្រូវការរបស់សហគមន៍គឺជាកត្តាជំរុញចម្បងដែលកំណត់

គោលដៅនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិល បានរកឃើញនូវសេចក្តីត្រូវការរបស់សហគមន៍ទាំងនេះ តាមរយៈការស្រាវជ្រាវ និងការពិភាក្សា ដោយមានការចូលរួមពីសហគមន៍។

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលសម្របគម្រោងរបស់ខ្លួន ជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាចំនួនបី ដែលអង្គការសង្គមស៊ីវិល បានចូលរួមចំណែកសំខាន់បំផុត គឺលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ (៨៩,២%) សម្រេចឲ្យបានសកលកម្មអប់រំមូលដ្ឋាន (៩៥,៨%) ព្រមទាំងលើកកម្ពស់ សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី (៨៤,១% នៃអង្គការសង្គមស៊ីវិល)។

រាជធានីភ្នំពេញ គឺជាទីកន្លែងដែលត្រូវបានផ្តោតគោលដៅបំផុត សម្រាប់គម្រោងរបស់អង្គការសង្គមស៊ីវិល ដោយជាង៣០% នៃអង្គការសង្គមស៊ីវិល មានគម្រោងយ៉ាងហោចណាស់មួយនៅទីនោះ ។ សៀមរាប បាត់ដំបង និងកំពង់ចាម គឺជាខេត្តដែលមានគម្រោងរបស់អង្គការសង្គមស៊ីវិលច្រើនជាងគេ។ ខេត្តទាំងនេះក៏មានចំនួនប្រជាជនច្រើនជាងគេផងដែរ ហើយគឺជាខេត្តដែលមានការិយាល័យរបស់អង្គការសង្គមស៊ីវិលច្រើនជាងគេ ក្រៅពីរាជធានីភ្នំពេញ។

**ការសម្របសម្រួល និងសហប្រតិបត្តិការ** : សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល គឺមានផលប្រយោជន៍ដល់អង្គការសង្គមស៊ីវិលទាំងអស់ និងអាចលើកកម្ពស់ ការចូលរួមចំណែករបស់ខ្លួនដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាទាំងមូល។ ការរៀបចំផែនការផ្លូវការនិងក្រៅផ្លូវការ រវាងអង្គការសង្គមស៊ីវិលដែលបានចុះបញ្ជី និងជាមួយនឹងអង្គការ នៅតាមសហគមន៍ គឺមានសារសំខាន់ក្នុងការអភិវឌ្ឍន៍គម្រោងឲ្យមានប្រសិទ្ធភាពក្នុងតំបន់គោលដៅ។ ៥៣,១% នៃអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការសិក្សានេះ បានរាយការណ៍ថា ពួកគេមានផែនការយ៉ាងតិចមួយ ជាមួយអង្គការសង្គមស៊ីវិល ឬអង្គការនៅតាមសហគមន៍ផ្សេង។ បន្ថែមពីនេះទៀត ៦៩%នៃអង្គការសង្គមស៊ីវិល គឺបានចូលរួមក្នុងបណ្តាញអង្គការសង្គមស៊ីវិល ក្នុងឆ្នាំ ២០១២ ដោយអង្គការ CCC គឺជាបណ្តាញដែលបានលើកឡើងច្រើនជាងគេបំផុត (៤១,៦%)។

**អភិបាលកិច្ច** : របាយការណ៍សិក្សាឆ្នាំ២០១២នេះ បង្ហាញថា អង្គការសង្គមស៊ីវិល ភាគច្រើន ប្រតិបត្តិស្វ័យអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ ៩៥,៩% នៃអង្គការសង្គមស៊ីវិលមានច្បាប់ និង/ឬលក្ខន្តិកៈជាលាយលក្ខណ៍អក្សរ ៧៥,៣% មានផែនការយុទ្ធសាស្ត្រ និងជាង៥០% បានធ្វើសវនកម្មខាងក្រៅ (អង្គការ និង/ឬគម្រោង)។ នេះគឺជាសូចនាករណ៍ល្អមួយ នៃតម្លាភាពនៅក្នុង អង្គការសង្គមស៊ីវិល។

អង្គការ CCC បានបង្កើតប្រព័ន្ធគណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងឆ្នាំ២០០៧ ដែលមានឈ្មោះអភិបាលកិច្ចនិងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនៃអង្គការមិនមែនរដ្ឋាភិបាល (NGO GPP)។ ប្រព័ន្ធនេះគឺជាឧបករណ៍មួយដើម្បីពង្រឹងការប្រតិបត្តិស្វ័យអភិបាលកិច្ច និងរក្សាបាននូវស្តង់ដារខ្ពស់ដែលអង្គការសង្គមស៊ីវិលផ្អែកលើ។ ១៧,៧% នៃអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការសិក្សានេះ មានបំណងដាក់ពាក្យសុំវិញ្ញាបនប័ត្រ នាពេលអនាគត នេះបង្ហាញពីការបន្តការប្តេជ្ញាចិត្ត ក្នុងការប្រតិបត្តិអភិបាលកិច្ច និងគ្រប់គ្រងដោយខ្លួនឯង។

**សហប្រតិបត្តិការនាពេលអនាគត** : ៨២,៧% នៃអង្គការសង្គមស៊ីវិល នឹងស្វាគមន៍មជ្ឈមណ្ឌលអង្គការសង្គមស៊ីវិលមួយ នៅក្នុងខេត្ត ឬរាជធានីភ្នំពេញ ដោយជឿជាក់ថា ការធ្វើដូច្នេះនឹងធ្វើឲ្យមានភាពប្រសើរឡើងនូវការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការ ក្នុងចំណោមអង្គការសង្គមស៊ីវិល។ ៧៩,៣% សង្ឃឹមថា ការធ្វើដូច្នេះ នឹងជួយបំពេញតម្រូវការរបស់សហគមន៍ឲ្យកាន់តែប្រសើរឡើង និង ៦៩,៧% ជឿជាក់ថា ការធ្វើដូច្នេះ អាចជួយសន្សំសំចៃថវិកា និងជួយអង្គការឲ្យកាន់តែមានប្រសិទ្ធភាព។

ផែនការសម្រាប់សហប្រតិបត្តិការនាពេលអនាគតមួយទៀត គឺ ការបង្កើតមូលនិធិជាតិសំរាប់អង្គការសង្គមស៊ីវិល ដែលវាជាកន្លែងទទួលមូលនិធិពីម្ចាស់ជំនួយ ក្នុងប្រទេសកម្ពុជា។ ៦១,៦% នៃអ្នកផ្តល់ចម្លើយ ជឿជាក់ថា តាមរយៈយន្តការនេះ ការផ្តល់មូលនិធិ អាចនឹងផ្តោតលើតម្រូវ ការរបស់សហគមន៍បានកាន់តែប្រសើរ។

មានតែ ៤៨,៧% នៃអង្គការសង្គមស៊ីវិលប៉ុណ្ណោះ យល់ឃើញថា អ្នកដែលទើបនឹងបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យថ្មីៗ មានជំនាញសមស្របក្នុងការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល។ ដោយសារការយល់ឃើញបែបនេះមាន៩៤,១% នៃអង្គការសង្គមស៊ីវិលជឿជាក់ថាអង្គការសង្គមស៊ីវិល គួរតែមានតួនាទីក្នុងការផ្តល់ការអប់រំពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលដល់និស្សិតសាកលវិទ្យាល័យ។ ការមាននិស្សិតបញ្ចប់ការសិក្សាដែលមានជំនាញសមស្របក្នុងការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល នឹងផ្តល់អត្ថប្រយោជន៍ដល់អង្គការសង្គមស៊ីវិលព្រមទាំងអ្នកទទួលផលគោលដៅផងដែរ នាពេលអនាគត។

## អនុសាសន៍

អនុសាសន៍សំខាន់ៗសម្រាប់ការចូលរួមរៀបចំគោលនយោបាយដូចខាងក្រោម:

- លើកកម្ពស់សហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល។ ការធ្វើដូច្នេះ អាចសម្រេចបានតាមរយៈការកើនឡើងនូវការចូលរួមក្នុងបណ្តាញអង្គការសង្គមស៊ីវិល និងការលើកទឹកចិត្តឲ្យមាន កិច្ចព្រមព្រៀងរវាងអង្គការសង្គមស៊ីវិល។ បន្ថែមពីនេះទៀត ៨៣% នៃអង្គការសង្គមស៊ីវិល យល់ឃើញថា ការបង្កើតមជ្ឈមណ្ឌលអង្គការសង្គមស៊ីវិល នឹងធ្វើឲ្យទំនាក់ទំនងការងាររវាងអង្គការផ្សេងៗ កាន់តែប្រសើរឡើង។

- បង្កើនការប្រតិបត្តិសវនកម្មខាងក្រៅ និងវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្តនៃអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ នៃអង្គការមិនមែនរដ្ឋាភិបាល។ ជាលក្ខណៈអន្តរជាតិ និន្នាការក្នុងអង្គការសង្គមស៊ីវិល គឺឆ្ពោះទៅរកកំណើននិយតកម្ម។ ការបង្កើនការយល់ដឹង និងការចូលរួមក្នុងប្រព័ន្ធវិញ្ញាបនបត្រនៃអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជា ជីវៈនៃអង្គការមិនមែនរដ្ឋាភិបាល របស់អង្គការ CCC គឺជាមធ្យោបាយល្អមួយសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់បរិយាកាសនិយតកម្មផ្ទាល់ខ្លួន ដោយមិនមានដាក់កម្រិតដល់ប្រតិបត្តិការ ឬសេរីភាពអង្គការសង្គមស៊ីវិលឡើយ។

- លើកកម្ពស់ឲ្យមានភាពស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រថ្នាក់ជាតិ។ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុកជាច្រើនដែលបានចូលរួមក្នុងការសិក្សានេះ មិនបានដឹងច្បាស់អំពីគោលដៅអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិរបស់ប្រទេសកម្ពុជាឡើយ ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ការធ្វើឲ្យប្រាកដថា អង្គការសង្គមស៊ីវិលទាំងអស់ សម្របគម្រោងរបស់ខ្លួន ជាមួយនឹងយុទ្ធសាស្ត្រទាំងនេះ គឺជាមធ្យោបាយមួយក្នុងការធានាថា ធនធានរបស់អង្គការសង្គមស៊ីវិល ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍន៍ជាតិ។ នេះអាចសម្រេចទៅបាន តាមរយៈការបង្កើននូវការចែករំលែកព័ត៌មាន និងសហការរវាងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងម្ចាស់ជំនួយ ដោយបណ្តាញអង្គការសង្គមស៊ីវិល ដើរតួនាទីសំខាន់នៅក្នុងដំណើរការនេះ ជាជនបង្គោលសម្រាប់ចែករំលែកព័ត៌មាន និងជាតំណាងអង្គការសង្គមស៊ីវិល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងការពិភាក្សា។

- លើកកម្ពស់ការកំណត់គោលដៅរបស់អង្គការសង្គមស៊ីវិល។ ទោះបីជា ៨០% នៃប្រជាជនកម្ពុជា រស់នៅតំបន់ជនបទក៏ដោយ ក៏ជាង ៣២% នៃអង្គការសង្គមស៊ីវិល អនុវត្តគម្រោងនៅរាជធានីភ្នំពេញ ដែលជាទីកន្លែងអនុវត្តគម្រោងច្រើនជាងគេបំផុតនៅក្នុងប្រទេស។ បន្ថែមពីនេះទៀត ការប្រៀបធៀបទីតាំងអង្គការសង្គមស៊ីវិល ជាមួយនឹងខេត្តក្រីក្របំផុតនៅក្នុង

ប្រទេសកម្ពុជា (ដូចដែលបានកំណត់ដោយ គម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ) បង្ហាញថា ខេត្តមួយចំនួនក្នុងចំណោមខេត្តដែលក្រីក្របំផុតនៅក្នុងប្រទេសកម្ពុជា (ដូចជាខេត្តព្រៃវែង និងតាកែវ) មានតំណាងមិនគ្រប់គ្រាន់ក្នុងចំណោមអង្គការសង្គមស៊ីវិល។ ក្នុងករណីនេះ ការធ្វើឲ្យប្រសើរឡើងនូវការចងជាបណ្តាញ ការសម្របសកម្មភាពក្នុងចំណោមអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ព្រមទាំងការទទួលបានការសិក្សាស្រាវជ្រាវសមស្រប និងព័ត៌មាន កត្តាទាំងនេះនឹងជួយអង្គការសង្គមស៊ីវិល ក្នុងការកំណត់គោលដៅ ការផ្តល់មូលនិធិ និងធនធានគម្រោង ឲ្យកាន់តែមានប្រសិទ្ធភាព។

# សេចក្តីផ្តើម

អង្គការសង្គមស៊ីវិល (CSOs) គឺជាអង្គការមិនមែន រាជរដ្ឋាភិបាល គ្រួសារ និងសហគ្រាសឯកជន ហើយប្រឹងប្រែងផ្តល់ផលប្រយោជន៍ដល់ក្រុមមនុស្ស ឬមិនរកប្រាក់ចំណេញ (ជាញឹកញាប់ដើម្បីផលប្រយោជន៍រួម)។ ចាប់តាំងពីកើតឡើងជាថ្មី នៃអង្គការសង្គមស៊ីវិល នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ វាបានដើរតួនាទីយ៉ាងសំខាន់ ចំពោះការរើបឡើងវិញរបស់កម្ពុជាពីភាពឯកោ និងជម្លោះអស់ជាច្រើនទសវត្សរ៍។ ចាប់តាំងពីពេលនោះមក អង្គការសង្គមស៊ីវិលបានក្លាយជាអ្នកចូលរួមយ៉ាងសកម្មនៅគ្រប់ទិដ្ឋភាពទាំងអស់នៃសង្គម និងគោលនយោបាយសាធារណៈកម្ពុជា ដោយធ្វើការរួមគ្នាជាមួយនឹងក្រសួងស្ថាប័នរដ្ឋនៅគ្រប់ខេត្តក្រុង ដើម្បីជួយធានាថា ការចូលរួមទាំងអស់គ្នា នៅក្នុងការរីកចម្រើន និងការអភិវឌ្ឍន៍ប្រទេស។ ក្នុងវិស័យផ្សេងៗជាច្រើនទៀត អង្គការសង្គមស៊ីវិល បានផ្តល់សេវាកម្ម និងព័ត៌មានដ៏សំខាន់ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ តែជាញឹកញាប់មានការទទួលស្គាល់តិចតួចឬមិនទទួលស្គាល់ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

គម្រោងរបស់អង្គការសង្គមស៊ីវិលជាច្រើន ធ្វើឡើងដើម្បីសង្គមទូទៅ។ ដូច្នេះហើយ វាមានការពិបាកក្នុងការកំណត់បរិមាណនៃឥទ្ធិពល ឬលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដោយសារតែមិនមានគោលដៅ ឬលទ្ធផលតែមួយ ដែលកំណត់ពីប្រសិទ្ធភាពនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ជាញឹកញាប់ មធ្យោបាយដ៏ល្អបំផុតក្នុងការវិនិច្ឆ័យប្រសិទ្ធភាពរបស់គម្រោង គឺធ្វើការតាមដាន និងរាយការណ៍ជាប្រចាំ ព្រមទាំងធ្វើការវាយតម្លៃពីឥទ្ធិពលឲ្យបានប្រិតប្រៀង ដើម្បីវាស់វែងឥទ្ធិពលរបស់គម្រោង ទៅលើមនុស្ស នៅអំឡុងពេលណាមួយ។ ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពទាំងនេះ អាចមានការចំណាយច្រើន និងតម្រូវឲ្យមានជំនាញឯកទេស ដែលអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសមាគមតូចៗ ដែលភាគច្រើនជាអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ជាទូទៅ មិនមានជំនាញបែបនេះ។ លើសពីនេះទៀត ការបូកសរុបលទ្ធផលពីគម្រោងទាំងអស់ នឹងតម្រូវឲ្យមានធនធាន និងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង។

ដើម្បីបង្ហាញពីប្រសិទ្ធភាពរបស់វិស័យអង្គការសង្គមស៊ីវិល ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) បានធ្វើជំរឿន និងសិក្សាស្រាវជ្រាវលើអង្គការសង្គមស៊ីវិលជាលើកដំបូងក្នុង ឆ្នាំ២០១១។ ការសិក្សាស្រាវជ្រាវនេះ គឺជាការប្រឹងប្រែងអស់ពីចិត្តជាលើកដំបូង ដើម្បីតាមដានអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ដែលបានចុះបញ្ជី តាមរយៈជំរឿនលើកំណត់ត្រាចុះបញ្ជីរបស់រាជរដ្ឋាភិបាល

ព្រមទាំងផ្តល់នូវសេចក្តីសង្ខេប និងធ្វើការវិភាគពីវិធីដែលអង្គការសង្គមស៊ីវិល បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ជាតិ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

ដោយបញ្ចូលការធ្វើជំរឿន និងការអង្កេត ការសិក្សានេះ មានគោលបំណងស្វែងយល់ពីលក្ខណៈបច្ចុប្បន្ននៃអង្គការសង្គមស៊ីវិលកម្ពុជា និងវិវរកមធ្យោបាយជាច្រើន ដែលអង្គការសង្គមស៊ីវិល អាចមានឥទ្ធិពលលើការភិវឌ្ឍន៍ប្រទេសកម្ពុជា។ ការសិក្សានេះ កើតឡើងបន្ទាប់ពីការសិក្សា ឆ្នាំ២០១១ ស្តីពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដែលរៀបចំឡើងដោយអង្គការ CCC ហើយការសិក្សានេះ ធ្វើឡើងដោយមានការពិនិត្យ និងការឆ្លុះបញ្ចាំងពីខ្លួនឯងបន្ថែមទៀត នៅក្នុងសហគមន៍អង្គការសង្គមស៊ីវិល។ ការសិក្សាទាំងនេះ មានផែនការរៀបចំធ្វើឡើងប្រចាំឆ្នាំ ដើម្បីបង្ហាញពីសមត្ថភាពរបស់វិស័យអង្គការសង្គមស៊ីវិល ក្នុងការគិតដោយម៉ត់ចត់អំពីខ្លួនឯង និងសមាជិករបស់ខ្លួន ហើយការសិក្សាទាំងនេះ ក៏មានបំណងបើកដំណើរការឲ្យមានការពិភាក្សាបន្ថែមទៀតផងដែរ ស្តីពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការតាមដាន និងនិយ័តកម្ម ព្រមទាំងការកំណត់ពីជោគវាសនាផ្ទាល់ខ្លួនរបស់ពួកគេ។

ការសិក្សាឆ្នាំ២០១២នេះ បំពេញលើការសិក្សាស្រាវជ្រាវឆ្នាំ២០១១ និងពិនិត្យលើបញ្ហាដូចគ្នាជាច្រើន ទាក់ទងនឹងឥទ្ធិពលរបស់អង្គការសង្គមស៊ីវិលលើបញ្ហាមួយចំនួនរួមមាន អត្ថប្រយោជន៍សេដ្ឋកិច្ច អ្នកទទួលផល និងការផ្តោតលើភូមិសាស្ត្រ។ បន្ថែមពីនេះ មានការបញ្ចូលផ្នែកមួយចំនួនទៀត ដើម្បីយល់ឲ្យកាន់តែច្បាស់ពីសហប្រតិបត្តិការ និងស្វ័យអភិបាលកិច្ច ដោយសារតែផ្នែកទាំងនេះ បានក្លាយជាប្រធានបទសំខាន់ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ សម្រាប់ការពិភាក្សាចំណោមអង្គការសង្គមស៊ីវិល។ ការសិក្សាឆ្នាំ២០១២នេះ ត្រូវបានកែលម្អដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រ និងបង្កើតឲ្យមានការប៉ាន់ប្រមាណកាន់តែហ្មត់ចត់ អំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

របាយការណ៍នេះ ត្រូវបានគេរំពឹងថា អាចជាមូលដ្ឋានគ្រឹះសម្រាប់អង្គការសង្គមស៊ីវិលធ្វើការឆ្លុះបញ្ចាំងពីខ្លួនឯងបន្ថែមទៀត ដោយផ្តល់ឱកាសដល់សមាជិក ធ្វើការវាយតម្លៃដោយស្មោះត្រង់លើខ្លួនឯង និងស្ថានភាពរបស់វិស័យអង្គការសង្គមស៊ីវិលកម្ពុជា។ ដោយមានកិច្ចខិតខំប្រឹងប្រែងចុងក្រោយ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០១៥ និងការបង្កើតផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិថ្មីមួយសម្រាប់ឆ្នាំ២០១៤-២០១៨ គេសង្ឃឹមថា ការសិក្សានេះ នឹងជួយអង្គការសង្គមស៊ីវិលក្នុងផែនការយុទ្ធសាស្ត្ររបស់ពួកគេ សម្រាប់ឆ្នាំខាងមុខតាមរយៈការកំណត់អត្តសញ្ញាណនៃបញ្ហាប្រឈម និងវិស័យជាក់លាក់ ដើម្បីឲ្យមានការរីកចម្រើន។

# សាវតា

ផ្នែកនេះ ផ្តោតទៅលើព្រឹត្តិការណ៍ និងការស្រាវជ្រាវសំខាន់ៗ ដែលធ្វើឡើងក្នុងវិស័យនេះ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១២ និងឥទ្ធិពលរបស់វា មកលើអង្គការសង្គមស៊ីវិលកម្ពុជា។ មានវិស័យចំនួនបីដែលបានវិវត្តន៍សំខាន់នៅឆ្នាំចុងក្រោយនេះពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលកម្ពុជា ពោលគឺទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា រួមមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់កម្ពុជា (LANGO) ការកើនឡើងនូវការផ្តោតលើសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ (ដោយអង្គការសង្គមស៊ីវិលកម្ពុជាលេច មុខជាងគេ) ព្រមទាំងកើនឡើងនូវការផ្តោតលើស្វ័យអភិបាលកិច្ច និយ័តកម្ម និងតម្លាភាព។

## ព្រឹត្តិការណ៍ក្នុងស្រុក

ប្រទេសកម្ពុជា គឺជាកន្លែងមួយដែលមានអង្គការសង្គមស៊ីវិលជាច្រើន។ កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសក្រក្រីបំផុតនៅទ្វីបអាស៊ី។ បន្ទាប់ពីភាពឯកោ និងជម្លោះជិតពីរទសវត្សរ៍ ប្រទេសកម្ពុជា បានបើកចំហទៅកាន់ពិភពលោកសម័យទំនើប នៅពេលមានការមកដល់នៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) ក្នុងឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣។ ថវិកា UNTAC ចំនួន ១,៦ ពាន់លានដុល្លារអាមេរិក ភាគច្រើនត្រូវបានគ្រប់គ្រងដោយអង្គការសង្គមស៊ីវិល ដែលស្ថិតក្នុងប្រទេសកម្ពុជា ក្រោយពេលដែល UNTAC ត្រូវបានរំសាយ ហើយប្រទេសកម្ពុជា បានឈានចូលដល់ពេលវេលាមានសន្តិភាព និងកំណើនសេដ្ឋកិច្ច។ ចាប់តាំងពីពេលនោះមក តម្រូវការចុះបញ្ជីអប្បបរមា និងកំណើនមូលនិធិអភិវឌ្ឍន៍ និងជំនួយ នាំឲ្យអង្គការសង្គមស៊ីវិលមានការកើនឡើង (ទាំងក្នុងស្រុក និងអន្តរជាតិ) ដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

អស់រយៈពេលជាច្រើនឆ្នាំ ប្រទេសកម្ពុជា ត្រូវបានគេយល់ឃើញថាជា "ជម្រកសម្រាប់អង្គការមិនមែនរដ្ឋាភិបាល" ដោយមានការផ្តល់មូលនិធិយ៉ាងច្រើនមកពីដៃគូអភិវឌ្ឍន៍ជាតិ និងអង្គការអន្តរជាតិ និងបរិយាកាសធូរស្រាលផ្នែកនិយតកម្ម។ ប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានប្រឹងប្រែងរឹតបន្តឹងតម្រូវការ និងការកំហិតលើវិស័យអង្គការសង្គមស៊ីវិល។ សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គឺជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់បំផុត ដែលសេចក្តីព្រាងច្បាប់នេះ បច្ចុប្បន្នកំពុងតែស្ថិតនៅក្រោមការពិនិត្យឡើងវិញ ដោយស្ថាប័នជាន់ខ្ពស់របស់រាជរដ្ឋាភិបាល។ តំណាងអង្គការសង្គមស៊ីវិល អះអាងថា ច្បាប់នេះ នឹងរឹតបន្តឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការប្រតិបត្តិដោយឯករាជ្យ ហើយផ្នែកនៃ

ច្បាប់នេះ អាចត្រូវបានប្រើប្រាស់ដើម្បីផ្តន្ទាទោស ឬដាក់កំហិតអង្គការសង្គមស៊ីវិល កុំឲ្យមានប្រតិបត្តិការលើចំណុចរសើបផ្នែកនយោបាយ។ បន្ថែមពីនេះទៀត ច្បាប់នេះ ដែលតម្រូវឲ្យមានការចុះបញ្ជី និងផ្តល់របាយការណ៍ នឹងដាក់កំហិតដល់ការបង្កើតសមាគម និងអង្គការនៅតាមសហគមន៍តូចៗ។ ទោះបីជាអង្គការសង្គមស៊ីវិល/អង្គការនៅតាមសហគមន៍មូលដ្ឋាន ជាទូទៅខ្វះខាតមូលនិធិ និងបទពិសោធន៍ ដើម្បីបំពេញតាមតម្រូវការដ៏តឹងតែងរបស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឲ្យមានប្រសិទ្ធភាពក៏ដោយ ប៉ុន្តែ អង្គការទាំងនេះ ដើរតួនាទីយ៉ាងសកម្ម តំណាងឲ្យសេចក្តីត្រូវការ និងការពារសិទ្ធិរបស់ប្រជាជនកម្ពុជាទូទៅ។

បន្ទាប់ពីមានការប្រឆាំងតវ៉ាឥតសំចៃ ដោយអង្គការសង្គមស៊ីវិល និងតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅលើការចេញសេចក្តីព្រាងច្បាប់លើកទី៤ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល កាលពីចុងឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជា បានពន្យារអនុម័តច្បាប់នេះ និងបង្វែរចំណាប់អារម្មណ៍ទៅលើការបោះឆ្នោតឃុំ-សង្កាត់និងជាតិ ក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ វិញ។ គេរំពឹងថា ការងារនីតិកម្មលើច្បាប់សំខាន់នេះ នឹងដំណើរការឡើងវិញក្រោយពីព្រឹត្តិការណ៍ទាំងនេះ។

កាលពីចុងឆ្នាំ២០១២ ក៏ឃើញមានការចេញផ្សាយនូវរបាយការណ៍ស្តីពី *និន្នាការសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា និងសំណើឲ្យមាន ការតាមដានលើភាពជាដៃគូអភិវឌ្ឍន៍នាពេលអនាគត* (ឆ្នាំ២០១៣) ដោយគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC)។ របាយការណ៍នេះ សង្កត់ធ្ងន់លើគម្រោងចំណាយ និងរបៀបសម្របជំនួយ របស់អង្គការសង្គមស៊ីវិល ជាមួយនឹងពិធីការជាតិ និងអន្តរជាតិ។ របាយការណ៍នេះ ក៏បានបង្ហាញពីការផ្លាស់ប្តូរនិន្នាការ នៅក្នុងជំនួយអភិវឌ្ឍន៍ជាតិ និងការផ្លាស់ប្តូរជំនួយអភិវឌ្ឍន៍ ពីវិស័យសុខាភិបាល (តាមទម្លាប់ វិស័យសុខាភិបាល គឺជាអ្នកទទួលហិរញ្ញប្បទានផ្ទាល់ពីបរទេស ច្រើនជាងគេបង្អស់) ទៅកាន់វិស័យគមនាគមន៍ មួយផ្នែក ដោយការកើនឡើងយ៉ាងខ្លាំង នូវជំនួយមកពីប្រទេសចិន។ នេះគឺជារបាយការណ៍ ប្រចាំឆ្នាំចុងក្រោយ មុនពេលដែលគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចាប់ផ្តើមធ្វើសេចក្តីព្រាងយុទ្ធសាស្ត្រសហប្រតិបត្តិការនិងភាពជាដៃគូអភិវឌ្ឍន៍ សម្រាប់ឆ្នាំ២០១៤-២០១៨។

អង្គការសង្គមស៊ីវិល កំពុងរង់ចាំឱកាសមួយចំនួន ក្នុងឆ្នាំខាងមុខនេះ ដើម្បីចូលរួមក្នុងផែនការដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍ជាតិ និងការអភិវឌ្ឍន៍តាមផ្នែក។ ឆ្នាំ២០១២ ឃើញមានគំនិតផ្តួចផ្តើមរៀបចំធ្វើសេចក្តីព្រាង អំពីផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) សម្រាប់ឆ្នាំ២០១៤-២០១៨ ដែលគំនិតផ្តួចផ្តើមរៀបចំនេះ នឹងបន្តរហូតដល់ចប់ឆ្នាំ២០១៣។ ផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាផែនការយុទ្ធសាស្ត្រដ៏ធំបំផុត ដែលបង្កើតឡើងដោយ រាជរដ្ឋាភិបាលកម្ពុជា ដែលរៀបរាប់លម្អិតពីគោលនយោបាយសាធារណៈ និងគោលដៅអភិវឌ្ឍន៍សម្រាប់ប្រាំឆ្នាំខាងមុខ។ ដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា មូនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក បន្ស៊ីយុទ្ធសាស្ត្ររបស់ខ្លួន ទៅនឹងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ។ ឯកសារយុទ្ធសាស្ត្រតាមផ្នែកមួយចំនួន ដែលជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងត្រូវបានបង្កើតឡើង។ ឯកសារទាំងនេះមាន យុទ្ធសាស្ត្រសហប្រតិបត្តិការ និងភាពជាដៃគូអភិវឌ្ឍន៍ សម្រាប់ឆ្នាំ ២០១៤-២០១៨ ដែលព្រាងដោយគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានបំណងបង្កើតយុទ្ធសាស្ត្រថ្មី សម្រាប់បង្កើនប្រសិទ្ធភាពអភិវឌ្ឍន៍ តាមរយៈការលើកកម្ពស់សកម្មភាពអនុវត្ត និងតាមដាន។

## កិច្ចការក្នុងតំបន់ និងអន្តរជាតិ

ជាលក្ខណៈអន្តរជាតិ សកម្មភាពជាច្រើនក្នុងវិស័យអង្គការសង្គមស៊ីវិល បានផ្តោតលើព្រឹត្តិការណ៍ធំពីរ គឺ ១) ការអនុវត្តន៍គោលការណ៍ Istanbul ដែលត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ ២០១១ និង ២) ការរៀបចំបញ្ចប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ក្នុងឆ្នាំ២០១៥ ។

ដើម្បីដោះស្រាយបញ្ហាទាំងពីរនេះ និងបញ្ហាផ្សេងទៀត នៅដើមឆ្នាំ២០១៣ សម្ព័ន្ធភាពអភិវឌ្ឍន៍អាស៊ី (ADA) ត្រូវបានបង្កើតឡើង និងបានចេញផ្សាយ សេចក្តីថ្លែងការណ៍ទីក្រុងបាងកក ឆ្នាំ២០១៣។ សម្ព័ន្ធភាពអភិវឌ្ឍន៍អាស៊ី ដែលជាសម្ព័ន្ធភាពក្នុងតំបន់ នៃអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល មានគោលបំណងលើកកម្ពស់សហប្រតិបត្តិការ និងការប្រាស្រ័យទាក់ទងគ្នា ក្នុងចំណោមបណ្តាញសមាជិករបស់ខ្លួន។ យោងតាមសេចក្តីថ្លែងការណ៍ទីក្រុងបាងកក សម្ព័ន្ធភាពអភិវឌ្ឍន៍អាស៊ី បានបញ្ជាក់ពីគោលបំណងស្នូលរបស់ខ្លួនក្នុងការលើកកម្ពស់សកម្មភាពរបស់អង្គការសង្គមស៊ីវិល ឲ្យមានប្រសិទ្ធភាព តាមរយៈការបណ្តុះបណ្តាល និងការតស៊ូមតិ ជាពិសេសតាមរយៈធ្វើជាជនបង្គោលនៅក្នុងទ្វីបអាស៊ី ដើម្បីអនុវត្តគោលការណ៍ Istanbulនិងកិច្ចព្រមព្រៀងយោបល់ក្នុងខេត្តសៀមរាបសម្រាប់ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍របស់អង្គការសង្គមស៊ីវិល។ អង្គការ CCC គឺជាសមាជិកស្ថាបនិកមួយ នៃសម្ព័ន្ធអភិវឌ្ឍន៍អាស៊ីហើយ"គំនិតផ្តួចផ្តើមនៅខេត្តសៀមរាប" មានសារសំខាន់ក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាព ថ្នាក់ជាតិ និងក្នុងតំបន់ សម្រាប់ការអនុវត្តន៍គោលការណ៍ Istanbul ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍។

## ការកសាងសមត្ថភាព និងអភិបាលកិច្ចល្អ

ក្រៅពីការកើនឡើងតួនាទីសំខាន់ក្នុងកិច្ចការសាធារណៈ អង្គការសង្គមស៊ីវិល បានផ្តោតលើការកសាងសមត្ថភាពអង្គការរបស់ខ្លួន ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ (Suarez and Marshall, ២០១១)។ អង្គការសង្គមស៊ីវិល បានឆ្លើយតបតាមមធ្យោបាយមួយចំនួន រួមមានការបង្កើតការប្រតិបត្តិអភិបាលកិច្ចល្អផ្ទៃក្នុង (ធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង។ល។) និងសកម្មភាពត្រួតពិនិត្យផ្ទៃក្រៅដោយតតិយជន។ នេះអាចជាការផ្លាស់ប្តូរវិជ្ជមានមួយ ដោយសារតែការត្រួតពិនិត្យ (ទោះបីជាលក្ខណៈផ្ទៃក្នុងក៏ដោយ) ត្រូវបានគេបង្ហាញថា បានជួយបង្កើនឱកាសក្នុងការចូលរួមពីសហគមន៍ ក្នុងការរៀបចំផែនការ និងការអនុវត្តន៍គម្រោងរបស់អង្គការសង្គមស៊ីវិល (Burger and Owens ២០១០)។

ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ កម្មវិធីគំនិតផ្តួចផ្តើមនិយ័តកម្ម និងវិញ្ញាបនប័ត្រ ត្រូវបានបង្កើតឡើង ដែលបង្ហាញពីសមត្ថភាពរបស់វិស័យអង្គការសង្គមស៊ីវិល ដើម្បីជំរុញឲ្យមានអភិបាលកិច្ចល្អ និងកសាងសមត្ថភាពផ្ទៃក្នុង។ អង្គការ One World Trust បានបង្កើតទិន្នន័យដើម្បីកត់ត្រា និងតាមដានគំនិតផ្តួចផ្តើមស្វ័យនិយ័តកម្ម ជាលក្ខណៈអន្តរជាតិ (www.oneworldtrust.org)។ ក្នុងឆ្នាំ២០០៩ អង្គការនេះ បានកំណត់អត្តសញ្ញាណ និង ចាប់ផ្តើមតាមដានគំនិតផ្តួចផ្តើមចំនួន ៣០៩ នៅទូទាំងពិភពលោក ដែលច្រើនជាងការគិតទុក ពីមុនឆ្ងាយ។ ក្នុងចំណោមកម្មវិធីដែលកំណត់អត្តសញ្ញាណដោយអង្គការ One World Trust គឺ មានគំនិតផ្តួចផ្តើមចំនួនពីរ បានចាប់ផ្តើមនៅកម្ពុជា ដោយអង្គការ CCC គឺក្រមនៃ គោលការណ៍សីលធម៌ និងស្តង់ដារអប្បបរមាសម្រាប់អង្គការមិនមែនរដ្ឋាភិបាល នៅកម្ពុជា និងប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត សម្រាប់ការងារអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ នៃអង្គការមិនមែនរដ្ឋាភិបាល (NGO GPP)។ អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនៃអង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់ប្រព័ន្ធវិញ្ញាបនបត្រវាយតម្លៃមួយ (peer assessment) ដែល Warren និង Lloyd (២០០៩) ចាត់ទុកថាជាទម្រង់មួយក្នុងចំណោមទម្រង់ដ៏ខ្លាំងបំផុត នៃស្វ័យនិយ័តកម្ម។ ទោះបីជា បានចាប់ផ្តើមមិនដល់មួយទសវត្សរ៍ក៏ដោយ អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ នៃអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេស្គាល់យ៉ាងច្រើន និងត្រូវបានអនុវត្តកាន់តែច្រើន នៅក្នុងសហគមន៍អង្គការសង្គមស៊ីវិលកម្ពុជា ដោយពួកគេបានបង្ហាញនូវការប្តេជ្ញាចិត្តរយៈពេលវែង ដើម្បីអនុវត្តតាមស្តង់ដារខ្ពស់បំផុតនៃស្វ័យនិយតកម្ម និងបន្តការអភិវឌ្ឍន៍សមត្ថភាព។

# វិធីសាស្ត្រ

ការសិក្សាពីការចូលរួមចំណែក របស់អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្នាំ២០១២ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបីដំណាក់កាលដាច់ដោយឡែក ដើម្បីផ្តល់ការយល់ដឹងឲ្យបានស៊ីជម្រៅ អំពីវិស័យអង្គការសង្គមស៊ីវិលនៅកម្ពុជា ៖

១. ការធ្វើជំរឿនអង្គការសង្គមស៊ីវិលដែលចុះបញ្ជីនៅកម្ពុជា

២. ការអង្កេតបែបបរិមាណវិស័យ លើអង្គការសង្គមស៊ីវិលដែលត្រូវបានជ្រើសរើសសំណាកដោយចៃដន្យ

៣. ការអង្កេតបែបគុណវិស័យ លើទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ និងនាយកអង្គការសង្គមស៊ីវិលដែលត្រូវបានជ្រើសរើស ។

សកម្មភាពនីមួយៗទាំងនេះ តម្រូវឲ្យមានវិធីសាស្ត្រដាច់ពីគ្នា និងជូនកាលផ្សេងពីគ្នា ដើម្បីអនុវត្តសកម្មភាពនេះ ឲ្យមានប្រសិទ្ធភាព ។

## *ជំរឿនអង្គការសង្គមស៊ីវិល*

### មូលដ្ឋានទិន្នន័យជំរឿនអង្គការសង្គមស៊ីវិល

ជំរឿនអង្គការសង្គមស៊ីវិលឆ្នាំ២០១២ បានប្រើប្រាស់ទិន្នន័យដំបូងរបស់អង្គការសង្គមស៊ីវិលចំនួន ១.៩៥៦ ដែលបានចុះបញ្ជីនៅកម្ពុជា ។ បន្ទាប់ពីជំរឿនឆ្នាំ២០១១ គេសម្រេចចិត្តថា ជំរឿនឆ្នាំ២០១២ នឹងបញ្ចូលអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងសមាគមទាំងអស់ ដែលបានរាយការណ៍ដោយខ្លួនឯងថាមានសកម្មភាព ឬមិនមានសកម្មភាព (ចំនួន១.៣៨១) នៅក្នុងជំរឿនឆ្នាំ២០១១ ព្រមទាំងអង្គការអន្តរជាតិដែលមិនអាចទាក់ទងបាន(ចំនួន១៦៨)។ បន្ថែមពីនេះទៀត អង្គការសង្គមស៊ីវិល ដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ (MOI) ក្នុងឆ្នាំ២០០៣-២០០៩ (ចំនួន១០៥) ដែលមិនត្រូវបានបញ្ចូលក្នុងជំរឿនឆ្នាំ២០១១ និងបញ្ជីចុងក្រោយបង្អស់ ពីឆ្នាំ២០១១-២០១២ (ចំនួន៣៥២) ត្រូវបានបន្ថែមក្នុងជំរឿននេះ (សូមមើលតារាងទី១) ដើម្បីធ្វើបច្ចុប្បន្នភាពនូវរបកគំហើញទាំងនេះ។

ក្នុងឆ្នាំ២០១១ ជំរឿនអង្គការសង្គមស៊ីវិល មិនអាចទាក់ទងអង្គការសង្គមស៊ីវិលចំនួន ២០០៧ ពីបញ្ជីដែលផ្តល់ដោយរដ្ឋាភិបាល រួមមានអង្គការក្នុងស្រុកចំនួន ១,៨៣៩ និងអង្គការអន្តរជាតិចំនួន១៦៨។ ហេតុផលចម្បងចំពោះអត្រាឆ្លើយតបទាបនេះ គឺដោយសារការខ្វះ

ព័ត៌មានពេញលេញ ស្តីពីបញ្ជីចុះឈ្មោះអង្គការសង្គមស៊ីវិល និងការខ្វះព័ត៌មានទាក់ទងដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួច។ បញ្ជីឈ្មោះអង្គការសង្គមស៊ីវិលជាច្រើន ខ្វះព័ត៌មានទាក់ទងលម្អិត រួមទាំងលេខទូរស័ព្ទ និងអាសយដ្ឋាន។ ដោយសារតែអង្គការអន្តរជាតិ ទំនងជាមានវត្តមានទូលំទូលាយជាង អង្គការក្នុងស្រុក (ឧទាហរណ៍មានគេហទំព័រផ្លូវការ ការចុះបញ្ជីក្នុងប្រទេសផ្សេងទៀត ។ល។) ដូច្នេះអង្គការអន្តរជាតិ ដែលមិនអាចទាក់ទងបានក្នុងឆ្នាំ២០១១ តំណាងឲ្យអង្គការសង្គមស៊ីវិលមិនមានសកម្មភាព។ អង្គការអន្តរជាតិទាំងនេះ ងាយនឹងត្រូវបានគេរកឃើញបំផុត តាមរយៈការស្រាវជ្រាវបន្ថែមទៀត ហើយអង្គការទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងជំរឿនឆ្នាំ២០១២នេះ។ ទោះបីជាអង្គការអន្តរជាតិមិនអាចត្រូវបានរកឃើញទាំងអស់ក៏ដោយ ប៉ុន្តែ ព័ត៌មានទាក់ទងដែលខ្វះខាតខាងលើត្រូវបានរកឃើញ ក្នុងអង្គការអន្តរជាតិដែលមិនអាចទាក់ទងចំនួន ១៥៨ (៩៤%) នៃចំនួន១៦៨ ជាពិសេសតាមរយៈការប្រើប្រាស់ប្រភពអ៊ីនធឺណែត និងបញ្ជីឈ្មោះអង្គការសង្គមស៊ីវិល ដែលចុះបញ្ជីនៅប្រទេសផ្សេងៗទៀត។

**តារាងទី១ ទិន្នន័យដើមសម្រាប់ជំរឿនឆ្នាំ ២០១២**

| | ចំនួនអង្គការសង្គមស៊ីវិល |
|---|---|
| អង្គការសង្គមស៊ីវិលក្នុងបញ្ជីចុះឈ្មោះក្រសួងមហាផ្ទៃ 1995-2011: បញ្ជាក់ពីបើកដំណើរការ និងអសកម្មក្នុងឆ្នាំ 2011 | 1015 |
| បញ្ជីចុះឈ្មោះក្រសួងការបរទេស ឆ្នាំ1995-2012 | 494 |
| បញ្ជីចុះឈ្មោះក្រសួងមហាផ្ទៃ ឆ្នាំ 2003-2004 | 105 |
| បញ្ជីចុះឈ្មោះក្រសួងមហាផ្ទៃ 2011 | 342 |
| ចំនួនអង្គការសង្គមស៊ីវិល | **1956** |

## វគ្គបណ្តុះបណ្តាលជំរឿន និងការប្រមូលទិន្នន័យ

ការបណ្តុះបណ្តាលបុគ្គលិកជំរឿន បានធ្វើឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ដោយមានការប្រមូលទិន្នន័យ សម្រាប់ជំរឿនធ្វើចាប់ពី ខែវិច្ឆិកា ឆ្នាំ២០១២ ដល់ខែមករា ឆ្នាំ២០១៣។ យុទ្ធសាស្ត្រក្នុងការធ្វើសំណាកអង្គការសង្គមស៊ីវិលនៅក្នុងជំរឿននេះ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងជំរឿនឆ្នាំ២០១១ ដែរ។

១. ប្រសិនបើអង្គការសង្គមស៊ីវិលមានលេខទូរស័ព្ទ អ្នកប្រមូលព័ត៌មាន បានព្យាយាមហៅលេខនេះ (យ៉ាងហោចណាស់ បីដង ក្នុងពេលបីថ្ងៃផ្សេងៗគ្នា ប្រសិនបើលេខនៅដំណើរការ ប៉ុន្តែមិនមានការឆ្លើយតប) ។

២. ប្រសិនបើ មានសារអេឡិចត្រូនិច ឬគេហទំព័រ (ប៉ុន្តែពុំមាន លេខទូរស័ព្ទ) អ្នកប្រមូលព័ត៌មាន ព្យាយាមទាក់ទងអង្គការសង្គមស៊ីវិលតាមវិធីនេះ។

៣. បើពុំមានព័ត៌មានទាក់ទងផ្ទាល់ ជាដំបូង អ្នកប្រមូលព័ត៌មាន ព្យាយាមរកព័ត៌មាន ដោយប្រើប្រាស់ប្រភពផ្សេងៗ រួមមានបញ្ជីឈ្មោះអង្គការសង្គមស៊ីវិលកម្ពុជា និង បញ្ជីឈ្មោះស្ថាប័នជំនួញ ការស្រាវជ្រាវតាមគេហទំព័រ បញ្ជីឈ្មោះនៃអង្គការសង្គមស៊ីវិលពីប្រទេសផ្សេងទៀត ព្រមទាំងការសាកសួរប្រជាជនម្នាក់ៗតាមមូលដ្ឋាន និងបណ្តាញអង្គការសង្គមស៊ីវិលក្នុងស្រុក ដែលមានបទពិសោធន៍ក្នុងវិស័យនេះ។

៤. ប្រសិនបើពុំទទួលបាននូវព័ត៌មានទាក់ទង តាមរយៈវិធីទាំងនេះ អ្នកប្រមូលព័ត៌មាន ត្រូវបានបញ្ជូនទៅកាន់អាសយដ្ឋានការិយាល័យ ដែលផ្តល់ដោយអង្គការសង្គមស៊ីវិល នៅរាជធានីភ្នំពេញ នៅពេលដែលចុះបញ្ជី ឬអាសយដ្ឋានបច្ចុប្បន្ន មកពីទិន្នន័យជំរឿនឆ្នាំ២០១១ ប្រសិនបើមាន។

៥. ចំពោះអង្គការសង្គមស៊ីវិល ដែលមានការិយាល័យធំ ក្រៅពីរាជធានីភ្នំពេញ ត្រូវទាក់ទងទៅកាន់មេឃុំ ដែលអាសយដ្ឋានរបស់អង្គការសង្គមស៊ីវិល ត្រូវបានចុះបញ្ជីនៅទីនោះ និងសួរគាត់ថា តើគាត់ស្គាល់អង្គការសង្គមស៊ីវិលនេះ និងអាចផ្តល់ព័ត៌មានទាក់ទងរបស់អង្គការបានដែរឬទេ។

## ទម្រង់ជំរឿន

ទម្រង់ជំរឿនអង្គការសង្គមស៊ីវិល ត្រូវបានបង្កើតឡើង ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានទាក់ទង និងស្ថានភាពរបស់អង្គការសង្គមស៊ីវិល។ ផ្នែកស្តីពីស្ថានភាពអង្គការសង្គមស៊ីវិល ក៏បានសួរពីព័ត៌មានលម្អិតទូទៅខ្លះរបស់អង្គការសង្គមស៊ីវិល រួមមានអនុស្សរណៈយោគយល់គ្នា កិច្ចព្រមព្រៀងជាមួយនឹងអង្គការសង្គមស៊ីវិល/អង្គការនៅតាមសហគមន៍ផ្សេងទៀត និងថវិកាប្រចាំឆ្នាំ។ ទម្រង់បញ្ជីសំនួរនេះ មានពីរផ្នែក ៖

- ផ្នែកទី១ ៖ ព័ត៌មានទាក់ទងលម្អិតរបស់អង្គការសង្គមស៊ីវិល
- ផ្នែកទី២ ៖ បច្ចុប្បន្នភាពអំពីស្ថានភាពអង្គការសង្គមស៊ីវិល

ទម្រង់បញ្ជីសំនួរជំរឿនឆ្នាំ២០១២ មាននៅក្នុងឧបសម្ព័ន្ធ ទំព័រទី១០២។

## ការអង្កេតលើអង្គការសង្គមស៊ីវិល

### សំណាកនៃការអង្កេត




**រូបទី១ ទីតាំងសំណាកសម្រាប់ការអង្កេត ឆ្នាំ២០១២**

សំណាកចំនួន ៣០៦ ត្រូវបានជ្រើសរើសដោយចៃដន្យ ចេញពីទិន្នន័យបឋម នៃអង្គការសង្គមស៊ីវិលចំនួន ១.២៧៩ ដែលត្រូវបានកំណត់អត្តសញ្ញាណជាអង្គការសង្គមស៊ីវិលបើកដំណើរការ (ទទួលមូលនិធិ និងមិនទទួលមូលនិធិ) ក្នុងទិន្នន័យជំរឿនឆ្នាំ ២០១២។ ការធ្វើដូច្នេះ បានផ្តល់នូវសំណាកដែលតំណាងតាមតំបន់ និងប្រភេទអង្គការសង្គមស៊ីវិល ផ្សេងៗគ្នា (អង្គការក្នុងស្រុក សមាគម និងអង្គការអន្តរជាតិ សូមមើលតារាងទី២)។ សំណាកអង្គការសង្គមស៊ីវិល ក្នុងការសិក្សាស្រាវជ្រាវនេះ មានទីតាំងស្ថិតនៅក្នុងខេត្ត-រាជធានីចំនួន ២១ នៃខេត្ត-រាជធានីទាំង ២៤ នៅកម្ពុជា។ មិនមានអង្គការសង្គមស៊ីវិល ត្រូវបានជ្រើសរើសដោយចៃដន្យ នៅក្នុងខេត្តចំនួនបីគឺខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងកែប។ នេះទំនងដោយសារអង្គការសង្គមស៊ីវិល ប្រតិបត្តិការនៅក្នុងខេត្តទាំងបីនេះ មានចំនួនតិចតួច។ អង្គការសង្គមស៊ីវិលចំនួន

៣៥ ដែលតំណាងឲ្យ ១១,៤% នៃសំណាកដែលបានជ្រើសរើស បានបដិសេធមិនព្រមផ្តល់សម្ភាសន៍ នៅពេលពួកគេ ត្រូវបានទាក់ទងជាលើកដំបូង ដើម្បីចូលរួមក្នុងការសិក្សា ស្រាវជ្រាវនេះ។ បន្ថែមពីនេះទៀត អ្នកផ្តល់ចម្លើយចំនួនបួននាក់ បានបញ្ចប់សម្ភាសន៍ មុនពេលឆ្លើយសំណួរទាំងអស់ដោយបញ្ជាក់ថា រវល់ឬពុំមានពេលបញ្ចប់សម្ភាសន៍ដែលនៅសល់។ ការឆ្លើយតប មកពីអង្គការសង្គមស៊ីវិលចំនួន ២៧១ ត្រូវបានចងក្រង និងធ្វើវិភាគសម្រាប់របាយការណ៍នេះ រួមបញ្ចូលទាំងការឆ្លើយតប មកពីសម្ភាសន៍ពុំទាន់ចប់ទាំងបួននោះផង។ សំណាកសិក្សាស្រាវជ្រាវចុងក្រោយបានរួមបញ្ចូលអង្គការក្នុងស្រុកចំនួន១៤២ អង្គការអន្តរជាតិចំនួន៦២ និងសមាគម ក្នុងស្រុកចំនួន ៦៧។

**តារាងទី២ លទ្ធផលសំណាកសម្រាប់ការអង្កេត**

| លទ្ធផល | អង្គការក្នុងស្រុក | អង្គការអន្តរជាតិ | សមាគម | សរុប | របាយភាគរយ |
|---|---|---|---|---|---|
| សម្ភាសន៍ចប់ | 140 | 61 | 66 | 267 | 87.3 |
| សម្ភាសន៍មិនចប់ | 2 | 1 | 1 | 4 | 1.3 |
| បដិសេធ | 19 | 7 | 9 | 35 | 11.4 |
| **សរុប** | **161** | **69** | **76** | **306** | **100** |

## ការបណ្តុះបណ្តាលអំពីការធ្វើអង្កេត និងការប្រមូលទិន្នន័យ

សកម្មភាពប្រមូលទិន្នន័យ ដើម្បីធ្វើការអង្កេតលើអង្គការសង្គមស៊ីវិល ត្រូវបានធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ២០១៣។ ប្រធានក្រុមស្រាវជ្រាវ បានព្យាយាមទាក់ទងអង្គការសង្គមស៊ីវិលតាមរយៈលេខទូរស័ព្ទដែលមាននៅក្នុងទិន្នន័យជំរឿន ដើម្បីធ្វើការណាត់ជួបធ្វើសម្ភាសន៍។ម្តងម្កាល អង្គការសង្គមស៊ីវិល ស្នើឲ្យក្រុមស្រាវជ្រាវ បញ្ជូនទម្រង់សម្ភាសន៍ផ្លូវការ ទៅកាន់ពួកគេ តាមរយៈសារអេឡិចត្រូនិច។ ប្រសិនបើអាច សម្ភាសន៍ត្រូវបានធ្វើឡើង ជាមួយនឹងនាយកប្រតិបត្តិអង្គការ និងជាមួយសមាជិកនៃក្រុមគណៈគ្រប់គ្រងជាន់ខ្ពស់ បើនាយកប្រតិបត្តិអវត្តមាន។

សមាជិកក្រុមស្រាវជ្រាវបានធ្វើសម្ភាសន៍ទាំងអស់ ជាមួយអ្នកផ្តល់ចម្លើយនៃអង្គការសង្គមស៊ីវិល ។ ប្រធានក្រុមស្រាវជ្រាវ បានសម្របសម្រួលសម្ភាសន៍ទាំងនេះ ពិនិត្យផ្ទៀងផ្ទាត់តារាងសំណួរទាំងអស់ មុនពេលបញ្ចូលទិន្នន័យ និងធ្វើសម្ភាសន៍ជាភាសាអង់គ្លេស ជាមួយនាយកអង្គការសង្គមស៊ីវិលជាជនបរទេស នៅពេលដែលចាំបាច់។ ចំពោះអ្នកដែលប្រមូលទិន្នន័យនៅរាជធានីភ្នំពេញ អ្នកពិនិត្យផ្ទៀងផ្ទាត់នៃក្រុមស្រាវជ្រាវ បានពិនិត្យមើលសម្ភាសន៍

នីមួយៗដែលរួចរាល់ នៅការិយាល័យក្នុងរាជធានីភ្នំពេញ នៅចុងម៉ោងនៃថ្ងៃសម្ភាសន៍ និងចំពោះអ្នកដែលធ្វើសម្ភាសន៍នៅតាមខេត្ត ធ្វើនៅពេលចុងបញ្ចប់នៃថ្ងៃប្រមូលទិន្នន័យ។ ចំពោះបញ្ហាពាក់ព័ន្ធនឹងទិន្នន័យ អ្នកពិនិត្យផ្ទៀងផ្ទាត់ បានទាក់ទងអង្គការសង្គមស៊ីវិលតាមទូរស័ព្ទ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ចំពោះការឆ្លើយតបមិនច្បាស់លាស់។

## ឧបករណ៍នៃការអង្កេត

ការសិក្សាស្រាវជ្រាវ អំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្នាំ២០១២ បានប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យ ដែលបានកែសម្រួលចេញពីឧបករណ៍ប្រមូលទិន្នន័យឆ្នាំ២០១១។ ឧបករណ៍ឆ្នាំ២០១១នេះ បានផ្តល់ដោយអង្គការ CCC ហើយត្រូវយកមកកែសម្រួល និងតេស្តសាកល្បងជាមុនច្រើនដង ដើម្បីធានាថា ឧបករណ៍ទាំងអស់ ពោលគឺ ១/ ងាយយល់សម្រាប់អ្នកផ្តល់ចម្លើយ ២/ មិនមានការវាយប្រហារ និងការគំរាមកំហែង (ការធ្វើដូច្នេះ ទំនងជាទទួលបានចម្លើយពិតជាង) ៣/ ងាយស្រួលសម្រាប់អ្នកធ្វើសម្ភាសន៍ ធ្វើការកត់ត្រា និង៤/ មិនទទួលបាននូវទិន្នន័យដោយចៃដន្យ។

បញ្ជីសំណួរអង្កេតចែកចេញជា ១២ផ្នែក ៖

- ផ្នែកទី១ ៖ បុគ្គលិក
- ផ្នែកទី២ ៖ វិស័យការងារ
- ផ្នែកទី៣ ៖ ការសម្របសម្រួល
- ផ្នែកទី៤ ៖ អ្នកទទួលផល
- ផ្នែកទី៥ ៖ កម្មវិធីវិញ្ញាបនបត្រអង្គការមិនមែនរដ្ឋាភិបាលរបស CCC
- ផ្នែកទី៦ ៖ អភិបាលកិច្ច
- ផ្នែកទី៧ ៖ ការចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍
- ផ្នែកទី៨ ៖ ធនធាន
- ផ្នែកទី៩ ៖ ព័ត៌មានលំអិតស្តីពីគម្រោង
- ផ្នែកទី១០ ៖ ជំនួយ ឬអំណោយ
- ផ្នែកទី១១ ៖ សហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលនាពេលអនាគត
- ផ្នែកទី១២ ៖ សារតារបស់អ្នកផ្តល់ចំលើយ

បញ្ជីសំណួរសម្រាប់ធ្វើអង្កេតឆ្នាំ២០១២ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ទំព័រទី១០៤។

## ការបញ្ចូល និងការវិភាគទិន្នន័យ

ទម្រង់ជំរឿនពេញលេញ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ដែលត្រូវបានបង្កើត នៅក្នុង Microsoft Access ខណៈដែលទិន្នន័យមកពីការអង្កេត ត្រូវបានបញ្ចូលទៅក្នុងទិន្នន័យ ដែលត្រូវបានបង្កើត នៅក្នុងប្រព័ន្ធដំណើរការជំរឿន និងអង្កេត ដោយបុគ្គលិក បញ្ចូលទិន្នន័យ ដែលមានបទពិសោធន៍ចំនួនបីរូប។

ទិន្នន័យទាំងអស់ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ចំនួនពីរដង (បញ្ចូលទិន្នន័យទ្វេដង) បន្ទាប់មកផ្ទៀងផ្ទាត់ដោយអ្នកគ្រប់គ្រងទិន្នន័យ ដើម្បីត្រួតពិនិត្យមើលភាពមិនស៊ីគ្នា កំហុសអក្ខរាវិរុទ្ធ និងកំហុសផ្សេងទៀតដែលអាចប៉ះពាល់ដល់លទ្ធផលនៃការអង្កេត។

ទិន្នន័យបែបបរិមាណទាំងអស់ ត្រូវបានវិភាគ ដោយប្រើប្រាស់ STATA។ ការវិភាគនេះ ត្រូវបានធ្វើឡើង ដើម្បីត្រួតពិនិត្យលើភាពដែលអាចទុកចិត្តបានរបស់ស្ថិតិទិន្នន័យ ព្រមទាំងភាពពាក់ព័ន្ធទៅនឹងគោលបំណងរបស់គម្រោងទាំងមូល។

ដោយសារតែអ្នកផ្តល់ចម្លើយមិនអាចឆ្លើយគ្រប់សំណួរទាំងអស់ (ឧទាហរណ៍ អង្គការសង្គមស៊ីវិលដែលមិនមានបុគ្គលិកជាជនបរទេស នឹងមិនឆ្លើយសំណួរទាក់ទងនឹងបុគ្គលិកជាជនបរទេស) ទំហំសំណាកសម្រាប់សំណួរនីមួយៗ អាចខុសគ្នាពីទំហំសំណាកសរុប។ ទំហំសំណាកនេះ តាងដោយអក្សរ "n" និង មាននៅក្នុងអត្ថបទនេះ នៅពេលដែលដកស្រង់សូចនាករ ឬនៅពេលដែលទំហំសំណាក អាចមានភាពមិនច្បាស់។ អក្សរ "n" នេះមាននៅគ្រប់តារាងទាំងអស់ សម្រាប់អ្នកអាន ឲ្យយល់ពីលក្ខណៈនៃការឆ្លើយតបនោះ។

## សម្ភាសន៍បែបគុណភាព

នាយកអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ ត្រូវបានជ្រើសរើសដើម្បីចូលរួមនៅក្នុងសម្ភាសន៍បែបគុណភាព នៅដំណាក់កាលប្រមូលទិន្នន័យអង្កេត។ នាយកអង្គការសង្គមស៊ីវិលចំនួនប្រាំពីររូប ត្រូវបានជ្រើសរើសដោយចៃដន្យ ពីអ្នកផ្តល់ចម្លើយនិងដៃគូអភិវឌ្ឍន៍ចំនួនដប់រូបត្រូវបានជ្រើសរើសតាមប្រភេទនៃទីភ្នាក់ងារ (ទីភ្នាក់ងារទ្វេភាគី ទីភ្នាក់ងារពហុភាគី ទីភ្នាក់ងារអង្គការសហប្រជាជាតិ គ្រឹះស្ថានឯកជននិងទីភ្នាក់ងារទ្វេភាគីតូចៗ ។ល។) ដើម្បីទទួលបានទស្សនៈចម្រុះ។ នាយកអង្គការសង្គមស៊ីវិលចំនួនប្រាំមួយរូប និងដៃគូអភិវឌ្ឍន៍ចំនួនពីររូប ដែលយកចេញពីបញ្ជីបឋម អាចត្រូវបានសម្ភាសន៍នៅចុងបញ្ចប់នៃការធ្វើអង្កេត។ ការពិភាក្សា ត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រងការប្រមូលទិន្នន័យ ហើយក៏ជាអ្នកសម្ភាសន៍ក្នុងការអង្កេតផងដែរ។ ការសម្ភាសន៍ ត្រូវបានថតសម្លេង បន្ទាប់មកកត់ត្រាចូលក្នុង Microsoft

Word។ ទស្សនៈដែលត្រូវបានបញ្ចេញនៅក្នុងសម្ភាសន៍នេះ ត្រូវបានសង្ខេបនៅក្នុងផ្នែកលទ្ធផល និងមិនមានបំណងតំណាងឲ្យផ្នែកទាំងមូលទេ ប៉ុន្តែជាការ បញ្ចេញទស្សនៈ និងមតិរបស់នាយកអង្គការសង្គមស៊ីវិល និងដៃគូភ្នាក់ងារអភិវឌ្ឍន៍ស្តីពីបញ្ហាក្នុងផ្នែកនេះប៉ុណ្ណោះ។

បញ្ជីសំណួរស្រាវជ្រាវបែបគុណភាពឆ្នាំ២០១២ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ទំព័រទី១៣៤។

## *ដែនកំណត់/ការប្រៀបធៀបនឹងឆ្នាំ២០១១*

ដោយសារតែមានវិធីសាស្រ្តផ្សេងៗគ្នា ក្នុងការសិក្សាស្រាវជ្រាវឆ្នាំ២០១២នេះ ជាទូទៅលទ្ធផលឆ្នាំ២០១២នេះគឺពិបាកធ្វើការប្រៀបធៀបជាមួយនឹងលទ្ធផលនៃការសិក្សាឆ្នាំ២០១១។ លទ្ធផលឆ្នាំ២០១២ គួរតែជាទិដ្ឋភាពមួយបង្ហាញអំពីវិស័យអង្គការសង្គមស៊ីវិល នៅក្នុងឆ្នាំ២០១២នេះ។

ការផ្លាស់ប្តូរគួរឲ្យកត់សំគាល់បំផុតមួយ ពីការសិក្សាឆ្នាំ២០១១ គឺការវិភាគលើបរិមាណថវិកា និងអ្នកទទួលផលរបស់អង្គការសង្គមស៊ីវិល។ ខណៈដែលការអង្កេតឆ្នាំ២០១១ បានត្រួតពិនិត្យតាមប្រភេទអង្គការសង្គមស៊ីវិល ដោយដាក់អង្គការសង្គមស៊ីវិលជាក្រុម តាមលំដាប់ថវិកា និងអ្នកទទួលផល ការសិក្សាស្រាវជ្រាវឆ្នាំ២០១២ វិភាគលើទិន្នន័យដែលផ្តល់ដោយអង្គការសង្គមស៊ីវិលនីមួយៗ។ ការធ្វើដូច្នេះ ផ្តល់នូវរូបភាពច្បាស់ជាងមុន អំពីវិស័យអង្គការសង្គមស៊ីវិលទាំងមូល ព្រមទាំងមធ្យមភាគជាតំណាង និងការប៉ាន់ស្មាន ។

# លទ្ធផលជំរឿនអង្គការសង្គមស៊ីវិល

## តម្រូវការសម្រាប់ជំរឿនអង្គការសង្គមស៊ីវិល

នៅពេលនេះ ពុំទាន់មានចំនួនច្បាស់លាស់ថា តើអង្គការសង្គមស៊ីវិលប៉ុន្មាន កំពុងប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា តម្រូវឲ្យមានការចុះបញ្ជី និងការរាយការណ៍ ប៉ុន្តែការអនុវត្តន៍តិចតួចតាមតម្រូវការនេះ ហើយការតាមដានវិញក៏តិចតួចដោយរាជរដ្ឋាភិបាលវិញ។ អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវបានតម្រូវឲ្យធ្វើការចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ (អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក/សមាគម) ឬក្រសួងការបរទេស (អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ) ទោះបីជា ការចុះបញ្ជីអង្គការសង្គមស៊ីវិល តម្រូវឲ្យមានព័ត៌មានតិចតួចក៏ដោយ។ ព័ត៌មាននេះ មិនត្រូវបានផ្ទៀងផ្ទាត់ដោយរាជរដ្ឋាភិបាលទេ នៅពេល ឬក្រោយដំណើរការចុះបញ្ជី។ បញ្ជីចុះឈ្មោះអង្គការសង្គមស៊ីវិល មានជារៀងរាល់ឆ្នាំ ប៉ុន្តែក្រសួងទាំងពីរ មិនបានបញ្ចូលបញ្ជីគ្នានោះទេ ។

ក្រោយពីការចុះបញ្ជី បានបញ្ចប់ អង្គការសង្គមស៊ីវិល ត្រូវបានស្នើឲ្យរាយការណ៍ពីស្ថានភាព សកម្មភាព និងថវិការបស់ខ្លួន ទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជារៀងរាល់ឆ្នាំ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រក្សាទុកទិន្នន័យនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានរាយការណ៍ (http://cdc.khmer.biz/ngo/index.asp) ។ ទោះបីជាយ៉ាងណាអង្គការសង្គមស៊ីវិលភាគច្រើន មិនបានរាយការណ៍ឡើយ។ នៅដើមឆ្នាំ២០១៣ អង្គការសង្គមស៊ីវិលចំនួន ៦៩៧ (៤០,៤%) នៃចំនួនសរុប ១.៧២៤ នៅក្នុងទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានចុះបញ្ជីថាមានសកម្មភាព ឬបិទ រួមទាំងអង្គការសង្គមស៊ីវិលដែលបានរាយការណ៍នៅឆ្នាំ២០១២។ ចំនួនដែលនៅសល់ (៥៩,៦%) ត្រូវបានចុះបញ្ជីថាមិនបានរាយការណ៍។

ជំរឿនអង្គការ សង្គមស៊ីវិលឆ្នាំ២០១១ និង ២០១២ ដោយអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) គឺជាការខិតខំប្រឹងប្រែងលើកដំបូងក្នុងការធ្វើបច្ចុប្បន្នភាពនូវព័ត៌មានបញ្ជីឈ្មោះអង្គការសង្គមស៊ីវិល ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស ហើយជំរឿននេះ មានសារសំខាន់ក្នុងការស្វែងយល់ពីវិស័យទាំងមូល។ គេសង្ឃឹមថា តួលេខជំរឿន និងលទ្ធផលទាំងនេះ នឹងមានសារប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ និងអ្នកធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយសាធារណៈ នាពេលខាងមុខ ដើម្បីយល់ដឹងបន្ថែមទៀតពីទំហំពិតប្រាកដនៃវិស័យនេះ។

## ប្រភេទអង្គការសង្គមស៊ីវិល

ជំរឿនឆ្នាំ២០១១ ចាត់អង្គការសង្គមស៊ីវិលជាបួនប្រភេទគឺ អង្គការសង្គមស៊ីវិលមានសកម្មភាព មិនមានសកម្មភាព បិទ និងមិនអាចទាក់ទងបាន។ អង្គការសង្គមស៊ីវិលមានសកម្មភាព ត្រូវបានកំណត់និយមន័យថាជា អង្គការដែលកំពុងធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជា ហើយអង្គការសង្គមស៊ីវិលមិនមានសកម្មភាព គឺជាអង្គការដែលមិនបានធ្វើសកម្មភាពនៅកម្ពុជា នៅពេលធ្វើជំរឿននេះ។ អង្គការសង្គមស៊ីវិលបិទ គឺជាអង្គការដែលបានរាយការណ៍ជាផ្លូវការពីការបិទអង្គការរបស់ខ្លួន ទៅកាន់ក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និង/ឬ ពុំមានសកម្មភាព និងគ្មានផែនការធ្វើសកម្មភាពនាពេលអនាគត។

ជំរឿនឆ្នាំ២០១២ បានពង្រីកប្រភេទអង្គការសង្គមស៊ីវិលឆ្នាំ២០១១ ដើម្បីបញ្ជាក់ពីអត្ថន័យមិនច្បាស់លាស់ នៅក្នុងពាក្យពីមុន (សូមមើលតារាងទី៣)។ អង្គការសង្គមស៊ីវិល " បើកដំណើរការទទួលបានមូលនិធិ " គឺជាអង្គការដែលបច្ចុប្បន្ន ទទួលបានមូលនិធិ (ពីប្រភពណាមួយ) និងកំពុងអនុវត្តគម្រោង។ អង្គការសង្គមស៊ីវិល "បើកដំណើរការមិនទទួលបានមូលនិធិ" គឺជាអង្គការដែលបច្ចុប្បន្នមិនបានទទួលមូលនិធិ ប៉ុន្តែកំពុងស្វែងរកមូលនិធិ ឬរំពឹងថាទទួលបានមូលនិធិមួយចំនួន ក្នុងពេលឆាប់ៗនេះ អាចកំពុងអនុវត្តគម្រោង និងអាចរក្សាការិយាល័យ ឬអាសយដ្ឋានការងាររបស់ខ្លួន។ អង្គការសង្គមស៊ីវិល "បិទ" បានឈប់អនុវត្តសកម្មភាព មិនកំពុងទទួលមូលនិធិ និងមិនមានផែនការធ្វើសកម្មភាព ឬស្វែងរកមូលនិធិនាពេលអនាគត។ អង្គការសង្គមស៊ីវិលដែលបិទជាផ្លូវការ បានរាយការណ៍ពីការបិទរបស់ខ្លួនទៅក្រសួងពាក់ព័ន្ធ (ក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស) ហើយអង្គការសង្គមស៊ីវិលដែលបិទក្រៅផ្លូវការ មិនបានរាយការណ៍ពីការបិទរបស់ខ្លួន។ អង្គការសង្គមស៊ីវិល ដែលក្រុមជំរឿន

**តារាងទី៣ ស្ថានភាពអង្គការសង្គមស៊ីវិលឆ្នាំ២០១២ និង ឆ្នាំ ២០១១**

| ស្ថានភាពអង្គការសង្គមស៊ីវិលឆ្នាំ២០១២ | | ស្ថានភាពអង្គការសង្គមស៊ីវិលឆ្នាំ២០១១ |
|---|---|---|
| បើក | មានមូលនិធិ | សកម្ម |
| | គ្មានមូលនិធិ | អសកម្ម |
| បិទ | ផ្លូវការ | បិទ |
| | មិនផ្លូវការ | |
| រកមិនឃើញ | | មិនអាចទាក់ទង |
| បដិសេធ | | |

មិនអាចទាក់ទងបាន ត្រូវបានចុះបញ្ជីថា "មិនអាចរកឃើញ"។ អង្គការសង្គមស៊ីវិលដែលមិនអាចទាក់ទងបានទាំងនេះ មិនត្រូវបានសន្មត់ថា មិនមានសកម្មភាពឡើយ ដោយគ្រាន់តែយើងមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីទាក់ទងពួកគេដោយផ្ទាល់។ យើងសង្ឃឹមថា ជំរឿនតទៅមុខទៀត និងបន្តប្រមូលព័ត៌មាន ដោយអង្គការ CCC ដើម្បីទទួលលទ្ធផលកាន់តែប្រសើរឡើង។

## លទ្ធផលជំរឿន

ជំរឿនអង្គការសង្គមស៊ីវិលឆ្នាំ២០១២ បានចាប់ផ្តើមដោយមានបញ្ជីឈ្មោះអង្គការសង្គមស៊ីវិលចំនួន១.៩៥៦។ នៅពេលធ្វើការសម្អាតទិន្នន័យជំរឿននេះ ចំនួនស្ទួនគ្នា៥៦ ត្រូវបានរកឃើញ និងដកចេញ។ បន្ថែមពីនេះទៀត ក្នុងដំណើរការជំរឿនទាំងមូល អង្គការសង្គមស៊ីវិលថ្មីចំនួន១៨ ត្រូវបានរកឃើញ ហើយក្រោយមកទៀត អង្គការទាំងនេះ ត្រូវបានបន្ថែមចូលក្នុងទិន្នន័យនេះ។ អង្គការសង្គមស៊ីវិលទាំងនេះ មិនត្រូវបានបញ្ចូលទៅក្នុងទិន្នន័យបឋម ប៉ុន្តែ អាចជាផ្នែកមួយនៃបញ្ជីអង្គការសង្គមស៊ីវិលដែលមិនអាចទាក់ទងបាន ដែលមិនត្រូវបានបញ្ចូលតាំងពីដំបូង ទៅក្នុងជំរឿនឆ្នាំ២០១២។ អង្គការទាំងនេះត្រូវបានបញ្ចូលទៅក្នុងទិន្នន័យស្ថាពរ នៅក្នុងប្រភេទអង្គការបើកដំណើរការ។ អង្គការសង្គមស៊ីវិលចំនួនបី (អង្គការក្នុងស្រុកពីរ និងសមាគមចំនួនមួយ) បានផ្លាស់ប្តូរស្ថានភាពរបស់ខ្លួន ទៅជាអាជីវកម្ម ហើយបន្ទាប់មកត្រូវបានចាត់ទុកថាជាអង្គការសង្គមស៊ីវិល "បិទ" នៅក្នុងការវិភាគទិន្នន័យជំរឿន។ ហេតុដូច្នេះ អង្គការសង្គមស៊ីវិលសម្រាប់ជំរឿនឆ្នាំ២០១២ មានចំនួនសរុប ១.៩១៨ (តារាងទី៤)។




**រូបទី២ របាយភាគរយនៃលទ្ធផលជំរឿនអង្គការសង្គមស៊ីវិលឆ្នាំ២០១២ (n=1949)**

ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន ១.៩១៨ នៅក្នុងទិន្នន័យជំរឿនស្ថាពរ អង្គការស៊ីវិលសរុបចំនួន ១.៤០៦ (៧៣.៣%) អាចទាក់ទងបាន។ អង្គការសង្គមស៊ីវិលទាំងនេះ បានបញ្ជាក់ពីស្ថានភាព បើក ឬបិទរបស់ខ្លួន ទៅកាន់ក្រុមជំរឿនឆ្នាំ២០១២ (សូមមើលតារាងទី៤ និងរូបភាពទី២)។ នៅក្នុងក្រុមនេះ អង្គការសង្គមស៊ីវិលចំនួន ១.៣១៥ នៅក្នុងប្រទេសកម្ពុជា ត្រូវបានបញ្ជាក់ថា បើកដំណើរការ ក្នុងឆ្នាំ២០១២ ដែលតំណាងឲ្យ ៦៨,៦% នៃអង្គការសង្គមស៊ីវិល នៅក្នុងទិន្នន័យស្ថាពរឆ្នាំ២០១២។ ចំនួននេះ ប្រហាក់ប្រហែលទៅនឹងលទ្ធផលនៃជំរឿនឆ្នាំ២០១១ ដែលបញ្ជាក់ថា មានអង្គការសង្គមស៊ីវិលមានសកម្មភាព និងគ្មានសកម្មភាព ចំនួន ១.៣២៤ ដែលកំពុងមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារអង្គការសង្គមស៊ីវិលមួយចំនួន មិនអាចទាក់ទងបាន នៅតែបើក និងមានសកម្មភាព អង្គការសង្គមស៊ីវិលបន្ថែមចំនួន ១៨ ដែលត្រូវបានរកឃើញនៅពេលធ្វើជំរឿននេះ ដូច្នេះ ការកំណត់ចំនួនពិតប្រាកដនៃអង្គការសង្គមស៊ីវិលបើកដំណើរការ ដែលមានប្រតិបត្តិការនៅក្នុងប្រទេស គឺជាដំណើរការកំពុងបន្ត។

អង្គការសង្គមស៊ីវិលចំនួន ៦៧ (៣,៥%) បានបិទក្នុងឆ្នាំ២០១២ (រួមទាំងអង្គការដែលបានផ្លាស់ប្តូរទៅជាអាជីវកម្ម)។ អង្គការសង្គមស៊ីវិលចំនួន២៤ ដែលអាចទាក់ទងបាន បានបដិសេធពុំព្រមចូលរួមនៅក្នុងជំរឿន ដូច្នេះហើយ មិនអាចបញ្ជាក់ពីស្ថានភាពរបស់អង្គការទាំងនេះ។ ក្នុងចំណោមអង្គការសង្គមស៊ីវិលប្រភេទផ្សេងទៀត អង្គការក្នុងស្រុក មានអត្រាបដិសេធក្នុងជំរឿននេះខ្ពស់ជាងគេបំផុត បន្ទាប់មក គឺសមាគម និងអង្គការអន្តរជាតិ។ អង្គការក្នុងស្រុក និងអង្គការអន្តរជាតិ មានចំនួនបិទស្មើគ្នា ក្នុងឆ្នាំ២០១២ (ចំនួន២៤ សម្រាប់អង្គការទាំងពីរ សូមមើលតារាងទី៤) ប៉ុន្តែ អង្គការអន្តរជាតិមានអត្រាបិទខ្ពស់បំផុត (៥%) ដោយសារមានចំនួនតិចតួច នៅក្នុងសំណាកសរុប។

**តារាងទី៤ លទ្ធផលសំណាកជំរឿន តាមប្រភេទអង្គការសង្គមស៊ីវិល**

| | ចំនួនតាមប្រភេទ | | | | | របាយភាគរយតាមប្រភេទ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | អាជីវកម្ម | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | អាជីវកម្ម |
| បើក | **1315** | 670 | 321 | 324 | 0 | **68.6** | 69.4 | 67.4 | 68.5 | 0 |
| បិទ | **67** | 24 | 24 | 16 | 3 | **3.5** | 2.5 | 5.0 | 3.4 | 100 |
| បដិសេធ | **24** | 17 | 3 | 4 | 0 | **1.3** | 1.8 | 0.6 | 0.9 | 0 |
| អត់ឃើញ | **512** | 255 | 128 | 129 | 0 | **26.7** | 26.4 | 26.9 | 27.3 | 0 |
| **សរុប** | **1918** | **966** | **476** | **473** | **3** | **100** | **100** | **100** | **100** | **100** |
| បញ្ជូលស្ទួន (ដកចេញពីសំណាក) = 56 | | | | | | | | | | |
| អង្គការសង្គមស៊ីវិលថ្មីមិនមានក្នុងទិន្នន័យដើម (បន្ថែមក្នុងសំណាក) = 18 | | | | | | | | | | |

ទោះបីជាមានវិធានការក្នុងការធានាថា អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវបានទាក់ទង ប៉ុន្តែ ២៦,៧% នៅក្នុងជំរឿននេះ មិនអាចទាក់ទងបានទេ ។ មូលហេតុចម្បង គឺដោយសារតែ មិនមានព័ត៌មានទាក់ទងគ្រប់គ្រាន់ នៅពេលធ្វើជំរឿននេះ។

ក្នុងចំណោមអង្គការសង្គមស៊ីវិលបើកចំហចំនួន ១.៣១៥ នៅក្នុងជំរឿនឆ្នាំ២០១២នេះ អង្គការចំនួន ១.១៣០ (៨៥,៩%) ត្រូវបានផ្តល់មូលនិធិក្នុងឆ្នាំ២០១២ និងចំនួន ១៧៥ មិនទទួលបានមូលនិធិ។ អង្គការអន្តរជាតិ មានឱកាសខ្ពស់បំផុតក្នុងការទទួលបានមូលនិធិ ដោយ ៩៧,២% នៃអង្គការអន្តរជាតិបើកដំណើរការទាំងអស់ ទទួលបានមូលនិធិក្នុងឆ្នាំ២០១២។ សមាគម មានឱកាសទាបបំផុតក្នុងការទទួលបានមូលនិធិ ដោយជិតមួយភាគបួន (២៣,៨%) នៃសមាគមបើកដំណើរការគ្មានមូលនិធិ(សូមមើលរូបទី៣)។




**រូបទី៣ របាយភាគរយនៃប្រភេទអង្គការសង្គមស៊ីវិលដែលទទួលមូលនិធិ**

## អង្គការសង្គមស៊ីវិលបិទ

លទ្ធផលជំរឿនបង្ហាញថា អង្គការសង្គមស៊ីវិលចំនួន៦៧ បានបិទ នៅពេលណាមួយ ក្នុងឆ្នាំ២០១២ មុនពេលក្រុមជំរឿន បានទាក់ទងពួកគេ (រួមទាំងអង្គការសង្គមស៊ីវិលដែលផ្លាស់ប្តូរទៅជាអាជីវកម្ម (សូមមើលតារាងទី៥)។ អង្គការអន្តរជាតិ មានការបិទជាផ្លូវការច្រើនជាងគេបំផុត ដោយអង្គការអន្តរជាតិ ដែលបិទភាគច្រើន (៧៥%) បានរាយការណ៍ទៅកាន់ រាជរដ្ឋាភិបាល និងមានតែមួយភាគបីនៃអង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុក ប៉ុណ្ណោះ បានរាយការណ៍ពីការបិទរបស់ខ្លួន។

នៅពេលសួរថា តើហេតុអ្វីបានជាអង្គការសង្គមស៊ីវិលទាំងនោះ មិនបានរាយការណ៍ពីការបិទរបស់ខ្លួន អ្នកផ្ដល់ចម្លើយភាគច្រើនបាននិយាយថា អង្គការមិនមានលុយគ្រប់គ្រាន់ដើម្បីរាយការណ៍ពីការបិទនេះ ទៅកាន់រាជរដ្ឋាភិបាលទេ។ ចំណុចនេះ អាចត្រូវបានបកស្រាយតាមរបៀបផ្សេងៗគ្នា ពោលគឺ ដោយគ្មានមូលនិធិ អង្គការសង្គមស៊ីវិលទាំងនេះ អាចខ្វះបុគ្គលិកបំពេញ និងតាមដានលិខិតស្នាម ឲ្យក្រសួងផ្សេងៗ និង/ឬពួកគេ អាចមានការបារម្ភពីការចំណាយដែលអាចកើតឡើង ពាក់ព័ន្ធនឹងការរាយការណ៍ពីការផ្លាស់ប្ដូរទាំងនេះ។[1] អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុកទាំងនេះ អាចមានការព្រួយបារម្ភយ៉ាងខ្លាំង ដែលជាទូទៅ អង្គការទាំងនេះ ខ្វះការគាំទ្រផ្នែកអភិវឌ្ឍន៍ស្ថាប័ន និងផ្នែករដ្ឋបាល ពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ហេតុដូច្នេះ នាំឲ្យការបិទក្រៅផ្លូវការ មានអត្រាខ្ពស់ ក្នុងចំណោមក្រុមទាំងនេះ។ ហេតុផលផ្សេងទៀតនាំឲ្យមានការបិទអង្គការសង្គមស៊ីវិលក្រៅផ្លូវការ គឺដោយសារអង្គការទាំងនោះ កំពុងរៀបចំឯកសារពាក់ព័ន្ធសម្រាប់ក្រសួង អង្គការទាំងនោះ កំពុងរង់ចាំច្បាប់ស្ដីពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការទាំងនោះ មិនបានដឹង។[2]

ដោយផ្អែកលើការវិភាគពីហេតុផលទាំងនេះ ការកែលំអនីតិវិធី ការអប់រំបុគ្គលិកផ្នែករដ្ឋបាល និងគ្រប់គ្រងរបស់អង្គការសង្គមស៊ីវិល អំពីតម្រូវការរបស់ក្រសួង ដើម្បីធ្វើការផ្លាស់ប្ដូរព័ត៌មានលម្អិតពីស្ថានភាពរបស់អង្គការសង្គមស៊ីវិល និងការផ្សព្វផ្សាយពីការចំណាយពាក់ព័ន្ធទាំងអស់នេះ គឺជាវិធីដែលរាជរដ្ឋាភិបាល អាចធ្វើឲ្យប្រសើរឡើងយ៉ាងច្រើន នូវការរាយការណ៍របស់អង្គការសង្គមស៊ីវិល។

**តារាងទី៥ ប្រភេទអង្គការសង្គមស៊ីវិលបិទក្នុងជំរឿនឆ្នាំ២០១២**

| | ចំនួនតាមប្រភេទ | | | | | របាយភាគរយតាមប្រភេទ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | អាជីវកម្ម | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | អាជីវកម្ម |
| ផ្លូវការ | **31** | 8 | 18 | 5 | 0 | **46.3** | 33.3 | 75.0 | 31.3 | 0 |
| ក្រៅផ្លូវការ | **21** | 10 | 2 | 9 | 0 | **31.3** | 41.7 | 8.3 | 56.3 | 0 |
| អត់មាន | **15** | 6 | 4 | 2 | 3 | **22.4** | 25.0 | 16.7 | 12.5 | 100 |
| **សរុប** | **67** | **24** | **24** | **16** | **3** | **100** | **100** | **100** | **100** | **100** |

[1] គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) រាយការណ៍ថា មិនមានថ្លៃឈ្នួលផ្លូវការ សម្រាប់ការរាយការណ៍ពីការបិទអង្គការសង្គមស៊ីវិល ទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស នោះទេ ។

[2] “មិនបានដឹង” មានន័យថា អង្គការមិនដឹងពីរបៀបបិទអង្គការសង្គមស៊ីវិលផ្លូវការ (ខ្វះការយល់ដឹងពីនីតិវិធីសមរម្យ) ឬអង្គការមិនដឹងថា ហេតុអ្វីបានជាបុគ្គលិកអង្គការសង្គមស៊ីវិល មិនបានរាយការណ៍ពីការបិទនេះ ។

## ការផ្លាស់ប្តូរប្រភេទអង្គការសង្គមស៊ីវិល

ក្នុងការសិក្សាស្រាវជ្រាវឆ្នាំ២០១២នេះ ៣% (ចំនួន៣៩) នៃអង្គការសង្គមស៊ីវិលបើកដំណើរការ បានរាយការណ៍ពីការផ្លាស់ប្តូរប្រភេទអង្គការរបស់ខ្លួន (សូមមើលតារាងទី៦)។ រាល់អង្គការសង្គមស៊ីវិលចំនួនបីដែលបានផ្លាស់ប្តូរការចុះបញ្ជីរបស់ខ្លួន មានអង្គការពីរបានផ្លាស់ប្តូរពីអង្គការអន្តរជាតិ ឬសមាគម ទៅជាអង្គការក្នុងស្រុក។ នេះជារឿងគួរឲ្យចាប់អារម្មណ៍មួយ ដោយសារបំណងផ្លាស់ប្តូរទៅកាន់អង្គការក្នុងស្រុក អាចជាការផ្លាស់ប្តូរគំនិតនៅក្នុងសហគមន៍អភិវឌ្ឍន៍។ កាលពីមុន អង្គការអន្តរជាតិ ត្រូវបានយល់ឃើញថាជាដៃគូអភិវឌ្ឍន៍ ដែលមានប្រសិទ្ធភាពបំផុត (សូមមើល Hudock ២០០០ សម្រាប់ឧទាហរណ៍) ប៉ុន្តែប៉ុន្មានឆ្នាំថ្មីនេះ ម្ចាស់ជំនួយ និងអង្គការផ្តល់ជំនួយខ្លះ បានផ្លាស់ប្តូរមកចូលចិត្តទីភ្នាក់ងារដៃគូក្នុងស្រុកជាងទៅវិញ។ ការផ្តល់ជំនួយតាមរយៈអង្គការក្នុងស្រុកអាចត្រូវបានយល់ឃើញថា មានការសន្សំសំចៃជាង (ដោយសារមិនមានការចំណាយលើទីស្នាក់ការនៅបរទេស) និងមានប្រសិទ្ធភាពជាង ក្នុងការលើកកម្ពស់សមត្ថភាពបុគ្គលិកក្នុងស្រុក (ដូចដែលការសិក្សានេះ បង្ហាញថា អង្គការក្នុងស្រុកមានអត្រាបុគ្គលិកក្នុងស្រុក ខ្ពស់ជាងបុគ្គលិក បរទេស)។ ដោយសារតែមានទំនាក់ទំនងរឹងមាំជាមួយនឹងសហគមន៍ ការចូលរួមរបស់អង្គការក្នុងស្រុក អាចធ្វើឲ្យលទ្ធផលនៃគម្រោងមានភាពប្រសើរឡើង នៅកម្រិតផ្សេងៗគ្នាជាច្រើន ព្រមទាំងបង្កើនចីរភាពនៃគំនិតផ្តួចផ្តើម ក្រោយពេលគម្រោងដើម បានបញ្ចប់ (Gow & Vasant ១៩៨៣)។

**តារាងទី៦ អង្គការសង្គមស៊ីវិលដែលបានផ្លាស់ប្តូរក្នុងឆ្នាំ២០១២**

| ប្រភេទផ្លាស់ប្តូរ | 2011 ក្នុងស្រុក | 2011 អន្តរជាតិ | 2011 សមាគម | សរុប | (n=1315) ភាគរយ |
|---|---|---|---|---|---|
| ជាអង្គការក្នុងស្រុក | -- | 14 | 14 | 28 | 2.1 |
| ជាអង្គការអន្តរជាតិ | 6 | -- | 2 | 8 | 0.6 |
| ជាសមាគមន៍ | 2 | 1 | -- | 3 | 0.2 |
| ជាអាជីវកម្ម | 2 | 0 | 1 | 3 | 0.2 |

## ការបែងចែកអង្គការសង្គមស៊ីវិលតាមភូមិសាស្ត្រ

មាន៥៣,៨% នៃអង្គការសង្គមស៊ីវិលបើកដំណើរការដែលបានឆ្លើយតបទៅនឹងជំរឿននេះ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ (សូមមើលតារាងទី៧)។ មានហេតុផលជាច្រើនដោយសាររាជធានីភ្នំពេញគឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មនិងរាជរដ្ឋាភិបាល ក្នុងប្រទេសកម្ពុជា។ ៧៥,៧% នៃការិយាល័យរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ស្ថិតនៅភ្នំពេញ ដែលអាចបង្ហាញពីបំណងធ្វើការទាក់ទងជាមួយនឹងស្ថាប័នរដ្ឋធំៗ (ដូចជាក្រសួង) និងរក្សាទំនាក់ទំនងជាមួយនឹងទីស្នាក់ការកណ្តាលរបស់ខ្លួន និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិធំៗ)។ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុកភាគច្រើន ស្ថិតនៅតាមខេត្ត ហើយខេត្តដែលមានប្រជាប្រិយភាពបំផុតចំនួនបី គឺខេត្តសៀមរាប បាត់ដំបង និងកណ្តាល។ ខេត្តទាំងបីនេះ មានប្រជាជនជាង ៣,១ លាននាក់។[3] ជាការល្អដែលអង្គការសង្គមស៊ីវិលភាគច្រើន ជ្រើសរើសទីតាំងការិយាល័យរបស់ខ្លួន នៅក្នុងតំបន់ទាំងនេះ។ គេត្រូវពិចារណាពីលទ្ធផលនេះដោយប្រុងប្រយ័ត្ន ដោយសារតែលទ្ធផលនេះ ឆ្លុះបញ្ចាំងពីទីតាំងការិយាល័យចុះបញ្ជី ជាជាងទីតាំងនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ការបែងចែកសកម្មភាពអង្គការសង្គមស៊ីវិល ត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវជាងមុន នៅក្នុងរបកគំហើញនៃការអង្កេតអង្គការសង្គមស៊ីវិល ដោយសារអង្គការសង្គមស៊ីវិលត្រូវបានសួរយ៉ាងច្បាស់លាស់ ពីទីតាំងគម្រោងថ្មីបំផុតចំនួនពីរ (សូមមើលខេត្តគោលដៅក្នុងលទ្ធផលនៃការអង្កេត)។

រូបភាពទី៤ខាងក្រោម បង្ហាញពីទីតាំងនៃការិយាល័យអង្គការសង្គមស៊ីវិល ដោយមានដាក់ចំនួនអត្តសញ្ញាណគ្រួសារក្រីក្រ នៅក្នុងខេត្តនីមួយៗ តាមកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រប្រទេសកម្ពុជារបស់ក្រសួងផែនការ (IDPoor)។ ព័ត៌មានអំពីចំនួនគ្រួសារក្រីក្រ ច្រើនបំផុតទៅតិចបំផុត ត្រូវបានរៀបចំដោយអង្គការសង្គមស៊ីវិលសរុបទាំងអស់ ដែលមានមូលដ្ឋាននៅក្នុងខេត្ត។ ការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ កំពុងតែបន្ត (ជុំទី៥ នៃកម្មវិធីនេះ បច្ចុប្បន្នកំពុងតែដំណើរការ) និងព័ត៌មានសម្រាប់ខេត្តទាំងបី (ខេត្តកំពង់ចាម កំពង់ធំ និងស្ទឹងត្រែង) និងរាជធានីភ្នំពេញ ពុំទាន់មាននៅឡើយ។ សម្រាប់ការសិក្សាថ្មីពេលខាងមុខអាចបញ្ចូលចំនួនគ្រួសារក្រីក្រទៅក្នុងខេត្តទាំងនោះទៅក្នុងក្រាហ្វិក។ ទោះបីជាយ៉ាងណាក៏ដោយ ព័ត៌មាននេះមានអត្ថប្រយោជន៍ដល់ការត្រួតពិនិត្យការកំណត់គោលដៅរបស់អង្គការសង្គមស៊ីវិល។

ខេត្តបីនៃខេត្តចំនួនប្រាំដែលមានចំនួនគ្រួសារក្រីក្រខ្ពស់ជាងគេបំផុត (ខេត្តសៀមរាប បាត់ដំបង និងកណ្តាល) ក៏មានការិយាល័យអង្គការសង្គមស៊ីវិលច្រើនជាងគេបំផុតផងដែរ

[3] ជំរឿនប្រជាជនទូទៅនៃប្រទេសកម្ពុជាឆ្នាំ២០០៨។ ប្រជាជនទាំងបីខេត្តបញ្ចូលគ្នា (ខេត្តសៀមរាប បាត់ដំបង និងកំពង់ចាម) មានចំនួន ៣.១៨៦.៨៩៧នាក់ ក្នុងឆ្នាំ២០០៨ ។

ដោយបង្ហាញថា អង្គការសង្គមស៊ីវិល មានតំណាងច្រើនជាងគេ នៅក្នុងខេត្តទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ខេត្តព្រៃវែង និងតាកែវ ដែលមានចំនួនប្រជាជនក្រីក្រច្រើនជាងគេបំផុតនៅក្នុងប្រទេស មានតំណាងអង្គការសង្គមស៊ីវិលតិចជាងខេត្តតូចជាង (ទាក់ទងនឹងចំនួនប្រជាជនក្រីក្រ) ដូចជាខេត្តបន្ទាយមានជ័យ និងកំពង់ស្ពឺ។




រូបទី៤ របាយអង្គការសង្គមស៊ីវិលបើកដំណើរការតាមតំបន់ និងអត្តសញ្ញាណគ្រួសារក្រីក្រ ( n=1315 )

តារាងទី៧ របាយប្រភេទអង្គការសង្គមស៊ីវិលដែលសកម្មក្នុងតំបន់ផ្សេងៗ

| | ចំនួន | | | | របាយភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម |
| ភ្នំពេញ | **707** | 325 | 243 | 139 | **53.8** | 48.5 | 75.7 | 42.9 |
| សៀមរាប | **104** | 63 | 21 | 20 | **7.9** | 9.4 | 6.5 | 6.2 |
| បាត់ដំបង | **91** | 55 | 15 | 21 | **6.9** | 8.2 | 4.7 | 6.5 |
| កណ្ដាល | **54** | 32 | 11 | 11 | **4.1** | 4.8 | 3.4 | 3.4 |
| កំពង់ចាម | **53** | 27 | 2 | 24 | **4.0** | 4.0 | 0.6 | 7.4 |
| កំពង់ធំ | **38** | 22 | 4 | 12 | **2.9** | 3.3 | 1.3 | 3.7 |
| បន្ទាយមានជ័យ | **33** | 19 | 3 | 11 | **2.5** | 2.8 | 0.9 | 3.4 |
| កំពង់ស្ពឺ | **33** | 13 | 4 | 16 | **2.5** | 1.9 | 1.3 | 4.9 |
| កំពង់ឆ្នាំង | **28** | 15 | 2 | 11 | **2.1** | 2.2 | 0.6 | 3.4 |
| ព្រៃវែង | **22** | 17 | 1 | 4 | **1.7** | 2.5 | 0.3 | 1.2 |
| កំពត | **21** | 12 | 2 | 7 | **1.6** | 1.8 | 0.6 | 2.2 |
| ស្វាយរៀង | **19** | 10 | 2 | 7 | **1.4** | 1.5 | 0.6 | 2.2 |
| តាកែវ | **18** | 11 | 3 | 4 | **1.4** | 1.6 | 0.9 | 1.2 |
| ពោធិ៍សាត់ | **17** | 10 | 1 | 6 | **1.3** | 1.5 | 0.3 | 1.9 |
| រតនគីរី | **16** | 8 | 1 | 7 | **1.2** | 1.2 | 0.3 | 2.2 |
| ព្រះសីហនុ | **15** | 7 | 3 | 5 | **1.1** | 1.0 | 0.9 | 1.5 |
| ក្រចេះ | **10** | 7 | 0 | 3 | **0.8** | 1.0 | 0.0 | 0.9 |
| កោះកុង | **9** | 4 | 0 | 5 | **0.7** | 0.6 | 0.0 | 1.5 |
| មណ្ឌលគីរី | **7** | 2 | 1 | 4 | **0.5** | 0.3 | 0.3 | 1.2 |
| ឧត្តរមានជ័យ | **5** | 4 | 1 | 0 | **0.4** | 0.6 | 0.3 | 0.0 |
| កែប | **4** | 3 | 0 | 1 | **0.3** | 0.5 | 0.0 | 0.3 |
| ព្រះវិហារ | **4** | 2 | 0 | 2 | **0.3** | 0.3 | 0.0 | 0.6 |
| ស្ទឹងត្រែង | **4** | 2 | 1 | 1 | **0.3** | 0.3 | 0.3 | 0.3 |
| ប៉ៃលិន | **3** | 0 | 0 | 3 | **0.2** | 0.0 | 0.0 | 0.9 |
| | **1315** | **670** | **321** | **324** | **100.0** | **100** | **100** | **100** |

## ផ្នែកសកម្មភាពចម្បង

នៅក្នុងជំរឿននេះ អង្គការសង្គមស៊ីវិល ត្រូវបានសួរថា តើអង្គការបានធ្វើសកម្មភាពលើផ្នែកណាខ្លះ (រូបភាពទី៥ និងតារាងទី៨)។ ៤២% នៃអង្គការសង្គមស៊ីវិល ដែលមាន សកម្មភាព បានធ្វើការចម្បងរបស់ខ្លួន ឬសកម្មភាពផ្សេងទៀតក្នុងផ្នែក "អប់រំ និងបណ្តុះបណ្តាល" ដូចដែលបានរាយការណ៍នៅពេលធ្វើសម្ភាសន៍អង្គការសង្គមស៊ីវិល អំឡុងពេលជំរឿននេះ។ វាជារឿងសំខាន់ដែលយើងគួរដឹងថា ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងផ្នែកនេះ មានភាពទូលំទូលាយ និងអាចជាន់គ្នាជាមួយនឹងផ្នែកផ្សេងទៀត ដូចជា សុខុមាលភាព និងសិទ្ធិកុមារ សុខាភិបាល អាហារូបត្ថម្ភ និងមេរោគអេដស៍/ជំងឺអេដស៍ ឬកសិកម្ម។ ផ្នែកទាំងនេះប្រហាក់ប្រហែលនឹងផ្នែកដែលត្រូវបានកំណត់អត្តសញ្ញាណ អំឡុងពេលការសិក្សានេះ។




***រូបទី៥ សកម្មភាពតាមវិស័យរបស់អង្គការសង្គមស៊ីវិល (n=1315; ចម្លើយលើសពីមួយ)***

ក្នុងការបែងចែកអង្គការសង្គមស៊ីវិលទៅតាមប្រភេទ មានការកត់សំគាល់គួរឲ្យចាប់អារម្មណ៍ពីវត្តមានដ៏ខ្លាំងរបស់អង្គការអន្តរជាតិ នៅក្នុងផ្នែកអប់រំ និងសុខាភិបាល។ អង្គការអន្តរជាតិ ហាក់បីដូចជាមានចំនួនតិចតួច ក្នុងវិស័យកសិកម្ម ប៉ុន្តែ ផ្តោតលើបញ្ហាសុខុមាលភាព និងសិទ្ធិកុមារ ច្រើនជាងអង្គការ និងសមាគមក្នុងស្រុក។ អង្គការក្នុងស្រុក ក៏ផ្តោតយ៉ាងខ្លាំងលើការអប់រំ និងការបណ្តុះបណ្តាល ប៉ុន្តែ អង្គការទាំងនេះ មានសកម្មភាពផ្សេងៗទៀត នៅក្នុងផ្នែកទាំងមូល។ សមាគម ផ្តោតយ៉ាងខ្លាំងបំផុតលើកសិកម្ម និងសុខភាពសត្វ បន្ទាប់មកទៀត

គឺសកម្មភាពក្នុងផ្នែកអប់រំ និងសុខាភិបាល។ នេះអាចឆ្លុះបញ្ចាំងថា សមាគម មានទំនោរដាក់ការិយាល័យនៅតាមខេត្ត។ ការធ្វើដូច្នេះ ធ្វើឲ្យសមាគមអាចផ្តោតលើកង្វល់របស់ប្រជាជននៅតាមជនបទ បានកាន់តែច្រើន។

**តារាងទី៨ សកម្មភាពលំអិតតាមវិស័យផ្នែកតាមប្រភេទអង្គការសង្គមស៊ីវិល (ចម្លើយលើសពីមួយ)**

| | ចំនួន | | | | របាយភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | សរុប (n=1315) | ក្នុងស្រុក (n=670) | អន្តរជាតិ (n=321) | សមាគម (n=324) |
| អប់រំ និងបណ្តុះបណ្តាល | **549** | 312 | 161 | 76 | **41.7** | 46.6 | 50.2 | 23.5 |
| សុខភាព អាហារូបត្ថម និង អេដស៍ | **255** | 121 | 96 | 38 | **19.4** | 18.1 | 29.9 | 11.7 |
| កសិកម្មនិងសុខភាពសត្វ | **231** | 124 | 25 | 82 | **17.6** | 18.5 | 7.8 | 25.3 |
| អភិវឌ្ឍសហគមន៍ | **153** | 88 | 38 | 27 | **11.6** | 13.1 | 11.8 | 8.3 |
| សិទ្ធិនិងសុខុមាលភាពកុមារ | **148** | 79 | 51 | 18 | **11.3** | 11.8 | 15.9 | 5.6 |
| បរិស្ថាននិងធនធានធម្មជាតិ | **90** | 56 | 18 | 16 | **6.8** | 8.4 | 5.6 | 4.9 |
| បញ្ហាស្ត្រី និងយេនឌ័រ | **71** | 46 | 18 | 7 | **5.4** | 6.9 | 5.6 | 2.2 |
| ពិការភាព និងស្តាលទូភាព ពលកម្ម | **63** | 41 | 12 | 10 | **4.8** | 6.1 | 3.7 | 3.1 |
| វប្បធម៌ សិល្បៈ និង ទេសចរណ៍ | **62** | 19 | 10 | 33 | **4.7** | 2.8 | 3.1 | 10.2 |
| សន្សំ និងឥណទាន | **57** | 39 | 5 | 13 | **4.3** | 5.8 | 1.6 | 4.0 |
| អនាម័យ និងទឹក | **45** | 30 | 12 | 3 | **3.4** | 4.5 | 3.7 | 0.9 |
| ស្រាវជ្រាវ និងពិគ្រោះយោបល់ | **36** | 26 | 5 | 5 | **2.7** | 3.9 | 1.6 | 1.5 |
| សាសនា/ជំនឿ | **33** | 10 | 6 | 17 | **2.5** | 1.5 | 1.9 | 5.2 |
| សិទ្ធិមនុស្សនិងប្រជាធិបតេយ្យ | **29** | 16 | 6 | 7 | **2.2** | 2.4 | 1.9 | 2.2 |
| ពិភាក្សាលើការតស៊ូមតិ និងគោលនយោបាយ | **25** | 18 | 3 | 4 | **1.9** | 2.7 | 0.9 | 1.2 |
| មនុស្សធម៌ ជំនួយ និង បង្កាគ្រោះមហន្តរាយ | **24** | 14 | 5 | 5 | **1.8** | 2.1 | 1.6 | 1.5 |
| សមាគមនរដ្ឋាភិបាល | **8** | 0 | 0 | 8 | **0.6** | 0.0 | 0.0 | 2.5 |
| ជំនួយការច្បាប់ | **7** | 5 | 1 | 1 | **0.5** | 0.7 | 0.3 | 0.3 |
| អភិវឌ្ឍស្ថាប័ន និងអាជីវកម្ម | **6** | 3 | 0 | 3 | **0.5** | 0.4 | 0.0 | 0.9 |
| យល់ដឹងពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ | **4** | 0 | 4 | 0 | **0.3** | 0.0 | 1.2 | 0.0 |
| ផ្តល់ជំនួយដល់អង្គការ និងសមាគម | **1** | 1 | 0 | 0 | **0.1** | 0.1 | 0.0 | 0.0 |
| ផ្សេងៗ(ទូទៅ សង្គម សេវាកម្មសង្គមជាដើម) | **102** | 36 | 21 | 45 | **7.8** | 5.4 | 6.5 | 13.9 |
| អត់ចម្លើយ | **19** | 7 | 5 | 7 | **1.4** | 1.0 | 1.6 | 2.2 |
| សរុប | **2,018** | **1,091** | **502** | **425** | | | | |

## ការគាំទ្ររបស់អង្គការសង្គមស៊ីវិល ដល់អង្គការសង្គមស៊ីវិលផ្សេងទៀត

ក្នុងចំណោមអ្នកផ្តល់ចម្លើយទៅនឹងជំរឿនអង្គការសង្គមស៊ីវិលនេះ ២៨,៩% នៃអង្គការសង្គមស៊ីវិល បាននិយាយថា ពួកគេបានគាំទ្រអង្គការសង្គមស៊ីវិល អង្គការនៅតាមសហគមន៍ ឬក្រុមសហគមន៍ផ្សេងទៀត (សូមមើលរូបភាពទី៦)។ ការគាំទ្រនេះ អាចជាហិរញ្ញវត្ថុ របស់របរ ឬសម្ភារៈ ឬ ការគាំទ្រមិនមែនជាសម្ភារៈ ដូចជាផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព។ អង្គការក្នុងស្រុក បានគាំទ្រអង្គការសង្គមស៊ីវិល អង្គការនៅតាមសហគមន៍ ឬក្រុមសហគមន៍បានច្រើនបំផុត ដោយជាងមួយភាគបី (៣៤,៩%) នៃអង្គការក្នុងស្រុក ផ្តល់ជំនួយគាំទ្រដូចដែលបានរៀបរាប់ខាងលើ។ សរុបមក អង្គការក្នុងស្រុក ដែលបានឆ្លើយតបនឹងសំណួរនេះ បានគាំទ្រអង្គការសង្គមស៊ីវិលនិងក្រុមផ្សេងទៀតចំនួន ១០.៧១៨ ពោលគឺ អង្គការក្នុងស្រុកនីមួយៗ បានគាំទ្រអង្គការសង្គមស៊ីវិលជាមធ្យមចំនួន៥០។ ទោះបីជាអង្គការអន្តរជាតិដែលមានចំនួនតិចជាង បានគាំទ្រអង្គការសង្គមស៊ីវិលផ្សេងទៀតក៏ដោយ ប៉ុន្តែអង្គការនីមួយៗទាំងនេះ បានគាំទ្រអង្គការសង្គមស៊ីវិល និងក្រុមផ្សេងទៀត ជាមធ្យមចំនួន ១៤១ ដែលនេះជាមធ្យមភាគខ្ពស់បំផុតក្នុងចំណោមប្រភេទអង្គការសង្គមស៊ីវិលទាំងអស់។




**រូបទី៦ ប្រភេទអង្គការសង្គមស៊ីវិលគាំទ្រដល់អង្គការសង្គមស៊ីវិលផ្សេងទៀត អង្គការមូលដ្ឋាន និងក្រុមផ្សេងទៀត**

តារាងទី៩ ប្រភេទអង្គការសង្គមស៊ីវិល និងក្រុមដែលបានគាំទ្រ ចេញពីលទ្ធផលជំរឿន

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| សរុបអង្គការសង្គមស៊ីវិល អង្គការមូលដ្ឋាន និងក្រុមដែលបានគាំទ្រ | **59.8** | **12** | **20219** | **338** |
| ចំនួនគាំទ្រដោយអង្គការក្នុងស្រុក | 50.3 | 13 | 10718 | 213 |
| ចំនួនគាំទ្រដោយអង្គការអន្តរជាតិ | 141.2 | 5 | 7482 | 53 |
| ចំនួនគាំទ្រដោយសមាគម | 28.0 | 10 | 2019 | 72 |

## សហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល ជាមួយរដ្ឋាភិបាល

ជំរឿនឆ្នាំ២០១២នេះ ៨២,១% នៃអង្គការសង្គមស៊ីវិលបើកដំណើរការបានរាយការណ៍ថា អង្គការមានអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងជំរឿននេះ អង្គការសង្គមស៊ីវិល ត្រូវបានសួរអំពីអនុស្សរណៈយោគយល់គ្នា ជាមួយថ្នាក់ណាមួយ រួមមានក្រសួង និងមន្ទីរតាមខេត្ត។ អង្គការអន្តរជាតិ ទំនងច្បាស់ជាមានអនុស្សរណៈយោគយល់គ្នាជាមួយនឹងរាជ រដ្ឋាភិបាល ដោយជិត ៩៥% នៃអង្គការ ទាំងអស់ រាយការណ៍ថា យ៉ាងហោចណាស់មានអនុស្សរណៈយោគយល់គ្នាចំនួនមួយ (សូមមើលរូបភាពទី៧)។ បន្ទាប់មកទៀត អង្គការក្នុងស្រុកចំនួន ៨៦% មានអនុស្សរណៈយោគយល់គ្នាជាមួយរាជរដ្ឋាភិបាល យ៉ាងហោចណាស់ចំនួនមួយ។ មានតែ ៦២% នៃសមាគម បានរាយការណ៍ថា មានអនុស្សរណៈយោគយល់គ្នាជាមួយនឹងសមភាគីរាជរដ្ឋាភិបាល។ ហេតុផលនេះ មិនមែនបានមកពីទិន្នន័យជំរឿនដោយផ្ទាល់នោះទេ ប៉ុន្តែអាចដោយសារសមាគមមានលក្ខណៈតូចជាងទទួលបានមូលនិធិតិច និងមិនស្ថិតនៅរាជធានីភ្នំពេញ ដែលធ្វើឲ្យសមាគមចំណាយច្រើន និងមានការលំបាកច្រើន ក្នុងការទទួលបាននូវអនុស្សរណៈយោគយល់គ្នានេះ។




**រូបទី៧ ប្រភេទអង្គការសង្គមស៊ីវិលដែលមានចុះ MOUs ជាមួយរាជរដ្ឋាភិបាលកម្ពុជា (កំរិតណាមួយ)**

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលមានអនុស្សរណៈយោគយល់គ្នា អង្គការសង្គមស៊ីវិលជាងពាក់កណ្តាល មានអនុស្សរណៈយោគយល់គ្នាជាមួយនឹងក្រសួងមហាផ្ទៃ (MOI សូមមើលតារាងទី១០)។ បន្ទាប់ពីនេះ ក៏មានអនុស្សរណៈយោគយល់គ្នាជាច្រើនដែរ ជាមួយនឹងក្រសួងការបរទេស (MOFA)។ អង្គការ ក្នុងស្រុក/សមាគម និងអង្គការអន្តរជាតិ សំដៅឆ្ពោះទៅរកការចុះអនុស្សរណៈយោគយល់គ្នាជាមួយនឹងក្រសួងទាំងពីរនេះ ដោយសារតែក្រសួងទាំងពីរនេះ គឺជាក្រសួងដែលអង្គការទាំងនេះ ត្រូវបានតម្រូវឲ្យចុះបញ្ជីជាមួយ។ ក្នុងកិច្ចពិភាក្សាជាមួយនឹងនាយកអង្គការ CCC និងនាយកអង្គការសង្គមស៊ីវិល មានការកត់សំគាល់ឃើញថា អ្នកខ្លះមានប្រើប្រាស់ពាក្យ "ការចុះបញ្ជី" និង "អនុស្សរណៈយោគយល់គ្នា" ជំនួសគ្នា ដើម្បីពិពណ៌នាពីកិច្ចព្រមព្រៀងផ្លូវការណាមួយ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ចម្លើយចំពោះសំណួរនេះ អាចឆ្លុះបញ្ចាំងពីការភាន់ច្រឡំ ដោយសារអង្គការសង្គមស៊ីវិល អាចរាយការណ៍ពីការចុះបញ្ជីរបស់ខ្លួនថាជា អនុស្សរណៈយោគយល់គ្នា ដែលនាំឲ្យមានអត្រាខ្ពស់នៃអនុស្សរណៈយោគយល់គ្នា រវាងក្រសួងទាំងពីរ និងអង្គការមិនមែនរដ្ឋាភិបាល។ ដោយមិនបានត្រួតពិនិត្យទិន្នន័យអនុស្សរណៈយោគយល់គ្នា ពីក្រសួងទាំងនេះដោយផ្ទាល់ យើងមិនអាចដឹងថា តើអនុស្សរណៈយោគយល់គ្នាចំនួនប៉ុន្មាន ត្រូវបានរាយការណ៍ថាពុំត្រឹមត្រូវ ប៉ុន្តែអ្នកអានគួរពិចារណាពីលទ្ធភាពទាំងនេះ នៅពេលបកស្រាយទិន្នន័យនេះ។

# តារាងទី១០ អនុស្សរណៈរវាងរាជរដ្ឋាភិបាល តាមប្រភេទអង្គការសង្គមស៊ីវិល (ចម្លើយលើសពីមួយ)

| | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| ក្រសួង/មន្ទីរ/ការិយាល័យ | សរុប | ក្នុងស្រុក | អន្តរជាតិ | សមាគម | សរុប (n=1080) | ក្នុងស្រុក (n=575) | អន្តរជាតិ (n=304) | សមាគម (n=201) |
| មហាផ្ទៃ | **612** | 460 | 27 | 125 | **56.7** | 80.0 | 8.9 | 62.2 |
| ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | **261** | 10 | 249 | 2 | **24.2** | 1.7 | 81.9 | 1.0 |
| សង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា | **172** | 73 | 79 | 20 | **15.9** | 12.7 | 26.0 | 10.0 |
| អប់រំ យុវជន និងកីឡា | **143** | 49 | 79 | 15 | **13.2** | 8.5 | 26.0 | 7.5 |
| សុខាភិបាល | **142** | 62 | 62 | 18 | **13.1** | 10.8 | 20.4 | 9.0 |
| កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | **56** | 28 | 17 | 11 | **5.2** | 4.9 | 5.6 | 5.5 |
| អភិវឌ្ឍជនបទ | **41** | 17 | 22 | 2 | **3.8** | 3.0 | 7.2 | 1.0 |
| ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | **35** | 14 | 14 | 7 | **3.2** | 2.4 | 4.6 | 3.5 |
| ធម្មការ និងសាសនា | **28** | 8 | 6 | 14 | **2.6** | 1.4 | 2.0 | 7.0 |
| កិច្ចការនារី | **18** | 7 | 10 | 1 | **1.7** | 1.2 | 3.3 | 0.5 |
| វប្បធម៌និងវិចិត្រសិល្បៈ | **14** | 2 | 4 | 8 | **1.3** | 0.3 | 1.3 | 4.0 |
| បរិស្ថាន | **14** | 5 | 6 | 3 | **1.3** | 0.9 | 2.0 | 1.5 |
| ទេសចរ | **11** | 0 | 2 | 9 | **1.0** | 0.0 | 0.7 | 4.5 |
| ព័ត៌មាន | **10** | 7 | 0 | 3 | **0.9** | 1.2 | 0.0 | 1.5 |
| ការិយាល័យទីស្តីការគណរដ្ឋមន្ត្រី | **8** | 4 | 1 | 3 | **0.7** | 0.7 | 0.3 | 1.5 |
| ពាណិជ្ជកម្ម | **8** | 2 | 0 | 6 | **0.7** | 0.3 | 0.0 | 3.0 |
| ឧស្សាហកម្មរ៉ែ និងថាមពល | **7** | 1 | 3 | 3 | **0.6** | 0.2 | 1.0 | 1.5 |
| ធនធានទឹកនិងឧតុនិយម | **6** | 5 | 0 | 1 | **0.6** | 0.9 | 0.0 | 0.5 |
| រៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | **2** | 2 | 0 | 0 | **0.2** | 0.3 | 0.0 | 0.0 |
| ការពារជាតិ | **2** | 0 | 2 | 0 | **0.2** | 0.0 | 0.7 | 0.0 |
| ទំនាក់ទំនងសភា...និងអធិការកិច្ច | **2** | 0 | 0 | 2 | **0.2** | 0.0 | 0.0 | 1.0 |
| សាធារណៈការនិងដឹកជញ្ជូន | **2** | 0 | 1 | 1 | **0.2** | 0.0 | 0.3 | 0.5 |
| សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | **1** | 1 | 0 | 0 | **0.1** | 0.2 | 0.0 | 0.0 |
| យុត្តិធម៌ | **1** | 0 | 1 | 0 | **0.1** | 0.0 | 0.3 | 0.0 |
| គ្មានចម្លើយ | **34** | 13 | 14 | 7 | **3.1** | 2.3 | 4.6 | 3.5 |
| **សរុប** | **1630** | **770** | **599** | **261** | | | | |

បន្ទាប់ពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស មានអនុស្សរណៈយោគយល់គ្នា ជាញឹកញាប់ជាមួយនឹងក្រសួង/មន្ទីរខេត្ត[4] ដែលជាទូទៅស៊ីគ្នានឹងផ្នែកសកម្មភាពចម្បង ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងជំរឿន និងការអង្កេត (សូមមើលផ្នែកសកម្មភាពចម្បង)។ ក្រសួង/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSAVY) ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) ក្រសួងសុខាភិបាល (MOH) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងធម្មការ និងសាសនា គឺជាក្រសួងទាំងប្រាំពីរដែលមានការចុះអនុស្សរណៈយោគយល់គ្នាច្រើនបំផុត បន្ទាប់ ពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស។

## ការប្រៀបធៀបភេទនៃនាយកអង្គការសង្គមស៊ីវិល

ក្នុងចំណោមអង្គការសង្គមស៊ីវិល តួនាទីប្រធានអង្គការនៅតែភាគច្រើនជាបុរស មាន ៧៦% នៃអង្គការសង្គមស៊ីវិលបើកដំណើរការទាំងអស់មាននាយកជាបុរស(សូមមើលរូបទី៨)។ ថ្នាក់ដឹកនាំអង្គការអន្តរជាតិ មានផលធៀបភេទដែលមានតុល្យភាពជាង ដោយ២៧% នៃនាយកអង្គការអន្តរជាតិ គឺជាស្ត្រី។ សមាគម ជាពិសេសសមាគមដែលជាទូទៅធ្វើការក្នុងវិស័យកសិកម្ម មានសមាមាត្រខ្ពស់បំផុតនៃនាយកជាបុរស។




**រូបទី៨ របាយយេនឌ័រនៃថ្នាក់ដឹកនាំតាមប្រភេទអង្គការសង្គមស៊ីវិល**

[4] ចូរកត់សំគាល់ថា ប្រភេទនៅក្នុងផ្នែកនេះ សំដៅទៅលើអនុស្សរណៈយោគយល់គ្នាជាមួយនឹងនាយកដ្ឋានថ្នាក់ជាតិ និងមន្ទីរថ្នាក់ខេត្ត នៃក្រសួងនីមួយៗ ។

## មូលនិធិអង្គការសង្គមស៊ីវិល ឆ្នាំ២០១២

តារាងទី១១ខាងក្រោម បង្ហាញពីព័ត៌មានលំអិតនៃថវិការបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា ដូចដែលបានរាយការណ៍ដោយអង្គការសង្គមស៊ីវិល នៅពេលធ្វើជំរឿននេះ។ ថវិកាជាមេដ្យានសម្រាប់អង្គការទាំងអស់នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១២ គឺ ៣០.០០០ ដុល្លារអាមេរិក។ អង្គការអន្តរជាតិ មានថវិកាខ្ពស់បំផុត ដោយតម្លៃជាមេដ្យានមានចំនួន ២០០.០០០ ដុល្លារអាមេរិក និងសមាគមមានថវិកាតិចជាងគេបំផុត ដោយមានតែ ៥.០០០ ដុល្លារអាមេរិក។ ចំនួនថវិកាជាមធ្យមនៅក្នុងជំរឿននេះ មានភាពខុសគ្នា យ៉ាងច្រើន ពីចំនួនថវិកាក្នុងការអង្កេតនេះ។ ទោះបីជាយ៉ាងណាក៏ដោយ អត្រាខ្ពស់ នៃការបដិសេធឆ្លើយសំណួរនេះ នៅក្នុងជំរឿន (ការបដិសេធមានចំនួន៤៧%) និងការសាកសួរសំណួរ ដែលជាចម្បងធ្វើតាមទូរស័ព្ទអាចធ្វើឲ្យព័ត៌មាននេះមានការលម្អៀង។ ដោយសារ ហេតុផល ទាំងនេះហើយ យើងយល់ថា វាជាការប្រសើរជាង ក្នុងការវិភាគចំនួនថវិកាចេញពីការសិក្សា ស្រាវជ្រាវនេះ (សូមមើលទំព័រទី៦០) ដែលត្រូវបានធ្វើឡើង ដោយជួបមនុស្ស ដោយផ្ទាល់មក ពីសំណាកចៃដន្យនៃអង្គការសង្គមស៊ីវិល ហើយការធ្វើដូច្នេះ មានអត្រាបដិសេធទាបជាង (ការបដិសេធមានចំនួន២៦,២%)។

**តារាងទី១១ មូលនិធិលំអិតក្នុងឆ្នាំ២០១២ (ជាដុល្លារ) តាមប្រភេទអង្គការសង្គមស៊ីវិល**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| ក្នុងស្រុក | 229,366 | 36,000 | 98,200,000 | 428 |
| អន្តរជាតិ | 732,464 | 200,000 | 71,800,000 | 98 |
| សមាគម | 256,702 | 5,000 | 53,700,000 | 209 |
| **សរុប** | **304,219** | **30,000** | **224,000,000** | **735** |

## *សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា*

ជំរឿនអង្គការសង្គមស៊ីវិល ដែលត្រូវបានផ្តួចផ្តើមដោយអង្គការ CCC ក្នុងឆ្នាំ២០១១ និងបានបន្តរហូតដល់ឆ្នាំ២០១២ គឺជាគំរូថ្មីមួយនៃស្វ័យអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៅក្នុងអង្គការ។ បន្ថែមពីនេះទៀត ជំរឿននេះ បង្ហាញពីរបៀបដែលអង្គការ និងរាជរដ្ឋាភិបាលកម្ពុជា អាចបំពេញការខ្វះខាតឲ្យគ្នា និងសហការគ្នា ដើម្បីសម្រេចនូវគោលដៅដូចគ្នា។ ក្នុងករណីនេះ អាចរក្សាបានស្ថានភាព និងព័ត៌មានទាក់ទង របស់អង្គការសង្គមស៊ីវិលបានចុះបញ្ជីដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

អំឡុងពេលដំណើរការជំរឿនឆ្នាំ២០១២នេះ អង្គការសង្គមស៊ីវិលចំនួនបួនដែលត្រូវបានចុះបញ្ជីនៅក្នុងទិន្នន័យ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាថា "មិនបានរាយការណ៍" ត្រូវបានកំណត់ អត្តសញ្ញាណ ដោយអង្គការ CCC ថាមិនបានបំពេញតាមស្តង់ដារសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសនេះ។ ឥឡូវនេះ អង្គការ CCC បានកំណត់បញ្ហាទាំងនេះ ហើយកំពុងធ្វើការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកែតម្រូវបញ្ហាទាំងនេះ។ បន្ថែមពីនេះទៀត អង្គការ CCC កំពុងធ្វើការបង្កើត គោលនយោបាយ សម្រាប់ដោះស្រាយការប្តឹងតវ៉ាអំពីការប្រព្រឹត្តអសីលធម៌ឬមិនសមរម្យដោយអង្គការសង្គមស៊ីវិលដែល គោលនយោបាយទាំងនេះ អាចប្រើប្រាស់នៅក្នុងរចនាសម្ព័ន្ធស្វ័យអភិបាលកិច្ច។

# បុគ្គលិក

ផ្នែកនេះ យើងបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវ អំពីការរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ ទាក់ទងនឹងស្ថានភាពបុគ្គលិក។ ទោះបីការបម្រើងារក្នុងវិស័យអង្គការសង្គមស៊ីវិល មានអត្ថប្រយោជន៍ដោយប្រយោលដល់ប្រទេសក៏ដោយ ប៉ុន្តែការងារនេះ អាចមានឥទ្ធិពលគួរឲ្យកត់សម្គាល់សម្រាប់ប្រជាជន និងសេដ្ឋកិច្ច។ ធ្វើការងារជាមួយអង្គការសង្គមស៊ីវិល អាចផ្តល់ឲ្យបុគ្គលម្នាក់ៗ នូវឱកាសមានតម្លៃ និងបទពិសោធន៍ផ្នែកបច្ចេកទេស តាមវិស័យរៀងៗខ្លួន ព្រមទាំងមានបទពិសោធន៍ជាមួយមនុស្សមានប្រវត្តិការងារ និងវប្បធម៌ចម្រុះ ដែលរួមមានជនពិការ និងជនជាតិភាគតិច។ អង្គការសង្គមស៊ីវិល ផ្តល់ឲ្យនិយោជិតនូវឱកាសក្នុងការជួយដល់ការអភិវឌ្ឍន៍ប្រទេស ហើយទន្ទឹមគ្នានេះ និយោជិតទទួលបាននូវបៀវត្សន៍ដែលមានភាពប្រកួតប្រជែង និងបទពិសោធន៍ការងារមានតម្លៃ។ បុគ្គលិករបស់អង្គការសង្គមស៊ីវិល ទទួលបាននូវការគោរពខ្លាំងក្នុងសង្គមកម្ពុជា ហើយមនុស្សជាច្រើន ស្វែងរកឱកាសការងារនេះ។

វាមានភាពលំបាកក្នុងការប្រៀបធៀបចំនួនបុគ្គលិកដែលបំពេញការងារ ជាមួយអង្គការសង្គមស៊ីវិល ជាមួយប្រភពឯកសារដទៃទៀត ដូចជាការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ដោយសារតែមិនមានជម្រើស ក្នុងការជ្រើសរើសអង្គការសង្គមស៊ីវិល ជានិយោជកនោះទេ។ ជំនួសមកវិញ បុគ្គលិកអង្គការសង្គមស៊ីវិល ទំនងជាត្រូវបានកំណត់អត្តសញ្ញាណ ក្នុងការធ្វើអង្កេតដទៃទៀត ដោយផ្អែកលើមុខតំណែងរបស់ពួកគេ (គណនេយ្យករ អ្នកគ្រប់គ្រង វិស្វករ ។ល។) ឬដោយផ្អែកលើវិស័យ (គមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន ។ល។) ។

ដើម្បីឲ្យស្របគ្នាជាមួយការអង្កេត ឆ្នាំ២០១១ យើងបានសួរសំណួរជាច្រើនអំពីបុគ្គលិកអង្គការសង្គមស៊ីវិល ដើម្បីស្វែងរកការរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការផ្តល់ការងារក្នុងប្រទេសកម្ពុជា។ យើងក៏បានសួរលម្អិតផងដែរ អំពីចំនួនបុរស/ស្ត្រីនៃបុគ្គលិកអង្គការសង្គមស៊ីវិល ចំនួនបុគ្គលិកខ្មែរ និងបរទេស និងចំនួនជនពិការ ដែលធ្វើការជាមួយអង្គការ។ ការប្រើប្រាស់សំណាកចៃដន្យ តាងឲ្យអង្គការសង្គមស៊ីវិលទាំងអស់ដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា អាចឲ្យយើងទាញលទ្ធផលចេញមកពីសំណាកនេះ ដើម្បីបង្កើតនូវការប៉ាន់ប្រមាណគួរឲ្យទុកចិត្តបាន អំពីចំនួនបុគ្គលិកសរុបតាមផ្នែកនីមួយៗ ដែលកំពុងបំពេញការងារក្នុងផ្នែកទាំងនេះ។

ការសិក្សាអង្កេតអង្គការសង្គមស៊ីវិលឆ្នាំ២០១២នេះ បានសម្ភាសន៍អង្គការ ចំនួន៣០៦ ដែលត្រូវបានជ្រើសរើសសំណាកដោយចៃដន្យ ចេញពីទិន្នន័យជំរឿន និងទិន្នន័យដែលប្រមូលបានពីសម្ភាសន៍ចំនួន ៨៨,៦% (២៧១អង្គការសង្គមស៊ីវិល) ។

## បុគ្គលិកសរុប

តារាងខាងក្រោមនេះ បង្ហាញពីចំនួនបុគ្គលិកសរុប ដែលត្រូវបានរាយការណ៍ដោយចេញពីសំណាកអង្គការដែលបានឆ្លើយតប ចំនួន២៦៤ បានជួលបុគ្គលិកចំនួន៨.៧៩៤នាក់ ក្នុងខែធ្នូ ឆ្នាំ២០១២ ដែលរួមមានបុគ្គលិកទទួលបានបៀវត្សរ៍ ចំនួន៤.៩១៣នាក់ (ពេញម៉ោង និងក្រៅម៉ោង ២៤៩ អង្គការ) និងបុគ្គលិកមិនទទួលបានបៀវត្សរ៍ចំនួន៣.៨៨១នាក់ (អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការងារ ១៧៨អង្គការ)។ អង្គការចំនួនប្រាំពីរ បានរាយការណ៍ថា ពួកគេមិនមានបុគ្គលិក និងអង្គការចំនួន២២ បានរាយការណ៍ថា ពួកគេមានតែបុគ្គលិកមិនទទួលបានបៀវត្សរ៍។ អង្គការអន្តរជាតិទាំងអស់ យ៉ាងហោចណាស់មានបុគ្គលិកពេញម៉ោងម្នាក់ ប៉ុន្តែសមាគមចំនួន២០% បានរាយការណ៍ថា មិនមានបុគ្គលិកពេញម៉ោងក្នុងឆ្នាំ២០១២ឡើយ ។

ដូច្នេះ ចំនួនបុគ្គលិកគិតជាមធ្យម ដែលធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១២ (២៧១ អង្គការ) គឺ ៣២,៥ នាក់ ដែលរួមមានអ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការងារ ហើយចំនួនបុគ្គលិកទទួលបានបៀវត្សរ៍គិតជាមធ្យម គឺ ១៨,១ នាក់ ក្នុងមួយអង្គការ។ ប្រសិនបើ យើងប៉ាន់ប្រមាណអង្គការសង្គមស៊ីវិលបើកដំណើរការក្នុងប្រទេសកម្ពុជា យើងឃើញថា ពួកគេមានបុគ្គលិកសរុបប្រហែល ៤៣.០០០នាក់ (បុគ្គលិកទទួលបានបៀវត្សរ៍និងមិនទទួលបានបៀវត្សរ៍) ក្នុងឆ្នាំ២០១២ ហើយបុគ្គលិកទទួលបានបៀវត្សរ៍ មានចំនួនប្រហែល ២៤.០០០ នាក់។

**តារាងទី១២ បុគ្គលិកសរុបនៃអង្គការសង្គមស៊ីវិលទាំងទទួល និងមិនទទួលបៀវត្សរ៍**

| | សរុបបុគ្គលិក | ពេញម៉ោង | ក្រៅម៉ោង | ស្ម័គ្រចិត្ត | ហាត់ការ |
|---|---|---|---|---|---|
| **សរុប** | **8,794** | **4,267** | **646** | **2,863** | **1,018** |
| ក្នុងស្រុក | **4,508** | 2,106 | 367 | 1,570 | 465 |
| អន្តរជាតិ | **2,428** | 1,641 | 115 | 448 | 224 |
| សមាគម | **1,858** | 520 | 164 | 845 | 329 |

ចំនួនបុគ្គលិកអង្គការសង្គមស៊ីវិល មានភាពខុសគ្នាយ៉ាងច្រើន ពីការសិក្សាស្រាវជ្រាវ ឆ្នាំ២០១១ (៥៥.០០០នាក់ ក្នុងឆ្នាំ២០១១ និង ៤៣.០០០នាក់ ក្នុងឆ្នាំ២០១២) ភាគច្រើនគឺ ដោយសារការផ្លាស់ប្តូរពាក់ព័ន្ធនឹងរបៀបដែលអង្គការសង្គមស៊ីវិលត្រូវបានជ្រើសរើស សម្រាប់ ការអង្កេតនេះ។ សំណាកអង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១១ ត្រូវបានជ្រើសរើសចេញតែពី ទីក្រុង និងខេត្តធំៗក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ភាពលម្អៀងនេះ គឺទំនងជានាំឲ្យមាន ការ ជ្រើសរើសសំណាកលើស ចេញពីអង្គការសង្គមស៊ីវិលធំៗ និងមានមូលនិធិច្រើន ដែល អង្គការ ទាំងនេះ មានបុគ្គលិកច្រើន ដូច្នេះ នាំឲ្យមានការកើនឡើងនូវតួលេខសរុបផងដែរ។ ការអង្កេត ឆ្នាំ២០១២នេះ បានប្រើប្រាស់សំណាកចៃដន្យចេញពីអង្គការសង្គមស៊ីវិលទូទាំងប្រទេស ដូច្នេះ ធ្វើការពិចារណា លើអង្គការសង្គមស៊ីវិលទាំងធំ និងតូចដោយស្មើគ្នា និងផ្តល់នូវការប៉ាន់ ប្រមាណដែលកាន់តែគួរឲ្យទុកចិត្ត។

## បុគ្គលិកប្រុស និងស្រីដែលទទួលបានបៀវត្សរ៍

ក្នុងចំណោមបុគ្គលិកទទួលបានបៀវត្សរ៍ចំនួន៤.៩១៣នាក់ ដែលត្រូវបានរាយការណ៍ ក្នុងការអង្កេតនេះ សមាមាត្រប្រុស-ស្ត្រី គឺប្រុស ៥៨% និងស្ត្រី៤២%។ តួលេខនេះ បង្ហាញថា អង្គការសង្គមស៊ីវិល មានចំនួនបុគ្គលិកស្ត្រីគួរឲ្យកត់សម្គាល់។ អង្គការអន្តរជាតិ មានបំណងឲ្យ មានសមាមាត្របុគ្គលិកស្ត្រីខ្ពស់ជាងប្រភេទអង្គការសង្គមស៊ីវិលដទៃទៀតខណៈដែលសមាគម មានសមាមាត្របុគ្គលិកបុរសខ្ពស់ជាង (សូមមើលរូបទី៩ខាងក្រោម) ។

**តារាងទី១៣ ចំនួនបុគ្គលិកដែលទទួលបានបៀវត្សរ៍ ទៅតាមភេទ**

| | សរុបបុគ្គលិក | បុរស | ស្ត្រី | n | % បុរស | % ស្ត្រី |
|---|---|---|---|---|---|---|
| **សរុបបុគ្គលិកមានបៀវត្សរ៍** | **4913** | **2851** | **2062** | **249** | **58.0** | **42.0** |
| បុគ្គលិកពេញម៉ោង | 4267 | 2496 | 1771 | 245 | 58.5 | 41.5 |
| បុគ្គលិកក្រៅម៉ោង | 646 | 355 | 291 | 103 | 55.0 | 45.0 |




**រូបទី៩ របាយភាគរយអង្គការសង្គមស៊ីវិលដែលទទួលបៀវត្សរ៍ តាមភេទ**

## បុគ្គលិកខ្មែរ និងបរទេស

សម្រាប់ចំនួនបុគ្គលិកខ្មែរ និងបរទេស មានការិះគន់រួមមួយ អំពីជំនួយ និងកម្មវិធីអភិវឌ្ឍន៍ជាអន្តរជាតិ គឺថាកម្មវិធីអង្គការសង្គមស៊ីវិល មានចំនួនបុគ្គលិកបរទេសខ្ពស់ ជាពិសេស ក្នុងមុខតំណែងគ្រប់គ្រង និងការអភិវឌ្ឍន៍យុទ្ធសាស្ត្រ។ ទោះបីការសិក្សាស្រាវជ្រាវនេះ មិនបានធ្វើការបែងចែកដាច់ពីគ្នា តាមមុខតំណែងរបស់បុគ្គលិកក្នុងអង្គការក៏ដោយ (គឺបានធ្វើការបែងចែកតែបុគ្គលិកបរទេសទទួលបាន និងមិនទទួលបានបៀវត្សរ៍) ប៉ុន្តែ រូបទី១០ ខាងក្រោមនេះបង្ហាញថា មានអ្នកផ្តល់ចម្លើយតែ ២៨,៨% ប៉ុណ្ណោះ (៧៨នាក់) បានរាយការណ៍ថា ពួកគេបានជួលបុគ្គលិកបរទេសឲ្យបម្រើការងារ។ តួលេខនេះ បង្ហាញថា អង្គការ ដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា មានចំនួនបុគ្គលិកបរទេសតិចតួចប៉ុណ្ណោះ ។




**រូបទី១០ របាយភាគរយតាមប្រភេទអង្គការសង្គមស៊ីវិលដែលមានបុគ្គលិកជាបរទេស**

ក្នុងចំណោមអ្នកផ្តល់ចម្លើយនៃអង្គការអន្តរជាតិ ក្នុងការអង្កេតនេះ មាន ៧២,៦% ជួលបុគ្គលិកបរទេសឲ្យបម្រើការងារ គិតជាមធ្យម ជិត៤នាក់ (៣,៨នាក់) ក្នុងមួយអង្គការ (សូមមើលតារាងទី១៤) ប្រៀបធៀបជាបុគ្គលិកបរទេស ជាមធ្យម ពីរនាក់ក្នុងមួយអង្គការ សម្រាប់អង្គការក្នុងស្រុក ២០%។ ចំនួនបុគ្គលិកបរទេសស្ម័គ្រចិត្ត មានចំនួនលើសបុគ្គលិកបរទេសទទួលបានបៀវត្សរ៍យ៉ាងច្រើន។ ភាគច្រើននៃបុគ្គលិកបរទេសស្ម័គ្រចិត្តទាំងនេះ ធ្វើការជាមួយអង្គការក្នុងស្រុក ។

ជាមួយនឹងកំណើនភ្ញៀវទេសចរដែលមកទស្សនា ប្រទេសកម្ពុជាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ក៏អាចនឹងមានការកើនឡើងផងដែរ នូវចំនួនអ្នកស្ម័គ្រចិត្តបរទេសដែលធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។ ការអង្កេតឆ្នាំ២០១១ បានរាយការណ៍ថា មានអ្នកស្ម័គ្រចិត្តអន្តរជាតិសរុបចំនួន ៧៧៥ នាក់ ដែលចំនួននេះតិចជាងពាក់កណ្តាលនៃចំនួនសរុប ក្នុងការអង្កេតឆ្នាំ២០១២នេះ។ បុគ្គលិកស្ម័គ្រចិត្តបរទេស អាចនឹងធ្វើការជាមួយអង្គការសង្គមស៊ីវិលតែរយៈពេលពីរបីម៉ោងប៉ុណ្ណោះ ឬរយៈពេលជាច្រើនឆ្នាំ។ កត្តានេះ ធ្វើឲ្យការវិភាគអំពីចំនួនសរុបបុគ្គលិកស្ម័គ្រចិត្តបរទេសទាំងនេះ ព្រមទាំងឥទ្ធិពលពិតប្រាកដរបស់ពួកគេ មានការលំបាក។ បុគ្គលិកស្ម័គ្រចិត្តបរទេស ធ្វើការជាមួយអង្គការសង្គមស៊ីវិល ដោយសារមូលហេតុផ្សេងៗមួយចំនួនដូចជា បង្កើនសមត្ថភាពបុគ្គលិកក្នុងស្រុក ធ្វើឬចាត់ចែងការងាររយៈពេលខ្លី ផ្តល់ជំនាញឯកទេសក្នុងវិស័យដែលត្រូវការជំនាញឯកទេសខ្ពស់ ដូចជាឱសថ និងការដោះមីន ព្រមទាំងមូលហេតុដទៃទៀតជាច្រើន ។

តារាងទី១៣ បុគ្គលិកជាជនបរទេសតាមប្រភេទអង្គការសង្គមស៊ីវិល

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| **បុគ្គលិកបរទេសមានបៀវត្សរ៍** | **2.9** | **2** | **227** | **77** |
| ក្នុងស្រុក | 1.6 | 2 | 46 | 28 |
| អន្តរជាតិ | 3.8 | 3 | 169 | 45 |
| សមាគម | 3.0 | 3 | 12 | 4 |
| **អ្នកស្ម័គ្រចិត្តបរទេស** | **21.2** | **2** | **1716** | **81** |
| ក្នុងស្រុក | 22.6 | 2 | 1018 | 45 |
| អន្តរជាតិ | 17.6 | 4 | 387 | 22 |
| សមាគម | 22.2 | 2 | 311 | 14 |

## បុគ្គលិកពិការ

បន្ទាប់មកទៀត យើងបានសួរអង្គការសង្គមស៊ីវិលថាតើ ពួកគេបានជួលបុគ្គលិកពិការដែរឬទេ។ ទោះបីប្រទេសកម្ពុជា មានច្បាប់ទាក់ទងនឹងការជួលជនពិការ និងការកម្រិតការរើសអើងចំពោះជនពិការក៏ដោយ ប៉ុន្តែអង្គការជាច្រើន មិនបានជួលជនពិការ ដោយសារហេតុផលផ្សេងៗជាច្រើន។ ក្នុងរូបទី១១ខាងក្រោមនេះ ១៧,៣% (៤៧ អង្គការសង្គមស៊ីវិល) នៃសំណាកអង្គការសង្គមស៊ីវិល បានរាយការណ៍ថា ពួកគេបានជួលជនពិការឲ្យបម្រើការ។




រូបទី១១ របាយភាគរយតាមប្រភេទអង្គការសង្គមស៊ីវិលដែលមានបុគ្គលិកជាជនពិការ

លទ្ធផលនៃការអង្កេតបង្ហាញថា អង្គការសង្គមស៊ីវិល ជួលបុគ្គលិកទទួល បានបៀវត្សរ៍ជាជនពិការយ៉ាងច្រើន ដែលមានចំនួន ៣,២% ក្នុងចំណោមបុគ្គលិកទទួលបានបៀវត្សរ៍សរុប។ ២៦%នៃអង្គការអន្តរជាតិ បានជួលបុគ្គលិកជាជនពិការ ប៉ុន្តែ អង្គការក្នុងស្រុក ច្រើនជាង (២២ អង្គការ) បានជួលបុគ្គលិកជាជនពិការ (សូមមើលតារាងទី១៥)។

ប្រសិនបើយើងប៉ាន់ប្រមាណអង្គការសង្គមស៊ីវិល ដែលមានសកម្មភាពទាំងអស់ក្នុងប្រទេសកម្ពុជា អង្គការសង្គមស៊ីវិល បានជួលបុគ្គលិកជាជនពិការប្រហែល ៨០០នាក់ ក្នុងឆ្នាំ២០១២។

**តារាងទី១៥ ចំនួនបុគ្គលិកជាជនពិការបម្រើការតាមប្រភេទអង្គការសង្គមស៊ីវិលនិង តាមភេទ**

| | មធ្យម | មេដ្យាន | សរុប | N |
|---|---|---|---|---|
| **បុគ្គលិកជាជនពិការ** | **3.4** | **1** | **160** | **47** |
| ក្នុងស្រុក | 4.0 | 1 | 87 | 22 |
| អន្តរជាតិ | 3.1 | 2 | 46 | 15 |
| សមាគម | 2.7 | 1.5 | 27 | 10 |
| ប្រុស | 2.3 | 1 | 25 | 108 |
| ស្រី | 1.1 | 0 | 15 | 52 |

## កម្រិតវប្បធម៌របស់បុគ្គលិក

បន្ទាប់មក អង្គការសង្គមស៊ីវិល ត្រូវបានស្នើឲ្យផ្តល់នូវចំនួនបុគ្គលិកទទួលបានបៀវត្សរ៍ដែលបានជ្រើសរើសឲ្យបម្រើការងារ ដែលមានកម្រិតវប្បធម៌ដូចជា: បណ្ឌិត វេជ្ជបណ្ឌិត អនុបណ្ឌិត បរិញ្ញាបត្រ/បរិញ្ញាបត្ររង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងក្រោមមធ្យមសិក្សាចំណេះទូទៅ។ រូបខាងក្រោមនេះ បង្ហាញពីសមាមាត្រនៃសំណាកអង្គការសង្គមស៊ីវិលជាមួយនឹងបុគ្គលិកទទួលបានបៀវត្សរ៍ ដែលមានកម្រិតវប្បធម៌ទាំងនេះ។ កម្រិតនៃការអប់រំភាគច្រើនបំផុតក្នុងចំណោមបុគ្គលិក ដែលធ្វើការជាមួយអង្គការសង្គមស៊ីវិល គឺបរិញ្ញាបត្រ/បរិញ្ញាបត្ររង។ ៧៧,៩% នៃអង្គការ យ៉ាងហោចណាស់មានបុគ្គលិកម្នាក់ដែលមានបរិញ្ញាបត្រ និង៥៧,២% មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ចំនួនសរុបបុគ្គលិកដែលមានបរិញ្ញាបត្រ/បរិញ្ញាបត្ររង ដូចដែលបានរាយការណ៍ដោយអ្នកផ្តល់ចម្លើយ ក្នុងការសិក្សាស្រាវជ្រាវនេះ មានចំនួន ១.៩២៦នាក់ (សូមមើលតារាងទី១៦) ។




**រូបទី១២ របាយនៃការអប់រំរបស់បុគ្គលិកតាមប្រភេទអង្គការសង្គមស៊ីវិល (n=271)**

**តារាងទី១៦ ចំនួនបុគ្គលិក តាមកំរិតនៃការអប់រំ**

| | មធ្យម | មេដ្យាន | សរុប | N |
|---|---|---|---|---|
| បណ្ឌិត | 1.9 | 1 | 64 | 34 |
| វេជ្ជបណ្ឌិត | 3.0 | 1 | 80 | 27 |
| អនុបណ្ឌិត | 3.3 | 1.5 | 417 | 126 |
| បរិញ្ញាបត្រ/បរិញ្ញាបត្ររង | 9.4 | 4 | 1926 | 205 |
| មធ្យមសិក្សាចំណេះទូទៅ | 6.4 | 4 | 941 | 148 |
| បឋមសិក្សា | 8.0 | 4 | 1066 | 134 |

## និន្នាការនៃការជ្រើសរើសបុគ្គលិកក្នុង ឆ្នាំ២០១២

ការបញ្ចូលនូវផ្នែកមួយអំពីការជ្រើសរើសបុគ្គលិកប្រចាំឆ្នាំ ទៅក្នុងការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់នូវមូលដ្ឋានសំខាន់មួយ សម្រាប់ការប្រៀបធៀបតួលេខការងារ ក្នុងការសិក្សាស្រាវជ្រាវអង្គការសង្គមស៊ីវិលនាពេលអនាគត ដែលត្រូវបានធ្វើឡើងដោយអង្គការ CCC ហើយការដាក់បញ្ចូលនេះ ក៏នឹងផ្តល់នូវការវិភាគអំពីនិន្នាការក្នុងវិស័យនេះផងដែរ។ គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១២ ៩១,៧% នៃអង្គការសង្គមស៊ីវិលដែលត្រូវបានធ្វើការសិក្សាស្រាវជ្រាវ បានជ្រើសរើសបុគ្គលិកមួយចំនួន ខណៈដែល ៨៨% បានមានប្រសាសន៍ថា យ៉ាងហោចណាស់មានបុគ្គលិកម្នាក់ក្នុងអង្គការបានឈប់ពីការងារ។

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានជ្រើសរើសបុគ្គលិក គិតជាមធ្យម មានប្រហែល ៥,៥នាក់ ក្នុងឆ្នាំ២០១២ (ជាមេដ្យាន៣ តារាងទី១៧)។ បុគ្គលិកថ្មីទាំងនេះ មកពីវិស័យ និងផ្នែកផ្សេងៗជាច្រើន (សូមមើលរូបទី១៨)។ ផ្នែកសំខាន់បំផុតបីសម្រាប់បុគ្គលិកចូលបម្រើការងារក្នុងឆ្នាំ២០១២ គឺសាលារៀន (សាកលវិទ្យាល័យ វិទ្យាល័យ ។ល។) អង្គការក្នុងស្រុក និងវិស័យឯកជន។




**រូបទី១៣ របាយភាគរយនៃការជ្រើសរើសបុគ្គលិក និងទំនោរនៃឈប់ពីការងារតាមប្រភេទអង្គការសង្គមស៊ីវិល**

ក្នុងឆ្នាំ២០១២ មាន ៤៦,៩% នៃអង្គការដែលបានផ្តល់ចម្លើយមានយ៉ាងហោចណាស់បុគ្គលិកម្នាក់ ឈប់បម្រើការងារជាមួយ។ តួលេខនេះ អង្គការសង្គមស៊ីវិល បាត់បង់បុគ្គលិកគិតជាមធ្យមចំនួន ៣,៧នាក់ ក្នុងមួយអង្គការ។ ចម្លើយនេះ រួមមានបុគ្គលិកដែលចាកចេញពីអង្គការសង្គមស៊ីវិល ដោយសារមូលហេតុផ្សេងៗ ដូចជា ការលាឈប់ពីការងារ ការចូលនិវត្តន៍ ការបណ្តេញចេញពីការងារ ។ល។ បន្ទាប់ពីបុគ្គលិក ចាកចេញពីអង្គការ ពួកគេ ផ្លាស់ទៅវិស័យផ្សេងៗជាច្រើន ដែលជាងមួយភាគបួន បានផ្លាស់ទៅវិស័យឯកជន ក្នុងនាមជាបុគ្គលិកទទួលបានបៀវត្សរ៍ ឬជាម្ចាស់អាជីវកម្មផ្ទាល់ខ្លួន។ ផ្នែកសំខាន់បំផុតបន្ទាប់ ដែលបុគ្គលិកអង្គការសង្គមស៊ីវិល បានផ្លាស់ទៅ បន្ទាប់ពីចាកចេញពីអង្គការ គឺអង្គការក្នុងស្រុក សាកលវិទ្យាល័យ (សិក្សាសាកលវិទ្យាល័យក្នុងស្រុក និង ក្រៅប្រទេស ។ល។) និងបន្ទាប់មកបម្រើការជាមួយរដ្ឋាភិបាល។

ការប៉ាន់ប្រមាណចំនួននៃការជ្រើសរើសបុគ្គលិក និងឈប់ពីការងារអង្គការសង្គមស៊ីវិលទាំងអស់ក្នុងប្រទេសកម្ពុជា បង្ហាញថាអត្រាជ្រើសរើសបុគ្គលិកប្រចាំឆ្នាំ គិតជាមធ្យម ២,២នាក់ និងអត្រាឈប់ពីការងារ គិតជាមធ្យម១,៧នាក់ ក្នុងមួយអង្គការ (រួមបញ្ចូលរាល់ទម្រង់ទាំងអស់នៃការចប់ពីការងារ)។ តួលេខនេះ បង្ហាញពីលំហូរជាវិជ្ជមានរបស់បុគ្គលិក ទៅក្នុងវិស័យអង្គការសង្គមស៊ីវិល ដែលបញ្ជាក់ថា ការងារក្នុងវិស័យនេះ អាចកើនឡើងក្នុងឆ្នាំ២០១២។ ទោះបីជាយ៉ាងណាតម្រូវឲ្យមានការស្រាវជ្រាវបន្ថែម ដើម្បីបញ្ជាក់ពីតួលេខនេះ។

**តារាងទី១៧ ចំនួនបុគ្គលិកដែលត្រូវបានជ្រើសរើស និងចាកចេញក្នុង ឆ្នាំ២០១២**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| **បុគ្គលិកត្រូវជ្រើសរើស** | **5.5** | **3** | **599** | **108** |
| ក្នុងស្រុក | 5.8 | 3 | 325 | 56 |
| អន្តរជាតិ | 5.5 | 3 | 210 | 38 |
| សមាគម | 4.6 | 2 | 64 | 14 |
| **បុគ្គលិកចាកចេញ** | **3.7** | **2** | **468** | **127** |
| ក្នុងស្រុក | 3.3 | 2 | 238 | 73 |
| អន្តរជាតិ | 3.5 | 2 | 141 | 40 |
| សមាគម | 6.4 | 3 | 89 | 14 |




**រូបទី១៨ ការជ្រើសរើសបុគ្គលិក និងការឈប់ពីការងារ (ភាគរយនៃអង្គការសង្គមស៊ីវិល ចម្លើយលើសពីមួយ)**

# ហិរញ្ញវត្ថុ

## មូលនិធិ ឆ្នាំ២០១២

វិធីមួយក្នុងការវាស់វែងឥទ្ធិពលរបស់អង្គការសង្គមស៊ីវិលលើប្រទេសកម្ពុជា គឺត្រូវមើលទៅលើចំនួនថវិកាដែលបានចំណាយ។ ទោះបីជាមាន ការជជែកដេញដោលក្តៅគគុក ប្រកបដោយវិទ្យាសាស្ត្រ ប៉ុន្តែ ការពិនិត្យមើលថវិការបស់អង្គការសង្គមស៊ីវិលប្រចាំឆ្នាំ ផ្តល់នូវការយល់ឃើញអំពីស្ថានភាពសេដ្ឋកិច្ចរបស់វិស័យនេះ និងឥទ្ធិពលទូទៅ អំពីរបៀបដែលអង្គការសង្គមស៊ីវិលដែលទទួលបានជោគជ័យ បានផ្តល់មូលនិធិ និងអនុវត្ត គម្រោងរបស់ពួកគេ (ជាទ្រឹស្តី គម្រោងដែលត្រូវបានអនុវត្ត និងមានផែនការល្អ ទំនងជាទទួលបានមូលនិធិបន្ថែម)។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមូលនិធិរបស់អង្គការសង្គមស៊ីវិល ដែលមានការប្រកួតប្រជែង ថវិកាគឺជាប្រធានបទរសើបមួយ ដែលមិនមែនអង្គការទាំងអស់ទេ ចង់ពិភាក្សាអំពីរឿងនេះ។ ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន២០០ ដែលបានឆ្លើយតបក្នុងការអង្កេតនេះ ពាក់ព័ន្ធនឹងមូលនិធិ មានមូលនិធិគិតជាមធ្យម ចំនួន ៥៧១.៣៧០ ដុល្លារអាមេរិក និងមូលនិធិសរុបជាមេដ្យាន ចំនួន៧០.០០០ ដុល្លារអាមេរិក។ ភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងតម្លៃថវិកាគិតជាមធ្យម និងតម្លៃថវិកាជាមេដ្យាន លើកបង្ហាញចម្លើយតបជាច្រើន ដែលអង្គការសង្គមស៊ីវិល បានឆ្លើយតបទៅនឹងសំណួរនេះ ក្នុងការសិក្សាស្រាវជ្រាវ ឆ្នាំ២០១២នេះ។

**តារាងទី១៨ ថវិកាលំអិតសម្រាប់ ឆ្នាំ២០១២ (ដុល្លារអាមេរិក)**

| តាមសកម្មភាព | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| សរុបមូលនិធិ | **571,370** | **70,000** | **114,000,000** | **200** |
| មូលនិធិគម្រោង | 432,320 | 50,000 | 82,600,000 | 191 |
| មូលនិធិស្នូល | 116,685 | 3,600 | 21,800,000 | 187 |
| **តាមប្រភេទអង្គការសង្គមស៊ីវិល** | **មធ្យម** | **មេដ្យាន** | **សរុប** | **n** |
| ក្នុងស្រុក | 289,082 | 50,000 | 30,900,000 | 107 |
| អន្តរជាតិ | 1,323,261 | 266,423 | 63,500,000 | 48 |
| សមាគម | 440,570 | 19,000 | 19,800,000 | 45 |

បន្ថែមលើការសាកសួរអំពីថវិកាសរុបរបស់អង្គការសង្គមស៊ីវិល ការអង្កេតឆ្នាំ២០១២នេះ បង្ហាញពីភាពខុសគ្នារវាងការផ្តល់មូលនិធិលើគម្រោង និងការផ្តល់មូលនិធិស្នូល។ យោងតាមអ្នកផ្តល់ចម្លើយក្នុងការអង្កេតនេះ បានបង្ហាញថា ការផ្តល់មូលនិធិលើគម្រោង (មូលនិធិដែលផ្តោតជាពិសេសលើការបញ្ចប់គម្រោងដែលត្រូវបានអនុម័ត) មានចំនួន ៧២,៥% នៃថវិការបស់អង្គការក្នុងឆ្នាំ២០១២ ដោយគិតជាមធ្យម សម្រាប់គម្រោងក្នុងឆ្នាំ២០១២ អង្គការសង្គម

ស៊ីវិល មានថវិកាចំនួន ៤៣២.៣២០ ដុល្លារអាមេរិក។ ការផ្ដល់មូលនិធិស្នូល (មូលនិធិដែលអង្គការសង្គមស៊ីវិល អាចប្រើប្រាស់សម្រាប់ទូទាត់ការចំណាយប្រតិបត្តិការ ដូចជាការជួលការិយាល័យ បុគ្គលិកផ្នែកគាំទ្រ ហេដ្ឋារចនាសម្ព័ន្ធ ។ល។ ព្រមទាំងការរៃអង្គាសថវិកាសកម្មភាពគម្រោង និងការបំពេញតម្រូវសហគមន៍ដែលកំពុងកើតឡើង) មានចំនួន ១៩% នៃថវិកា ក្នុងឆ្នាំ២០១២ (សូមមើលរូបទី១៥)។ អង្គការសង្គមស៊ីវិលចំនួនប្រាំពីរ បានផ្ដល់នូវចំនួនថវិកាសរុប ប៉ុន្តែមិនបានបែងចែកទៅតាម មូលនិធិស្នូល និងមូលនិធិលើគម្រោង។ ប្រសិនបើការចែកចាយមូលនិធិរបស់អង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១២ ត្រូវបានពិនិត្យមើល ជាមួយតែអង្គការ ដែលបានឆ្លើយតបសំណួរនេះប៉ុណ្ណោះ នោះយើងឃើញថា មូលនិធិលើគម្រោងមានចំនួន ៧៩,១% និងមូលនិធិស្នូលចំនួន២០,៩%។ ចំនួនថវិកានេះ ស្ថិតក្នុងថវិកាចំណាយដែលអាចទទួលយកបាន សម្រាប់អង្គការអន្តរជាតិ ដូចដែលបានបង្ហាញដោយសមាគមនៃអង្គការមិនមែនរដ្ឋាភិបាលពិភពលោក (WANGO ឆ្នាំ២០០៤)។

ដោយសារតែភាពស្មុគស្មាញនៃព័ត៌មានហិរញ្ញវត្ថុក្នុងវិស័យចម្រុះនេះ ដូច្នេះ វាមានការលំបាកក្នុងការប៉ាន់ប្រមាណចំនួនមូលនិធិសរុប របស់អង្គការសង្គមស៊ីវិលក្នុង ឆ្នាំ២០១២។ លើសពីនេះទៅទៀត ដោយសារបម្រែបម្រួលខ្ពស់នៃថវិការបស់អង្គការសង្គមស៊ីវិល ធ្វើអោយមានភាពខុសគ្នារវាងតម្លៃជាមេដ្យាន និងតម្លៃគិតជាមធ្យម ក្នុងតារាងទី១៨ បម្រែបម្រួលនេះធ្វើឲ្យការប៉ាន់ប្រមាណអំពីតម្លៃថវិកាសរុប មានបញ្ហាច្រើន។ ប្រសិនបើយើង ប៉ាន់ប្រមាណចេញពីថវិកាជាមេដ្យានដែលមានកម្រិតទាបខ្លាំងចំនួន ៧០.០០០ ដុល្លារអាមេរិក ក្នុងមួយអង្គការ យើងនឹងទទួលបានតម្លៃសរុបសម្រាប់វិស័យនេះគឺ ៨១,៣៤ លានដុល្លារអាមេរិក។ ចំនួននេះ ទំនងជាចំនួនទាបពេកដែលមិនអាចប៉ាន់ប្រមាណបានល្អ សម្រាប់វិស័យនេះ ដោយសារតែចំនួននេះ ទាបជាងចំនួនថវិកាដែលអ្នកចូលរួម បានឆ្លើយនៅក្នុងការសិក្សានេះ ។




**រូបទី១៥ របាយមូលនិធិអង្គការសង្គមស៊ីវិលឆ្នាំ២០១២ (n=114 លានដុល្លារ)**

ប្រសិនបើយើងពិនិត្យមើលចំនួនថវិកាដែលផ្តល់ដោយអង្គការសង្គមស៊ីវិល ដល់ប្រភពរាជរដ្ឋាភិបាល យើងឃើញថា ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ អង្គការសង្គមស៊ីវិលដែលមានសកម្មភាពចំនួន ៤០០ ក្នុងទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណែត របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរាយការណ៍ថា ពួកគេបានចំណាយថវិកាជាង ៣៤០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ (គិតជាមធ្យម ៨៥០.០០០ ដុល្លារអាមេរិក ក្នុងមួយអង្គការ)[5]។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលបានរួមបញ្ចូលហិរញ្ញប្បទានផ្ទាល់ពីបរទេស ពីដៃគូអភិវឌ្ឍន៍ជាតិ បានប៉ាន់ប្រមាណពីការចំណាយថវិកាសរុបចំនួន ១,៣៧៥ ពាន់លានដុល្លារអាមេរិក ក្នុងរយៈពេលដូចគ្នានេះ (គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១៣)។ ការប៉ាន់ប្រមាណតួលេខរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់អង្គការសង្គមស៊ីវិល បង្ហាញថវិកាសរុបក្នុងឆ្នាំ២០១២ ចំនួន ៩៨៧,៧ លានដុល្លារអាមេរិក ប៉ុន្តែចំនួននេះ ទំនងជាធំជាងចំនួនសរុបពិតប្រាកដ ដោយសារតែវាបង្ហាញថា ការចំណាយរបស់អង្គការសង្គមស៊ីវិល មានចំនួនជាង ៧០% នៃហិរញ្ញប្បទានផ្ទាល់ពីបរទេស។ លើសពីនេះទៅទៀត មិនមែនអង្គការសង្គមស៊ីវិលទាំងអស់ បានរាយការណ៍ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានោះទេ ហើយអង្គការដែលបានរាយការណ៍ ទំនងជាអង្គការធំ និងមានមូលនិធិប្រសើរជាង។

ការប៉ាន់ប្រមាណចេញពីថវិកាគិតជាមធ្យមដែលត្រូវបានគណនាក្នុងជំរឿននេះ ចំពោះអង្គការសង្គមស៊ីវិលបើកដំណើរការ និងទទួលបានមូលនិធិទាំងអស់ (១.១៣០ អង្គការ) ការ

[5] របាយការណ៍ត្រូវបានបង្កើតឡើងក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ចេញពីមូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា http://cdc.khmer.biz/index.asp ។

ប៉ាន់ប្រមាណនេះ ផ្តល់នូវថវិកាសរុបចំនួន ៣៩៣,៨ លានដុល្លារអាមេរិក។ ចំនួននេះ ទំនងជាមានភាពលម្អៀង និងមានចំនួនដូចគ្នានឹងចំនួនដែលត្រូវបានរាយការណ៍ដោយអង្គការសង្គមស៊ីវិលតែ៥០០ប៉ុណ្ណោះ ដែលបានរាយការណ៍ទៅ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមប្រព័ន្ធអ៊ីនធឺណែត។ ការប៉ាន់ប្រមាណគិតជាមធ្យម ក្នុងការសិក្សាស្រាវជ្រាវនេះ ដែលប្រហាក់ប្រហែលនឹងមធ្យមភាគឆ្នាំ២០១១ (៥១៧,៧៣០ ដុល្លារអាមេរិក) ផ្តល់នូវថវិកាសរុបសម្រាប់វិស័យនេះដែលមានចំនួន ៦៦៣ ដុល្លារអាមេរិក។ ចំនួននេះ ក៏កៀកគ្នាខ្លាំងផងដែរ នឹងតួលេខថវិកាដែលបានប៉ាន់ប្រមាណចេញពីការសិក្សាស្រាវជ្រាវឆ្នាំ២០១១។ ចំនួនថវិកាសរុបពិតប្រាកដ ទំនងជាស្ថិតក្នុងកម្រិតនៃការប៉ាន់ប្រមាណទាំងឆ្នាំ២០១១ និងឆ្នាំ២០១២។ ជាលទ្ធផលនៃការអង្កេតនេះ យើងអាចនិយាយថា ថវិកាសរុបរបស់វិស័យអង្គការសង្គមស៊ីវិល ក្នុងឆ្នាំ ២០១២ គឺមានចំនួនប្រហែលពី ៦០០ ទៅ ៧០០ លានដុល្លារ អាមេរិក ។

ទោះបីជាមានការលើកឡើងជាញឹកញាប់ ដោយរិះគន់ពីការគណនាទ្វេដងនៃថវិកាអង្គការសង្គមស៊ីវិលក៏ដោយ (ឧទាហរណ៍ នៅពេលដែលអង្គការ អន្តរជាតិមួយ ផ្តល់មូលនិធិដល់អង្គការក្នុងស្រុកមួយ ដើម្បីអនុវត្តគម្រោង ថវិកាទាំងនោះ នឹងត្រូវបាន រាប់បញ្ចូលទៅក្នុងថវិការបស់អង្គការសង្គមស៊ីវិលទាំងពីរ) ចំនួនមូលនិធិដែលត្រូវបានផ្តល់ ដោយអ្នកផ្តល់ចម្លើយក្នុងការអង្កេត ទំនងជាមិនត្រូវបានគណនាទ្វេដងឡើយ ដោយសារតែភាពចម្រុះ និងការជ្រើសរើសសំណាកដោយចៃដន្យ។ លើសពីនេះទៅទៀត ការប៉ាន់ប្រមាណអំពីចំនួនមូលនិធិដែលអង្គការសង្គមស៊ីវិលផ្តល់ឲ្យគ្នាទៅវិញទៅមកនៅកម្ពុជា (សូមមើលផ្នែកសហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលខាងក្រោម) បង្ហាញថា ឥទ្ធិពលនៃហិរញ្ញប្បទានទៅលើមាត្រដ្ឋានជាតិ គឺមានតិចតួច (តិចជាង១០% នៃថវិកាស្នាសរុប) និងស្ថិតក្នុងកម្រិតនៃថវិកាជាតិដែលផ្តល់ឲ្យខាងលើ។

## ប្រភពនៃមូលនិធិ ឆ្នាំ២០១២

ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន ២៣៨ ក្នុងសំណាក នៃការអង្កេតនេះ ដែលបានអនុវត្តគម្រោងក្នុង ឆ្នាំ២០១២ មាន ៩១,២% (៩៨ អង្គការ) បានរាយការណ៍ថា ពួកគេបានទទួលមូលនិធិពីអង្គការអន្តរជាតិ។ ចំនួនអង្គការសង្គមស៊ីវិលគួរឲ្យ កត់សម្គាល់ ក៏បានរាយការណ៍ផងដែរ ពីការពឹងផ្អែកលើម្ចាស់ជំនួយពហុភាគី (ដូចជាធនាគារ អភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក) និងអំណោយឯកជន។ ចម្លើយតបដទៃទៀត រួមមានចំណូលរកបានព្រះវិហារ/សាសនា ប្រភពអ្នកស្ម័គ្រ និងប្រភពពីបរទេស (មិនត្រូវបានបញ្ជាក់ច្បាស់ថាតើមូលនិធិទាំងនេះ គឺជាអំណោយឯកជន ឬមកពីអង្គការនោះទេ)។




**រូបទី១៦ ប្រភពនៃមូលនិធិដែលលើកឡើងដោយអង្គការសង្គមស៊ីវិលសម្រាប់អនុវត្តគម្រោងឆ្នាំ២០១២ (n=238 ចម្លើយលើសពីមួយ)**

## ការរំពឹងទុកអំពីមូលនិធិ សម្រាប់ឆ្នាំ ២០១៣

ក្នុងចំណោមនាយក និងបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់ ដែលបានចូលរួមក្នុងការសិក្សានេះ ភាគច្រើនលើសលុប (៧៨,៥%) យល់ឃើញថា មូលនិធិសរុបរបស់អង្គការសង្គមស៊ីវិលសម្រាប់ឆ្នាំ២០១៣ នឹងមានការកើនឡើង ឬស្ថិតនៅដដែល ដូចគ្នានឹងឆ្នាំ២០១២ (សូមមើលរូបទី១៧)។ មានអ្នកផ្តល់ចម្លើយតែ ២១,១% ប៉ុណ្ណោះ ដែលយល់ឃើញថា មូលនិធិអង្គការសង្គមស៊ីវិលសម្រាប់ឆ្នាំ២០១៣ នឹងមានចំនួនទាបជាងមូលនិធិឆ្នាំ២០១២ ដែលនេះឆ្លុះបញ្ចាំងជាវិជ្ជមាននៅក្នុងវិស័យនេះ សម្រាប់ឆ្នាំខាងមុខ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសុទិដ្ឋិនិយមជាង ពាក់ព័ន្ធនឹងមូលនិធិសម្រាប់គម្រោងរបស់ពួកគេក្នុងឆ្នាំ២០១៣ ខណៈដែលចម្លើយតបរបស់សមាគម បានឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជានៃមូលនិធិពួកគេសម្រាប់ឆ្នាំខាងមុខ។ មួយភាគបី (៣២% ស្មើនឹង ៧០ អង្គការ) នៃអង្គការសង្គមស៊ីវិលរំពឹងថា មូលនិធិឆ្នាំ២០១៣ នឹងបានមកពីអង្គការអន្តរជាតិ និងប្រភពមូលនិធិធំៗដទៃទៀត (ពហុភាគី អំណោយឯកជន និងប្រាក់ចំណូលរកបាន) រំពឹងថានឹងស្ថិតនៅដដែលផងដែរ។




រូបទី១៧ ការរំពឹងទុកពីការផ្លាស់ប្តូរមូលនិធិតាមប្រភេទអង្គការសង្គមស៊ីវិលក្នុង ឆ្នាំ២០១៣

# សកម្មភាពការងារ

## វិស័យសកម្មភាពចម្បង

ចំនួននិងភាពចម្រុះរបស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា មានន័យថាមានវិស័យផ្សេងៗគ្នាមួយចំនួនដែលអង្គការកំពុងមានសកម្មភាព ហើយបានរួមចំណែកដល់ការអភិវឌ្ឍន៍កម្ពុជាទាំងមូល។ ការសិក្សានេះអង្គការសង្គមស៊ីវិលបានលើកឡើងពីការងារចម្បងក្នុងវិស័យជាង ១៩ផ្សេងៗគ្នា។ រូបខាងក្រោមនេះ បង្ហាញថាមានចំនួន ៣២,១% នៃអង្គការបាន




**រូបទី១៨ វិស័យសកម្មភាពចម្បងៗ**

ពាយការណ៍ថា វិស័យសំខាន់ដែលបានអនុវត្តសកម្មភាពគឺវិស័យអប់រំ និងការបណ្តុះបណ្តាល បន្ទាប់មកគឺកសិកម្ម និងសុខភាពសត្វ (៩,៦%) ព្រមទាំង សុខាភិបាល អាហារូបត្ថម្ភ និងមេរោគអេដស៍/ជំងឺអេដស៍ (៩,៦%)។ វិស័យទាំងនេះ ប្រហាក់ប្រហែលនឹងវិស័យចម្បងលើកឡើងក្នុងជំរឿន ឆ្នាំ២០១២ ដែលវិស័យសំខាន់បំផុតប្រាំពីរ ដូចគ្នាទាំងជំរឿន និងអង្កេត។

ការស្វែងយល់អំពីវិស័យដែលអង្គការសង្គមស៊ីវិល មានភាពសកម្មបំផុត (និង សកម្មតិចបំផុត) មានសារប្រយោជន៍សម្រាប់ក្រសួងរបស់រាជរដ្ឋាភិបាល ភ្នាក់ងារម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលខ្លួនឯង។ ព័ត៌មាននេះ អាចប្រើប្រាស់ ដើម្បីសម្របថវិកា និងផែនការយុទ្ធសាស្ត្រ ជាមួយវិស័យសមស្រប ហើយព័ត៌មាននេះ អាចរកឃើញនូវចំណុចខ្សោយ ក្នុងវិស័យមួយចំនួន ដែលគេអាចបម្រុងធនធានបន្ថែម សម្រាប់វិស័យនោះ។ ក្នុងគោលបំណងនេះ អ្នកផ្តល់ចម្លើយ ក៏ត្រូវសាកសួរផងដែរ អំពីវិស័យបន្ថែមអ្វីខ្លះដែលគេធ្វើការ (តារាងទី១៩)។

**តារាងទី១៩ សកម្មភាពលើវិស័យផ្សេងទៀតរបស់អ្នកផ្តល់ចម្លើយ (ចម្លើយអាចលើសពីមួយ)**

| | ចំនួន | ភាគរយ (n=271) |
|---|---|---|
| អប់រំ និងបណ្តុះបណ្តាល | 135 | 49.8 |
| អភិវឌ្ឍន៍សហគមន៍ | 76 | 28.0 |
| សុខុមាលភាព និងសិទ្ធិកុមារ | 69 | 25.5 |
| សុខភាព អាហារូបត្ថម្ភ និង អេដស៍ | 61 | 22.5 |
| កសិកម្មនិងសុខភាពសត្វ | 57 | 21.0 |
| យេនឌ័រ និងបញ្ហាស្ត្រី | 57 | 21.0 |
| ទឹក និងអនាម័យ | 51 | 18.8 |
| ជំនួយមនុស្សធម៌ និងការ ត្រៀមបង្ការគ្រោះមហន្តរាយ | 49 | 18.1 |
| បរិស្ថាន និងធនធានធម្មជាតិ | 48 | 17.7 |
| ការស្រាវជ្រាវ និងការប្រឹក្សា | 40 | 14.8 |
| ឥណទាន និងសន្សំប្រាក់ | 36 | 13.3 |
| លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិ មនុស្ស | 34 | 12.5 |
| ការតស៊ូមតិ និងកិច្ចពិគ្រោះ យោបល់នយោបាយ | 31 | 11.4 |
| ទេសចរណ៍ សិល្បៈ និងវប្បធម៌ | 30 | 11.1 |
| ផ្តល់ជំនួយដល់អង្គការក្រៅរដ្ឋា ភិបាល/អង្គការតាមសហគមន៍ | 23 | 8.5 |
| ធុរកិច្ច/អភិវឌ្ឍន៍ស្ថាប័ន | 22 | 8.1 |
| សាសនា/ជំនឿ | 21 | 7.7 |
| ពិការភាព និងស្តារនីតិសម្បទា | 16 | 5.9 |
| សកម្មភាព/បង្កើនការយល់ដឹង អំពីគ្រាប់មីនគ្រាប់មិនទាន់ផ្ទុះ | 6 | 2.2 |
| ផ្សេងៗ | 57 | 21.0 |

អ្នកផ្តល់ចម្លើយបង្ហាញពីគំរូមួយ ប្រហាក់ប្រហែលទៅនឹងការងារចម្បងរបស់អង្គការសង្គមស៊ីវិល ដោយវិស័យសំខាន់បំផុតចំនួនប្រាំពីរ នៅតែដូចគ្នាដដែល ហើយការអប់រំ គឺជាវិស័យអាទិភាពខ្ពស់បំផុត។

មានមូលហេតុមួយចំនួនដែលអង្គការសង្គមស៊ីវិល ធ្វើការក្នុងវិស័យចម្បង។ កត្តាសំខាន់បំផុតចំនួនប្រាំ ក្នុងការកំណត់ សកម្មភាពរបស់ពួកគេ គឺតម្រូវការសហគមន៍ គោលដៅ និងបេសកកម្មរបស់អង្គការ ផែនការអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្ររបស់អង្គការ និងតម្រូវការរបស់ម្ចាស់ជំនួយ។ រូបទី១៩ បង្ហាញថា អង្គការភាគច្រើន (៥៦,៨%) បានមានប្រសាសន៍ថា តម្រូវការសហគមន៍ កំណត់ពីវិស័យដែលពួកគេធ្វើការ។ ហើយ មានសមាមាត្រត្រឹម (៥,៥%) បានមានប្រសាសន៍ថា អនុសាសន៍ចេញពីក្រុមប្រឹក្សាភិបាលរបស់អង្គការ មានឥទ្ធិពលក្នុងការកំណត់គោលដៅការងាររបស់ពួកគេ។ ទោះបីជាមានអ្នករិះគន់ជាច្រើនក៏ដោយ ប៉ុន្តែលទ្ធផលទាំងនេះ បង្ហាញថា អង្គការសង្គមស៊ីវិល កំពុងខិតខំប្រឹងប្រែងដោះស្រាយបញ្ហារបស់សហគមន៍ដែលពួកគេបម្រើ និងសម្របគម្រោងរបស់ពួកគេ ជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។




**រូបទី១៩ កត្តាដែលកំណត់លើវិស័យការងាររបស់អង្គការសង្គមស៊ីវិល ( n=271 ចម្លើយលើសពីមួយ)**

## គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ គឺជាគោលដៅជាក់លាក់សម្រាប់ការអភិវឌ្ឍន៍ជាតិ ដែលត្រូវបានកែសម្រួលទៅតាមប្រទេសនីមួយៗ ហើយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ២០០០។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គ្របដណ្តប់គោលដៅធំៗចំនួនប្រាំបួន ចាប់ពីការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លាន ដល់ការលើកកម្ពស់ការអប់រំចីរភាពបរិស្ថាន និងសហប្រតិបត្តិការអន្តរជាតិ។ ដោយមានការវាយតម្លៃតាមដានចំនួនពីរដងក្នុងឆ្នាំ២០០៥ និងឆ្នាំ២០១០ ដើម្បីដឹងពីវឌ្ឍនភាពនៃគោលដៅទាំងនេះ ហើយត្រូវបានរំពឹងថានឹងសម្រេច គោលដៅស្ថាពរ បានត្រឹមឆ្នាំ២០១៥។ រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគី ដូចជាធនាគារពិភពលោក បានសម្របផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ការសម្របសកម្មភាពរបស់អង្គការសង្គមស៊ីវិល ជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ធានាថា គម្រោងនឹងមានឥទ្ធិពលកាន់តែខ្ពស់ តាមរយៈការធ្វើការងារឆ្ពោះទៅកាន់គោលដៅរួមមួយជាមួយអង្គការសង្គមស៊ីវិលដទៃទៀត និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ ហើយនៅពេលជំណាលគ្នានេះដែរ ការសម្របសកម្មភាពនេះ ក៏ធានាឲ្យគម្រោងមានទំនាក់ទំនងជាមួយការអភិវឌ្ឍន៍ជាតិ និងគោលដៅរបស់សហគមន៍អភិវឌ្ឍន៍អន្តរជាតិធំៗ។

**តារាងទី២០ គោលដៅសហស្សវត្សរ៍ដែលអង្គការសង្គមស៊ីវិលចូលរួមចំណែក**

| | ចំនួន | ភាគរយ (n=118) |
|---|---|---|
| លប់បំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន ធ្ងន់ធ្ងរ | 58 | 49.2 |
| សម្រេចអោយបានសកលសកម្មការអប់រំ បឋមសិក្សា | 54 | 45.8 |
| លើកកម្ពស់យេនឌ័រ និងផ្តល់សិទ្ធិអំណាច ដល់ស្ត្រី | 52 | 44.1 |
| លើកកម្ពស់សុខភាពមាតា | 36 | 30.5 |
| ធានាចិរភាពបរិស្ថាន | 25 | 21.2 |
| កាត់បន្ថយមរណភាពកុមារ | 21 | 17.8 |
| ប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗ | 20 | 16.9 |
| បង្កើនភាពជាដៃគូជាសកលសំរាប់កិច្ច អភិវឌ្ឍន៍ | 20 | 16.9 |
| ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពី សង្គ្រាមនិងសង្គ្រោះជនរងគ្រោះ | 5 | 4.2 |

តាមការអង្កេតនេះ មាន៥៩,៤% (១៦១នាក់) នៃអ្នកផ្តល់ចម្លើយបានមានប្រសាសន៍ថា ពួកគេបានដឹងពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង ៣៩,៩% (១០៨នាក់) បានមានប្រសាសន៍ថា ពួកគេមិនដឹងអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ក្នុងចំណោមអ្នកដែលបានដឹងអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មាន ៧៣,៣% (១១៨នាក់) បាននិយាយថា អង្គការពួកគេ មានសកម្មភាពគាំទ្រយ៉ាងហោចណាស់គោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទាំងប្រាំបួន។ គោលដៅបីដែលអង្គការសង្គមស៊ីវិលជាច្រើន បានចូលរួមចំណែកយ៉ាងសកម្មជាងគេនោះ គឺការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ ការសម្រេចឲ្យបានជាទូទៅការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំ និងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្រ្តី (សូមមើលតារាងទី២០)។




**រូបទី២០ អង្គការសង្គមស៊ីវិលដែលគាំទ្រដល់គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា (n=161)**

## ការអនុវត្តន៍គម្រោង

អង្គការសង្គមស៊ីវិលចំនួន ២៣០ ឬស្មើនឹង ៨៤,៩% នៃអ្នកផ្តល់ចម្លើយបានរាយការណ៍ថា ពួកគេបានអនុវត្តគម្រោងយ៉ាងហោចណាស់មួយ អំឡុងពេលឆ្នាំ២០១២ ដែលគិតជាមធ្យមមានចំនួន ៣,៥ គម្រោង ក្នុងមួយអង្គការសង្គមស៊ីវិល (សូមមើលតារាងទី២១)។ នេះ គឺចំនួនគិតជាមធ្យមនៃអង្គការសង្គមស៊ីវិល ដែលកំពុងតែអនុវត្តគម្រោង (ជាមេដ្យាន ៣)។ ប្រសិនបើ

យើងប៉ាន់ប្រមាណចំនួនទាំងនេះ ទៅនឹងអង្គការសង្គមស៊ីវិលបើកដំណើរការទាំងអស់ ដោយគិតថា មានតែ ៨៦% នៃអង្គការសង្គមស៊ីវិលបើកដំណើរការប៉ុណ្ណោះ បានអនុវត្តគម្រោងក្នុងឆ្នាំ ២០១២[6] ដូច្នេះយើងឃើញថា អង្គការសង្គមស៊ីវិលបើកដំណើរការ បានអនុវត្តគម្រោងប្រហែល ៥០០០ ក្នុងប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០១២។

**តារាងទី២១ ការអនុវត្តគម្រោង ផ្អែកតាមលទ្ធផលអង្កេតឆ្នាំ២០១២**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| **សរុបចំនួនគម្រោងក្នុងឆ្នាំ២០១២** | **3.5** | **3** | **816** | **230** |
| ក្នុងស្រុក | 3.3 | 3 | 406 | 123 |
| អន្តរជាតិ | 5.2 | 3 | 297 | 57 |
| សមាគម | 2.3 | 2 | 113 | 50 |

## ខេត្តគោលដៅ

ដើម្បីស្វែងយល់បន្ថែមពីគម្រោង ដែលអង្គការសង្គមស៊ីវិលបានអនុវត្តអ្នកធ្វើសម្ភាសន៍ បានស្នើឲ្យអ្នកផ្តល់ចម្លើយផ្តល់នូវព័ត៌មានលម្អិតអំពីគម្រោងចំនួនពីរចុងក្រោយ ដែលអង្គការសង្គមស៊ីវិល បានចុះហត្ថលេខា ផ្តួចផ្តើមគំនិត និង/ឬផ្តល់មូលនិធិក្នុងឆ្នាំ២០១២។ ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានផ្តល់ចម្លើយមាន ២៣៨ អង្គការ បានផ្តល់ព័ត៌មានលម្អិតអំពីគម្រោងយ៉ាងហោចណាស់មួយ ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១២។ ការប្រើប្រាស់កាលបរិច្ឆេទថ្មី និងចំនួនគម្រោង (គម្រោងពីរចុងក្រោយចាប់ផ្តើមក្នុងឆ្នាំ២០១២) ផ្តល់ឲ្យគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នូវរង្វាស់មួយដែលងាយស្រួល ដើម្បីប្រើប្រាស់នៅក្នុងការអង្កេតជំហានបន្ទាប់ទៀត ព្រមទាំងផ្តល់នូវការវាស់វែងមួយ សម្រាប់ធៀប និងតាមដាននិន្នាការក្នុងការអនុវត្តន៍គម្រោងរបស់អង្គការសង្គមស៊ីវិលប្រចាំឆ្នាំ ដែលការធ្វើបែបនេះ កាត់បន្ថយគម្រោងជាន់គ្នា និងការរាប់លើស។

[6] អង្គការសង្គមស៊ីវិលបើកដំណើរការដែលមានមូលនិធិ ចេញពីជំរឿនឆ្នាំ២០១២ តំណាងឲ្យ ៨៦,១% នៃចំនួនអង្គការសង្គមស៊ីវិលសរុប (១.១៣០ អង្គការ)។ ដោយសារតែអង្គការសង្គមស៊ីវិលទាំងនេះ ទំនងខ្លាំងថាបានអនុវត្តគម្រោងក្នុងឆ្នាំ២០១២ ដូច្នេះចំនួននេះ ត្រូវបានប្រើប្រាស់ដើម្បីគណនាចំនួនគម្រោងអង្គការសង្គមស៊ីវិលសរុបដែលត្រូវបានអនុវត្តក្នុងឆ្នាំ២០១២។




**រូបទី២១ ខេត្តគោលដៅរបស់អង្គការសង្គមស៊ីវិលសម្រាប់ឆ្នាំ ២០១២ (ចម្លើយលើសពីមួយ n=238)**

រាជធានីភ្នំពេញ គឺជាទីកន្លែងដែលត្រូវបានផ្ដោតគោលដៅបំផុត សម្រាប់គម្រោងរបស់អង្គការសង្គមស៊ីវិល ដោយជាង ៣០% នៃអង្គការសង្គមស៊ីវិលទាំងអស់ មានគម្រោងយ៉ាងហោចណាស់មួយ នៅទីនោះ។ នេះមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារតែ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលដែលមានប្រជាជនច្រើន និងគ្របដណ្ដប់តំបន់ភូមិសាស្ត្រធំ។ ជាតំបន់ទីក្រុងដែលមានប្រជាជនចម្រុះជាងមួយលាននាក់ អ្នករស់នៅទីក្រុងនេះ ទទួលរងបញ្ហាទំនើបកម្មជាច្រើន ដែលកម្រមាននៅតំបន់ជនបទនៃប្រទេសកម្ពុជា ដូចជាការប្រើប្រាស់ថ្នាំញៀនកម្រិតខ្ពស់ និងអត្រាខ្ពស់នៃមេរោគអេដស៍/ជំងឺអេដស៍។ វាជារឿងគួរឲ្យចាប់អារម្មណ៍ផងដែរ ដោយកត់សម្គាល់ឃើញថា ទោះបីជាអង្គការសង្គមស៊ីវិលជាង ៥០% មានមូលដ្ឋានក្នុងរាជធានីភ្នំពេញក៏ដោយ ប៉ុន្តែ មានគម្រោងអង្គការសង្គមស៊ីវិលតែជាង ៣០% ប៉ុណ្ណោះ ត្រូវបានអនុវត្តនៅទីនោះ ។

ក្នុងចំណោមខេត្តទាំងអស់ សៀមរាប បាត់ដំបង និងកំពង់ចាម គឺជាខេត្តដែលមានគម្រោងរបស់អង្គការសង្គមស៊ីវិលច្រើនជាងគេ (សូមមើលតារាងទី២២)។ ខេត្តទាំងនេះ ក៏ជាខេត្តដែលមានចំនួនប្រជាជនច្រើនជាងគេផងដែរ ក្រៅពីរាជធានីភ្នំពេញ។ ខេត្តដែលមានគម្រោងតិចបំផុត គឺខេត្តស្ទឹងត្រែង ប៉ៃលិន និងកែប។ វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ដែលខេត្តទាំងនេះ មានអង្គការសង្គមស៊ីវិលតិចតួចបំផុតផងដែរ ។ ខេត្តទាំងបីនេះរួមបញ្ចូលគ្នា មានអង្គការសង្គមស៊ីវិលបើកដំណើរការតិចជាង ១% នៃអង្គការបើកដំណើរការសរុប ដែលត្រូវ

បានកំណត់អត្តសញ្ញាណក្នុងជំរឿនឆ្នាំ២០១២នេះ។ មូលហេតុដែលមានគម្រោងតិចក្នុងតំបន់ទាំងបីនេះ គឺអាចមកពីលក្ខណៈដាច់ស្រយាលនៃខេត្តស្ទឹងត្រែង និងដោយសារតែខេត្តប៉ៃលិន និងខេត្តកែប មានទំហំតូច (ទាំងភូមិសាស្ត្រ និងចំនួនប្រជាជន)។

**តារាងទី២២ ខេត្តគោលដៅសម្រាប់គម្រោងអង្គការសង្គមស៊ីវិល (n=238; ចម្លើយលើសពីមួយ )**

| | ចំនួន | ភាគរយ |
|---|---|---|
| ភ្នំពេញ | 77 | 32.4 |
| សៀមរាប | 58 | 24.4 |
| បាត់ដំបង | 53 | 22.3 |
| កំពង់ចាម | 42 | 17.6 |
| កំពង់ធំ | 39 | 16.4 |
| កណ្តាល | 39 | 16.4 |
| តាកែវ | 38 | 16.0 |
| កំពង់ស្ពឺ | 34 | 14.3 |
| កំពត | 34 | 14.3 |
| ព្រៃវែង | 31 | 13.0 |
| កំពង់ឆ្នាំង | 27 | 11.3 |
| បន្ទាយមានជ័យ | 25 | 10.5 |
| ពោធិ៍សាត់ | 25 | 10.5 |
| ក្រចេះ | 23 | 9.7 |
| ស្វាយរៀង | 23 | 9.7 |
| ព្រះវិហារ | 21 | 8.8 |
| ឧត្តមានជ័យ | 21 | 8.8 |
| កោះកុង | 21 | 8.8 |
| ព្រះសីហនុ | 20 | 8.4 |
| ស្ទឹងត្រែង | 18 | 7.6 |
| រតនគីរី | 18 | 7.6 |
| មណ្ឌលគីរី | 16 | 6.7 |
| ប៉ៃលិន | 15 | 6.3 |
| កែប | 13 | 5.5 |

បន្ទាប់មក យើងបានពិនិត្យពីចំនួនអង្គការសង្គមស៊ីវិលដែលមានគម្រោងក្នុងខេត្តនីមួយៗ និងផ្ទៀងផ្ទាត់ចំនួនទាំងនេះ ជាមួយនឹងចំនួននៃគ្រួសារក្រីក្រក្នុងខេត្តនោះ (ចេញពីទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ ទិន្នន័យនេះ បង្ហាញយើងពីទីកន្លែងដែលអង្គការ

សង្គមស៊ីវិល កំពុងផ្តោតគោលដៅគម្រោងថ្មីៗ (ដោយសារតែការសិក្សាស្រាវជ្រាវនេះ ប្រមូល តែព័ត៌មានអំពីគម្រោងពីរចុងក្រោយដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១២ប៉ុណ្ណោះ) ហើយទិន្នន័យ នេះ បង្ហាញយើងថាតើ ចំនួនអង្គការសង្គមស៊ីវិលដែលធ្វើការនៅទីនោះ ស្របគ្នាជាមួយនឹង ចំនួនគ្រួសារក្រីក្រនៅក្នុងតំបន់នោះ ឬអត់។ វាជារឿងសំខាន់ដែលត្រូវចងចាំថា គម្រោង អង្គការសង្គមស៊ីវិល មិនមែនផ្តោតគោលដៅតែលើអ្នកក្រីក្រនោះទេ ហើយត្រូវចងចាំដែរថា ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រមិនបានបង្ហាញពីតម្រូវការខុសគ្នារបស់សហគមន៍ ដែល អង្គការសង្គមស៊ីវិល អាចធ្វើការដោះស្រាយបាននោះទេ។ ទោះបីជាយ៉ាងណា ទិន្នន័យនេះ ធ្វើឲ្យមានចំណាប់អារម្មណ៍ ដោយសារវាផ្តល់នូវរង្វាស់មួយ ដើម្បីវាស់វែងការកំណត់គោលដៅ របស់អង្គការសង្គមស៊ីវិល។

ដោយសារតែទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនទាន់ត្រូវបានបញ្ចប់ ក្នុងខេត្ត ទាំងបួននេះនៅឡើយ ដូច្នេះមិនមានការប្រៀបធៀបអំពីចំនួនគ្រួសារក្រីក្រក្នុងខេត្តបីក្នុង ចំណោមខេត្តទាំងបួន ដែលបានកំណត់គោលដៅច្រើនជាងគេ (រាជធានីភ្នំពេញ ខេត្ត កំពង់ចាម និងខេត្តកំពង់ធំ)។ លទ្ធផលចេញមកពីខេត្តដទៃទៀត បង្ហាញថា មានអង្គការសង្គម ស៊ីវិលតិចតួច ដែលមានគម្រោងក្នុងខេត្តបួនក្នុងចំណោមខេត្តក្រីក្រជាងគេ (បាត់ដំបង កណ្តាល តាកែវ និងព្រៃវែង)។ ខេត្តសៀមរាបដែលមានចំនួនគ្រួសារក្រីក្រច្រើនជាងគេទីប្រាំ ទំនងជាមានអង្គការសង្គមស៊ីវិល ផ្តោតគោលដៅគម្រោងរបស់ពួកគេច្រើន។ ទិន្នន័យនេះ ប្រហាក់ប្រហែលទៅនឹងការប្រៀបធៀបទីតាំងការិយាល័យរបស់អង្គការសង្គមស៊ីវិល និង ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលបានបង្ហាញពីកង្វះតំណាងនៃការិយាល័យអង្គការ សង្គមស៊ីវិល (បើប្រៀបធៀបទៅនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ក្នុងខេត្តតាកែវ និង ខេត្ត ព្រៃវែង។

ខេត្តមួយចំនួនក្នុងចំណោមខេត្តទាំងនេះ ដែលមានអត្រាអង្គការសង្គមស៊ីវិលខ្ពស់ ធៀបនឹងចំនួនគ្រួសារក្រីក្រ រួមមានខេត្តកំពត កោះកុង ព្រះសីហនុ និងមណ្ឌលគិរី។ ខេត្តទាំង នេះ មានចំនួនគ្រួសារក្រីក្រទាបបំផុត ប៉ុន្តែមានចំនួនអង្គការសង្គមស៊ីវិលខ្ពស់ ដែលអនុវត្ត គម្រោងថ្មីៗក្នុងឆ្នាំ២០១២។ ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគិរី ក៏ទំនងជាមានតំណាងលើស បន្តិចផងដែរ បើប្រៀបធៀបទីតាំងការិយាល័យអង្គការសង្គមស៊ីវិល ជាមួយនឹងទិន្នន័យអត្ត សញ្ញាណកម្មគ្រួសារក្រីក្រ។ ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ ដែលទំនងជាមានតំណាង លើសផងដែរ តាមរយៈការិយាល័យអង្គការសង្គមស៊ីវិល ខេត្តទាំងពីរនេះ បង្ហាញតំណាង វិជ្ជមាន ជាមួយគម្រោងអង្គការសង្គមស៊ីវិល។




**រូបទី២២ ចំនួនអង្គការសង្គមស៊ីវិលធ្វើការតាមបណ្តាខេត្ត និងអត្តសញ្ញាណគ្រួសារក្រីក្រ**

**(n=238 ចម្លើយលើសពីមួយ)**

ករណីខេត្តព្រៃវែង គឺជាឧទាហរណ៍ច្បាស់មួយដែលត្រូវពិចារណា។ ព្រៃវែង ស្ថិតនៅភាគខាងកើតនៃរាជធានីភ្នំពេញ និងត្រូវបានស្គាល់ច្បាស់ថាជាខេត្តមួយក្នុងចំណោមខេត្តក្រីក្រជាងគេក្នុងប្រទេសកម្ពុជា។ យោងទៅតាមលទ្ធផលថ្មីបំផុត នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្របង្ហាញថា ព្រៃវែងគឺជាខេត្តមួយក្នុងចំណោមខេត្តជាច្រើនដែលមានចំនួនប្រជាជនក្រីក្រច្រើនជាងគេ (៦៦.៦៨៩នាក់ ក្រសួងផែនការ ឆ្នាំ២០១២) និងមានចំនួនភាគរយគ្រួសារ ក្រីក្រខ្ពស់គិតតាមចំនួនប្រជាជន។ ទោះបីជាយ៉ាងណាក៏ដោយ មានតែ ១៣% នៃអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការអង្កេតនេះប៉ុណ្ណោះ បានរាយការណ៍អំពីកម្មវិធី ដែលផ្តោតគោលដៅក្នុងខេត្តព្រៃវែងនេះ។ លើសពីនេះទៅទៀត មានតែអង្គការសង្គមស៊ីវិល ២៣ ប៉ុណ្ណោះ (១,២%) មានការិយាល័យកណ្តាលរបស់ពួកគេក្នុងខេត្តព្រៃវែង។

## អ្នកទទួលផល

ការអង្កេតឆ្នាំ២០១២នេះ អ្នកផ្តល់ចម្លើយត្រូវបានស្នើឲ្យផ្តល់អត្តសញ្ញាណ អំពីប្រភេទនៃអ្នកទទួលផលដែលគម្រោងរបស់ពួកគេ ផ្តោតគោលដៅលើ និងត្រូវបានស្នើឲ្យផ្តល់នូវចំនួនជាក់លាក់នៃអ្នកទទួលផលផ្ទាល់ និងប្រយោលនៃកម្មវិធីរបស់អង្គការ។ អ្នកផ្តល់ចម្លើយទាំងអស់ចំនួន២៧១នាក់។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ចម្លើយនៃអង្គការសង្គមស៊ីវិលចំនួន ៥៣ នាក់ (១៩,៦%) បានរាយការណ៍ថា ពួកគេមិនបានដឹងថា តើពួកគេបានជួយអ្នកទទួលផលចំនួនប៉ុន្មានទេ នៅពេលដែលសួរអំពីចំនួនអ្នកទទួលផលដែលពួកគេបានជួយ។

ជារួម អង្គការសង្គមស៊ីវិល បានរាយការណ៍ពីការកំណត់គោលដៅអ្នកទទួលផលជាង ១៣ក្រុម (សូមមើលរូបទី២៣)។ ក្រុមអ្នកទទួលផលសំខាន់ជាងគេ គឺក្រុមកុមារដែលអង្គការសង្គមស៊ីវិលចំនួន ៦៣ (២៣,២%) បានផ្តោតគោលដៅលើក្រុមនេះ សម្រាប់គម្រោង។ ក្រុមអ្នកទទួលផលគោលដៅសំខាន់ជាងគេចំនួនប្រាំពីរ (ក្រុមកុមារ ប្រជាជនទូទៅ អ្នកក្រីក្រ ស្ត្រី និស្សិត/យុវជន ជនពិការ និងអ្នកជំទួញ) ក្រុមទាំងនេះ ក៏ស្របគ្នាជាមួយវិស័យសំខាន់បំផុតចំនួនប្រាំពីរ សម្រាប់គម្រោងរបស់អង្គការសង្គមស៊ីវិលផងដែរ គឺវិស័យអប់រំ កសិកម្ម សុខាភិបាល សុខុមាលភាពកុមារ ពិការភាព ការអភិវឌ្ឍន៍សហគមន៍ និងបរិស្ថាន។ ក្នុង




**រូបទី២៣ អ្នកទទួលផលចំបងពីអង្គការសង្គមស៊ីវិល (n=271)**

ចំណោមជម្រើសទាំង១៥ ដែលមានក្នុងកម្រងសំណួរ ក្រុមអ្នកទទួលផលដែលត្រូវបានផ្តោតគោលដៅតិចបំផុត គឺជនរងគ្រោះដោយសារការជួញដូរមនុស្ស ដែលមានអង្គការសង្គមស៊ីវិលដែលបានចូលរួមឆ្លើយតែមួយគត់ ដែលផ្តោតគោលដៅជាចម្បងលើក្រុមនេះ។

សំណាកអង្គការសង្គមស៊ីវិល បានរាយការណ៍ពីការជួយប្រជាជនប្រហែល ១២ លាននាក់ តាមរយៈការអនុវត្តន៍គម្រោងការងារក្នុងប្រទេសកម្ពុជា (សូមមើលតារាងទី២៣)។ ចំនួននេះ រួមបញ្ចូលទាំងអ្នកទទួលផលផ្ទាល់ និងអ្នកទទួលផលប្រយោល និងតំណាងឲ្យចំនួនប្រជាជនក្នុងប្រទេសកម្ពុជាស្ទើរទូទាំងប្រទេសដែលបង្ហាញថាអ្នកទទួលផលមួយចំនួនទំនងជាត្រូវបានរាប់លើសពីម្តង។

**តារាងទី២៣ ចំនួនអ្នកទទួលផលទៅតាមប្រភេទ**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| **សរុបអ្នកទទួលផល** | **57,595** | **1,003** | **12,555,673** | **218** |
| អ្នកទទួលផលដោយផ្ទាល់ | 38,546 | 416 | 8,171,698 | 212 |
| អ្នកទទួលផលដោយប្រយោល | 26,409 | 625 | 4,383,975 | 166 |

ការព្យាយាមគណនាចំនួនអ្នកទទួលផលឲ្យបានត្រឹមត្រូវ គឺជាការពិបាកមួយដែលអាចច្រឡំ និងគណនាខុស។ សម្រាប់គម្រោងជាច្រើន ការលំបាក ក្នុងការតាមដានចំនួន និងលក្ខណៈរបស់អ្នកទទួលផលពិតប្រាកដ ជាពិសេសពាក់ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាល ដែលចំណេះដឹងផ្តល់ឲ្យដោយអង្គការសង្គមស៊ីវិលដល់បុគ្គលម្នាក់ អាចត្រូវបានផ្សព្វផ្សាយដល់ភូមិទាំងមូល។ លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការប្រាស្រ័យទាក់ទងដើម្បីឲ្យមានការផ្លាស់ប្តូរឥរិយាបថ (ដូចជាយុទ្ធនាការបុរសល្អថ្មីៗនេះ ធ្វើឡើងដោយអង្គការអន្តរជាតិ Paz y Desarrollo និងយុទ្ធនាការរួមភេទដោយសុវត្ថិភាព ដែលធ្វើឡើងដោយអង្គការ PSI) អាចទៅដល់ប្រជាជនរាប់លាននាក់ និងប្រហែលទៅដល់ប្រជាជនទូទាំងប្រទេស។ ដោយ ១៦,២%នៃអង្គការសង្គមស៊ីវិលផ្តោតគោលដៅលើប្រជាជនទូទៅក្នុងប្រទេសកម្ពុជា ចំនួនអ្នកទទួលផលមួយចំនួន ប្រហែលជាត្រូវបានរាប់ ដោយគិតទាំងក្រុមគោលដៅ និងផ្នែកតាមតំបន់។ ក្នុងស្ថានភាពនេះ ចំនួនមេដ្យាននៃអ្នកទទួលផល ១០០៣ នាក់ សម្រាប់អង្គការសង្គមស៊ីវិលនីមួយៗ អាចជាការប៉ាន់ប្រមាណទាប អំពីចំនួនប្រជាជនដែលត្រូវបានជួយដោយផ្ទាល់ ដោយអង្គការសង្គមស៊ីវិលនីមួយៗ ក្នុងប្រទេសកម្ពុជា។ ដើម្បីប៉ាន់ប្រមាណចេញពីជាមេដ្យាន អង្គការសង្គមស៊ីវិលបើកដំណើរការក្នុងប្រទេសកម្ពុជា បានផ្តល់ជំនួយដល់អ្នកទទួលផលប្រហែល ១.៣០០.០០០ នាក់ ក្នុងឆ្នាំ២០១២។ ប៉ុន្តែ ចំនួននេះ ទំនងជាមិនរាប់បញ្ចូលអន្តរាគមន៍ទ្រង់ទ្រាយធំ និងយុទ្ធនាការរបស់ប្រព័ន្ធផ្សព្វផ្សាយឡើយ។ ចំនួនអ្នកទទួលផលពិតប្រាកដ អាចនឹងខ្ពស់ជាងនេះច្រើន។

# ការសម្របសម្រួល និងសហប្រតិបត្តិការ

## សហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល

សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល គឺមានអត្ថប្រយោជន៍ សម្រាប់អង្គការសង្គមស៊ីវិលទាំងអស់ ហើយវាមានប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍កម្ពុជាទាំងមូល។ សហប្រតិបត្តិការនេះ អាចជាមធ្យោបាយសំខាន់មួយ ដើម្បីធ្វើឲ្យការអនុវត្តន៍គម្រោងមានភាពប្រសើរឡើង កសាងសមត្ថភាពបុគ្គលិក ព្រមទាំងលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីបញ្ហានៃវិស័យនីមួយៗ ដែលជាប់ពាក់ព័ន្ធនឹងគម្រោង អ្នកពាក់ព័ន្ធ និងអ្នកទទួលផលរបស់អង្គការសង្គមស៊ីវិល។

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការសិក្សានេះ មាន ៥៣,១% បានរាយការណ៍ថា ពួកគេមានផែនការយ៉ាងតិចមួយ ជាមួយអង្គការសង្គមស៊ីវិល ឬអង្គការនៅតាមសហគមន៍ផ្សេងទៀត។ ក្នុងចំណោមផែនការទាំងនេះ មាន ២២,៥% (៦១ អង្គការ) មានទាំងកិច្ចព្រមព្រៀងផ្លូវការ ជាមួយអង្គការសង្គមស៊ីវិលដទៃទៀត និងកិច្ចព្រមព្រៀងក្រៅផ្លូវការ ជាមួយអង្គការនៅតាមសហគមន៍។ ១៩,២% (៥២អង្គការ) មានកិច្ចសន្យា ឬអនុស្សរណៈយោគយល់ផ្លូវការយ៉ាងហោចណាស់មួយ ជាមួយនឹងអង្គការដែលបានចុះបញ្ជីផ្សេងទៀត ក្នុងប្រទេសកម្ពុជា និង ១១,៤% (៣១អង្គការ) មានផែនការក្រៅផ្លូវការយ៉ាងហោចណាស់មួយ ជាមួយអង្គការនៅតាមសហគមន៍ ដើម្បីអនុវត្តគម្រោង។ សរុបមក ចំនួនទាំងនេះបង្ហាញពីសហប្រតិបត្តិការ និងការសម្របសម្រួលកើនឡើង ក្នុងចំណោមអង្គការសង្គមស៊ីវិល ហើយចំនួននៃការចុះអនុស្សរណៈយោគយល់ និងផែនការក្រៅផ្លូវការ ក្នុងចំណោមអង្គការសង្គមស៊ីវិល និងអង្គការនៅតាមសហគមន៍ ត្រូវបានរំពឹងថានឹងកើនឡើងនាពេលអនាគត ។




**រូបទី២៤ របាយកិច្ចព្រមព្រៀងផ្លូវការ និងក្រៅផ្លូវការក្នុងចំណោមអង្គការសង្គមស៊ីវិលតាមប្រភេទ**

**តារាងទី២៤ កិច្ចព្រមព្រៀងរបស់អង្គការសង្គមស៊ីវិល ទៅតាមប្រភេទ**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| ចំនួនអង្គការសង្គមស៊ីវិលមានកិច្ចសន្យាផ្លូវការ | 7.5 | 2 | 830 | 110 |
| ចំនួនអង្គការតាមសហគមន៍មានកិច្ចព្រមព្រៀងក្រៅផ្លូវការ | 43.3 | 4 | 3684 | 85 |

## ការចូលរួមក្នុងបណ្តាញអង្គការសង្គមស៊ីវិល

បណ្តាញ ត្រូវបានទទួលស្គាល់ថាជាមធ្យោបាយមានប្រសិទ្ធភាពមួយ សម្រាប់ចំនួនអង្គការសង្គមស៊ីវិលដែលកើនឡើង សម្រាប់ចែករំលែកព័ត៌មាន ដំណោះស្រាយ និងការប្រតិបត្តិល្អៗបំផុត ព្រមទាំងផ្សព្វផ្សាយចំណេះដឹងអំពីតម្រូវការសហគមន៍ ក្នុងគោលបំណងដើម្បីបង្កើតឲ្យមានឥទ្ធិពលអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ក្នុងការអង្កេត ឆ្នាំ២០១២នេះ ៦៩% នៃអ្នកផ្តល់ចម្លើយបានរាយការណ៍ថា បានចូលរួមជាមួយបណ្តាញយ៉ាងហោចណាស់មួយនៅកម្ពុជា ឬនៅបរទេស។ អង្គការ សរុបចំនួន ៩៩ (៣៦,៥%) បានចូលរួមតែជាមួយអង្គការសង្គមស៊ីវិល/បណ្តាញអង្គការ ក្នុងស្រុកប៉ុណ្ណោះ។ ក្នុងចំណោមអង្គការ ៤៦,៣% នៃសមាគមមិនបានចូលរួមក្នុងបណ្តាញណាមួយទេ ដែលមានសមាមាត្រខ្ពស់ជាង ទាំងអង្គការក្នុងស្រុក

និងអន្តរជាតិ (សូមមើលរូបទី២៥)។ បណ្តាញសំខាន់បំផុតចំនួនបួននៃអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា គឺគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) និងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC)។ ការចូលរួមជាមួយសកម្មភាពបណ្តាញនៅបរទេស គឺមានភាពចម្រុះជាង។




**រូបទី២៥ ការចូលរួមក្នុងបណ្តាញអង្គការសង្គមស៊ីវិលតាមប្រភេទអង្គការ**

**តារាងទី២៥ ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងបណ្តាញអង្គការនៅកម្ពុជា (ចម្លើយលើសពីមួយ)**

| | ចំនួន | ភាគរយ (n=178) |
|---|---|---|
| គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) | 74 | 41.6 |
| វេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) | 41 | 23.0 |
| ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) | 26 | 14.6 |
| យេនឌ័រ និងការអភិវឌ្ឍន៍ កម្ពុជា (GADC/GAD Network) | 22 | 12.4 |
| មេឌីខាំ (MEDiCAM) | 20 | 11.2 |
| សម្ព័ន្ធភាពអង្គការក្រៅរដ្ឋាភិបាលដើម្បី ទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ | 15 | 8.4 |

| | | |
|---|---|---|
| (COSECAM) | | |
| គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលស្តីពី សិទ្ធិកុមារ (NGO-CRC) | 14 | 7.9 |
| គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការសមាគម ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) | 13 | 7.3 |
| បញ្ចប់ពេស្យាចារ រំលោភបំពាន និងការជួញដូរ កុមារនៅកម្ពុជា (ECPAT Cambodia) | 8 | 4.5 |
| គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយ សេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) | 6 | 3.4 |

## ការផ្តល់មូលនិធិរបស់អង្គការសង្គមស៊ីវិលដល់អង្គការសង្គមស៊ីវិលដទៃទៀត

អង្គការសង្គមស៊ីវិល ត្រូវបានសួរថា តើពួកគេបានផ្តល់ជំនួយ ឬអំណោយដល់អង្គការសង្គមស៊ីវិលដទៃទៀត ឬអត់ ដោយសារតែនេះអាចជាមធ្យោបាយមួយទៀត ក្នុងការវាស់វែងសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល និងស្វែងយល់ពីហិរញ្ញវត្ថុរបស់អង្គការឲ្យកាន់តែប្រសើរ។ ២៨% (៧៦អង្គការ) នៃអង្គការទាំងអស់ បានរាយការណ៍ថា ពួកគេបានផ្តល់នូវប្រភេទនៃការគាំទ្រមួយចំនួន ដល់អង្គការដទៃទៀត អង្គការនៅតាមសហគមន៍ និង/ឬរាជរដ្ឋាភិបាល ក្នុងឆ្នាំ២០១២។ ចំនួននេះ គឺស្របគ្នាជាមួយនឹងអង្គការសង្គមស៊ីវិល ២៩% ក្នុងជំរឿននេះ ដែលបានគាំទ្រអង្គការដទៃទៀត ។

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានផ្តល់មូលនិធិ ជិតពាក់កណ្តាល (៤៨,៧% ស្មើនឹង៣៧អង្គការ) បានមានប្រសាសន៍ថា ពួកគេបានផ្តល់ជំនួយ ដល់រាជរដ្ឋាភិបាល ខណៈដែលចំនួនអង្គការ តិចតួចបំផុត (២១,១% ស្មើនឹង១៦អង្គការ) បានមានប្រសាសន៍ថា ពួកគេបានផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់អង្គការ អន្តរជាតិ។ វាជារឿងគួរឲ្យចាប់អារម្មណ៍ ដោយកត់សម្គាល់ឃើញថា មានអង្គការក្នុងស្រុក ដែលបានរាយការណ៍ពីការផ្តល់ជំនួយ ឬអំណោយដល់អង្គការ អន្តរជាតិ ក្នុងឆ្នាំ២០១២ ដោយសារតែចំណុចនេះ វាផ្ទុយនឹងទំនាក់ទំនងដែលគេយល់ដឹងជាទូទៅ រវាងអង្គការសង្គមស៊ីវិល (មានន័យថា មូលនិធិ គឺហូរចេញពីអង្គការ អន្តរជាតិ ទៅកាន់អង្គការ/សមាគមក្នុងស្រុក) ។




**រូបទី២៦ របាយអង្គការសង្គមស៊ីវិលក្នុងការផ្តល់ជំនួយ និងមូលនិធិ ( n=76 ចម្លើយលើសពីមួយ)**

អង្គការដែលបានផ្តល់ចម្លើយបានរាយការណ៍អំពីចំនួនជំនួយ និងអំណោយសរុបដែលបានផ្តល់ក្នុងឆ្នាំ២០១២ គឺ ១០.០៧៥.២៨៥ ដុល្លារអាមេរិក (សូមមើលតារាងទី២៦) គិតជាមធ្យម គឺ ១៧០.០០០ ដុល្លារអាមេរិក ក្នុងមួយអង្គការសង្គមស៊ីវិល។ បើយើងគិតថា តិចជាងមួយភាគបីនៃអង្គការសង្គមស៊ីវិល បានផ្តល់មូលនិធិ ដល់អង្គការសង្គមស៊ីវិលដទៃទៀត នោះវាទំនងជាមានអង្គការ ប្រហែល ៣១៦ ដែលបានផ្តល់មូលនិធិក្នុងឆ្នាំ២០១២ (ពីចំនួនសរុបនៃអង្គការសង្គមស៊ីវិលបើកដំណើរការ ដែលទទួលបានមូលនិធិ)។ បើប៉ាន់ប្រមាណចេញពីមធ្យមភាគ អង្គការសង្គមស៊ីវិលទាំងនេះ បានផ្តល់មូលនិធិប្រហែល ៥៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២។

**តារាងទី២៦ មូលនិធិ និងអំណោយដែលផ្តល់ដោយប្រភេទអង្គការសង្គមស៊ីវិល (ដុល្លារអាមេរិក)**

| | មធ្យម | មេដ្យាន | សរុប | n |
|---|---|---|---|---|
| **សរុបមូលនិធិ** | **170,768** | **7,000** | **10,075,285** | **59** |
| ចំនួនមូលនិធិផ្តល់ទៅអង្គការអន្តរជាតិ | 168,358 | 12,500 | 2,188,650 | 13 |
| ចំនួនមូលនិធិផ្តល់ទៅរាជរដ្ឋាភិបាល | 74,423 | 2,500 | 2,158,265 | 29 |
| ចំនួនមូលនិធិផ្តល់ទៅអង្គការក្នុងស្រុក | 184,289 | 14,000 | 3,501,490 | 19 |
| ចំនួនមូលនិធិផ្តល់ទៅអង្គការមូលដ្ឋាន | 106,042 | 4,500 | 2,226,880 | 21 |

ទោះបីជាមានការពិភាក្សាច្រើន អំពីចំនួនមូលនិធិអង្គការសង្គមស៊ីវិលដែលអាចត្រូវបានគណនាទ្វេដងក៏ដោយ ប៉ុន្តែលទ្ធផលនៃការអង្កេតនេះ បង្ហាញថា ក្នុងចំណោមអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ចំនួនមូលនិធិពិតប្រាកដដែលបានមកពីអង្គការសង្គមស៊ីវិលមួយទៀត គឺទំនងជាតិចជាង១០% នៃថវិកាប៉ាន់ប្រមាណសរុប សម្រាប់វិស័យនេះ (សូមមើលទំព័រទី៦០)។ អង្គការសង្គមស៊ីវិល អាចនឹងកំពុងទទួលមូលនិធិពីអង្គការអន្តរជាតិ ដែលមិនស្ថិតនៅ ឬមិនបានចុះបញ្ជីក្នុងប្រទេសកម្ពុជា ឬអាចនឹងមានអង្គការអន្តរជាតិធំៗតិចតួច ដែលផ្តល់មូលនិធិយ៉ាងច្រើន ក្នុងវិស័យនេះ ដែលអង្គការទាំងនេះ មិនបានចូលរួមក្នុងការសិក្សានេះ ដូចដែលរូបទី១៦ខាងលើ (ប្រភពនៃមូលនិធិរបស់អង្គការសង្គមស៊ីវិល) បញ្ជាក់ថា ជាង៩០% នៃមូលនិធិរបស់អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវបានផ្តល់ឲ្យដោយអង្គការអន្តរជាតិ។

# អភិបាលកិច្ច

## ស្វ័យអភិបាលកិច្ចរបស់អង្គការសង្គមស៊ីវិល

ដោយសារតែអង្គការសង្គមស៊ីវិល ត្រូវបានកំណត់ថាជាអង្គការស្ថិតនៅក្រៅព្រំដែននៃស្ថាប័នដទៃទៀត ដូចជារាជរដ្ឋាភិបាល និងអាជីវកម្ម ដូច្នេះពួកគេស្ថិតនៅក្រោមវិធាន និងបទបញ្ញាផ្ទាល់ខ្លួន។ លើសពីនេះទៅទៀត គោលដៅមិនស្វែងរកកម្រៃ និងដើម្បីជួយមនុស្សគ្រប់គ្នា ជាញឹកញាប់ធ្វើឲ្យសកម្មភាព មើលទៅប្រកប ដោយគុណធម៌។ អង្គការសង្គមស៊ីវិលដែលត្រូវបានរិះគន់ ចំពោះកង្វះតម្លាភាព និងគណនេយ្យភាព ថ្មីៗនេះមានចលនាជាច្រើនក្នុងសហគមន៍អភិវឌ្ឍន៍ ដើម្បីដាក់ឲ្យប្រើប្រាស់យន្តការតាមដាន និងបទបញ្ញាតឹងរ៉ឹង ក្នុងវិស័យអង្គការសង្គមស៊ីវិលនេះ។

ក្នុងបរិបទនេះ វាមានសារសំខាន់ក្នុងការស្វែងយល់ពីកម្រិតនៃអភិបាលកិច្ច និងបទបញ្ញា ដែលអង្គការសង្គមស៊ីវិលកម្ពុជា កំពុងអនុវត្ត។ ចំណុចជាច្រើនក្នុងចំណោមចំណុចទាំងនេះ ដូចជាធម្មនុញ្ញរបស់អង្គការ និងក្រុមប្រឹក្សាភិបាល អាចនឹងត្រូវបានធ្វើឡើងដោយឯករាជ្យ ឬជាផ្នែកមួយនៃតម្រូវការចុះបញ្ជី សម្រាប់ប្រទេសក្រៅ។ ទម្រង់ដទៃទៀតនៃអភិបាលកិច្ច (ឧទាហរណ៍ សវនកម្មផ្ទៃក្រៅ និងការបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ) អាចនឹងត្រូវបានធ្វើឡើង តាមសំណើរបស់ម្ចាស់ជំនួយ ឬ ដើម្បីបង្ហាញតម្លាភាពដល់អ្នកពាក់ព័ន្ធរបស់អង្គការ។

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការអង្កេតឆ្នាំ២០១២នេះ មាន ៩៥,៩% បានប្រតិបត្តិយ៉ាងហោចណាស់ទម្រង់មួយក្នុងចំណោមទម្រង់ជាច្រើននៃអភិបាលកិច្ចដែលមានរាយឈ្មោះក្នុងបញ្ជីសំណួរ ដោយអង្គការភាគច្រើន បានអនុវត្តវិធានការទាំងអស់ដែលមានក្នុងកម្រងសំណួរ។ ទម្រង់អភិបាលកិច្ចដែលត្រូវបានប្រើប្រាស់ជាទូទៅ គឺ ធម្មនុញ្ញលក្ខន្តិកៈ ឬបទបញ្ញាផ្ទៃក្នុងជាលាយលក្ខណ៍អក្សរ ដែល ៩៥,៩%នៃអង្គការសង្គមស៊ីវិល មានឯកសារទាំងនេះ។ ទម្រង់នៃអភិបាលកិច្ចដែលមានតិចតួចបំផុត គឺសវនកម្មផ្ទៃក្រៅ ប៉ុន្តែទម្រង់អភិបាលកិច្ចនេះ ត្រូវបានអនុវត្តដោយអង្គការសង្គមស៊ីវិលដែលចូលរួមឆ្លើយទាំងអស់ ជាងពាក់កណ្តាល (៥២%)។ នៅពេលសួរថា តើពួកគេអាចបង្ហាញធម្មនុញ្ញ និងរបាយការណ៍ជាលាយលក្ខណ៍អក្សរដទៃទៀត បានដែរឬទេ មាន ៥៦,៨% អាចបង្ហាញក្រុមអង្កេត អំពីបទបញ្ញាផ្ទៃក្នុងនិងធម្មនុញ្ញ ខណៈដែលប្រហែលជា៤០% បានបង្ហាញរបាយការណ៍ដទៃទៀត រួមមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។




**រូបទី២៧ របាយវាស់វែងអំពីអភិបាលកិច្ចអង្គការសង្គមស៊ីវិល (n=271)**

ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលបានរាយការណ៍អំពីការធ្វើសវនកម្មផ្ទៃក្រៅ មាន ៥១,៨% (៧៣អង្គការសង្គមស៊ីវិល) បានធ្វើទាំងសវនកម្មអង្គការ និងសវនកម្មគម្រោង ២៧% (៣៨ អង្គការសង្គមស៊ីវិល) មានតែសវនកម្មអង្គការ និង២១,៣% (៣០អង្គការសង្គមស៊ីវិល) មានតែសវនកម្មគម្រោង។ មូលហេតុភាគច្រើនបំផុតផ្តល់ដោយអង្គការសង្គមស៊ីវិលដែលមិនបានធ្វើសវនកម្មផ្ទៃក្រៅក្នុងឆ្នាំ២០១២ គឺកង្វះមូលនិធិ/ថវិកា ក្នុងការបង់ឲ្យសវនករឯករាជ្យ។ មូលហេតុដទៃទៀតក្នុងការមិនធ្វើសវនកម្មផ្ទៃក្រៅ គឺដោយសារតែម្ចាស់ជំនួយ មិនបានតម្រូវឲ្យធ្វើ និងដោយសារតែគម្រោងដែលបានអនុវត្ត មានរយៈពេលខ្លី (ប្រហែលជាថវិកា មិនមានចំនួនច្រើនល្មម សម្រាប់ការចំណាយលើសវនកម្មផ្ទៃក្រៅ ដោយអង្គការផ្ទាល់ ឬដោយម្ចាស់ជំនួយ)។

## អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនៃអង្គការមិនមែនរដ្ឋាភិបាល (NGO GPP)

ជាផ្នែកមួយនៃចលនាទូទាំងពិភពលោក ឆ្ពោះទៅកាន់ការកើនឡើងនូវស្វ័យគ្រប់គ្រង និងគណនេយ្យភាព ក្នុងសហគមន៍អង្គការសង្គមស៊ីវិល គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) បានបង្កើតប្រព័ន្ធមួយសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីបង្ហាញពីគណនេយ្យភាព និងការប្រតិបត្តិអភិបាលកិច្ចល្អ ក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈនៃអង្គការមិនមែនរដ្ឋាភិបាល (NGO GPP) ផ្តល់នូវក្រមនៃ

គោលការណ៍សីលធម៌ ព្រមទាំងស្តង់ដារអភិបាលកិច្ច និងគណនេយ្យភាព សម្រាប់អង្គការសង្គមស៊ីវិល ដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ សម្រាប់អង្គការសង្គមដែលអនុវត្ត និងប្រកាន់ខ្ជាប់នូវគោលការណ៍ និងស្តង់ដារទាំងនេះ NGO GPP ផ្តល់នូវវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្ត ដែលបង្ហាញថា អង្គការសង្គមស៊ីវិល បានបំពេញនូវស្តង់ដារអន្តរជាតិទាំងនេះ។ NGO GPP គឺជាឧបករណ៍សំខាន់មួយ សម្រាប់អង្គការសង្គមស៊ីវិល ក្នុងការពង្រឹងការប្រតិបត្តិស្វ័យអភិបាលកិច្ច និងរក្សានូវស្តង់ដារខ្ពស់ ដែលវិស័យនេះផ្អែកលើ។

ទោះបីជាប្រព័ន្ធវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្ត (NGO GPP) ទើបតែមានក្នុងឆ្នាំ២០០៧ ក៏ដោយ ប៉ុន្តែមាន ៣៩,១% (១០៦ អង្គការ) នៃអង្គការសង្គមស៊ីវិលទាំងអស់ក្នុងប្រទេសកម្ពុជា បានដឹងអំពីប្រព័ន្ធវិញ្ញាបនបត្រនេះ និង ៨,៥% (២៣អង្គការ) នៃអង្គការសង្គមស៊ីវិលដែលបានផ្តល់ចម្លើយបានទទួលវិញ្ញាបនបត្រ NGO GPP នេះ។ លើសពីនេះ អង្គការសង្គមស៊ីវិល ១៧,៧% ផ្សេងទៀត មានបំណងដាក់ពាក្យសុំវិញ្ញាបនបត្រនេះ នាពេលអនាគត ដែលនេះបង្ហាញពីជោគជ័យរបស់កម្មវិធី NGO GPP និងការបន្តប្តេជ្ញាចិត្តរបស់អង្គការសង្គមស៊ីវិល ឆ្ពោះទៅរកការខិតខំប្រឹងប្រែងស្វ័យគ្រប់គ្រង និងការតាមដានបន្ថែមទៀត។




**រូបទី២៨ ការចូលរួមរបស់អង្គការសង្គមស៊ីវិលលើប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត (n=271)**

## សហប្រតិបត្តិការនាពេលអនាគត

សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិលនៅកម្ពុជា គឺមានសារប្រយោជន៍ចំពោះការអភិវឌ្ឍន៍ប្រទេសទាំងមូល។ នេះអាចលើកកម្ពស់ប្រសិទ្ធភាពរបស់វិស័យទាំងមូល ក្នុងការកំណត់គោលដៅសកម្មភាព និងអ្នកទទួលផល ការអនុវត្តន៍គម្រោង និងការប្រមូលផ្តុំធនធាន។ អ្នកផ្តល់ចម្លើយបានផ្តល់នូវសេចក្តីថ្លែងការណ៍ជាក់លាក់ អំពីសេណារីយ៉ូចំនួនបី សម្រាប់គម្រោងសហប្រតិបត្តិការនាពេលអនាគត ហើយបន្ទាប់មក សាកសួរអំពីការយល់ឃើញ ថាតើពួកគេយល់ព្រម ឬមិនយល់ព្រម។ ផ្នែកនេះ វាស់វែងអំពីឆន្ទៈនិងទស្សនៈរបស់អង្គការសង្គមស៊ីវិល សម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគត។

សេណារីយ៉ូទីមួយ ពិភាក្សាអំពីការបង្កើតមជ្ឈមណ្ឌលអង្គការសង្គមស៊ីវិល អាចជាមជ្ឈមណ្ឌលតែមួយក្នុងរាជធានីភ្នំពេញ ឬមជ្ឈមណ្ឌលនៅតាមខេត្ត ដែលអង្គការសង្គមស៊ីវិលទាំងអស់ អាចប្រមូលផ្តុំគ្នា និងសហប្រតិបត្តិការជាមួយគ្នា។ ជាង ៨០% នៃអ្នកចូលរួមឆ្លើយមានទស្សនៈវិជ្ជមានអំពីគំនិតយោបល់នេះ ហើយគាំទ្រឲ្យមានការបង្កើតមជ្ឈមណ្ឌលអង្គការសង្គមស៊ីវិលនេះឡើង (សូមមើលរូបទី២៩)។ ក្នុងចំណោមអ្នកផ្តល់ចម្លើយ ដែលបានគាំទ្រគំនិតនេះ បានយល់ស្របថា មជ្ឈមណ្ឌលអង្គការសង្គមស៊ីវិលថ្នាក់កណ្តាល នឹងលើកកម្ពស់ការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការ ក្នុងចំណោមអង្គការសង្គមស៊ីវិល ដែលមានប្រហែលជា ៧០% បានមានប្រសាសន៍ថា សហប្រតិបត្តិការនេះ នឹងជួយសន្សំសំចៃថវិកា ព្រមទាំងធ្វើឲ្យការងាររបស់ពួកគេ កាន់តែមានប្រសិទ្ធភាព។




រូបទី២៩ ទស្សនៈស្តីពីការបង្កើតមជ្ឈមណ្ឌលអង្គការសង្គមស៊ីវិល (n=271)

សេណារីយ៉ូទីពីរ គឺការបង្កើត "មូលនិធិជាតិសម្រាប់អង្គការសង្គមស៊ីវិល" សម្រាប់មូលនិធិនេះ អង្គការសង្គមស៊ីវិល អាចដាក់សំណើសុំថវិកា ដើម្បីអនុវត្តសកម្មភាព និងគម្រោង។ ចុងក្រោយ មូលនិធិជាតិសម្រាប់អង្គការសង្គមស៊ីវិល នឹងក្លាយជាកន្លែងផ្ទុកមូលនិធិពីម្ចាស់ជំនួយ ដែលចង់គាំទ្រគម្រោងអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ដែលនេះជាវិធីមួយក្នុងការធ្វើឲ្យដំណើរការផ្តល់មូលនិធិ កាន់តែមានប្រសិទ្ធភាព សម្រាប់ភាគីទាំងអស់។ គំនិតនេះទទួលបានការគាំទ្រមិនសូវច្រើនទេ ក្នុងចំណោមអ្នកផ្តល់ចម្លើយដោយសារតែពួកគេ មានការព្រួយបារម្ភថា ការបង្កើតមូលនិធិជាតិសម្រាប់អង្គការសង្គមស៊ីវិល អាចនឹងបង្កើនការប្រកួតប្រជែង ក្នុងការទទួលបានមូលនិធិពីម្ចាស់ជំនួយ ប្រសិនបើអង្គការសង្គមស៊ីវិលទាំងអស់មានច្រកទទួលមូលនិធិតែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកចូលរួមឆ្លើយភាគច្រើន បានយល់ស្របជាមួយសេចក្តីថ្លែងការណ៍ទាំងបី អំពីឥទ្ធិពលវិជ្ជមានរបស់មូលនិធិជាតិនេះ ហើយ ៦១,៦% យល់ឃើញថា មូលនិធិអាចនឹងត្រូវបានកំណត់គោលដៅកាន់តែប្រសើរ ដើម្បីបំពេញតម្រូវការរបស់សហគមន៍កម្ពុជា (រូបទី៣០)។




រូបទី៣០ ទស្សនៈស្តីពីផលទទួលបានពីមូលនិធិជាតិសម្រាប់អង្គការសង្គមស៊ីវិល (n=271)

សេណារីយ៉ូទីបី គឺការបង្កើតឲ្យមានការសិក្សាទាក់ទងនឹងអង្គការសង្គមស៊ីវិល នៅសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិលភាគច្រើន (៥១,៣%) ជឿជាក់ថា និស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យបច្ចុប្បន្ន ខ្វះខាតជំនាញសមស្រប ដើម្បីធ្វើការងារក្នុងវិស័យអង្គការសង្គមស៊ីវិល (រូបទី៣១)។ ដោយសារតែអង្គការសង្គមស៊ីវិល គឺជាអ្នកចូលរួមចំណែកសំខាន់ ដល់ការងារផ្សេងៗនៅកម្ពុជា សកម្មភាពនេះ អាចនឹងផ្តល់អត្ថប្រយោជន៍ដល់ទាំងអង្គការសង្គមស៊ីវិល និងនិស្សិតបញ្ចប់ការសិក្សា ប្រសិនបើពួកគេ ត្រៀមខ្លួនបានល្អ

ដើម្បីចូលទីផ្សារការងារ និងចង់ឲ្យការងារកាន់តែមានប្រសិទ្ធភាព។ អ្នកផ្តល់ចម្លើយនៃអង្គការសង្គមស៊ីវិល មានគំនិតវិជ្ជមានយ៉ាងខ្លាំង ទាក់ទងនឹងសេណារីយ៉ូនេះ ដោយ ៩៤,១% គាំទ្រឲ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើការងារជាមួយសាកលវិទ្យាល័យ ដើម្បីបង្កើតជំនាញ ដែលតម្រូវឲ្យមាន ដើម្បីធ្វើការងារក្នុងវិស័យអង្គការសង្គមស៊ីវិលនេះ។ លើសពីនេះទៅទៀត ៩០,៨% បានព្រមព្រៀងថា ប្រជាជនកម្ពុជា នឹងទទួលអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមនេះ ដោយសារតែប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិល មានឥទ្ធិពលដោយផ្ទាល់លើជីវិតរបស់អ្នកទទួលផល។




**រូបទី៣១ ទស្សនៈក្នុងការបង្កើតអង្គការសង្គមស៊ីវិល-ទាក់ទងនឹងជំនាញនៅសាកលវិទ្យាល័យ (n=271)**

ចម្លើយចំពោះសេណារីយ៉ូទាំងបីនេះ សម្រាប់សហប្រតិបត្តិការនាពេលអនាគត គឺមានភាពវិជ្ជមានយ៉ាងច្រើន ដោយនាយកអង្គការសង្គមស៊ីវិល ចង់ធ្វើការងាររួមគ្នាយ៉ាងខ្លាំង ដើម្បីលើកកម្ពស់វិស័យនេះ។ វាគឺជាក្តីសង្ឃឹមរបស់អង្គការ CCC ដែលគំនិតវិជ្ជមានទាំងនេះ នឹងផ្តល់នូវលទ្ធផលដែលមានសារប្រយោជន៍ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ពីព្រោះវិស័យនេះ បន្តដាក់ឲ្យប្រើប្រាស់គំនិតថ្មីៗ និងលើកកម្ពស់ការអនុវត្តន៍សេណារីយ៉ូមួយចំនួនក្នុងចំណោមសេណារីយ៉ូទាំងនេះ។

# អនុសាសន៍របស់អង្គការសង្គមស៊ីវិល

ផ្នែកនេះ ផ្តោតលើលទ្ធផលនៃសម្ភាសន៍បែបគុណភាព ដែលត្រូវបានធ្វើឡើងជាមួយនាយកអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ ទាក់ទងនឹងទស្សនៈអំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍ទាំងមូលរបស់ប្រទេសកម្ពុជា និងទាក់ទងនឹងអនុសាសន៍ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល។

## *ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍន៍*

### ការកំណត់គោលដៅ

ធាតុផ្សំដ៏សំខាន់មួយក្នុងការអនុវត្តន៍គម្រោងឲ្យមានប្រសិទ្ធភាព គឺការកំណត់គោលដៅ។ ម្ចាស់ជំនួយភាគច្រើន តម្រូវឲ្យអង្គការសង្គមស៊ីវិល កំណត់គោលដៅសកម្មភាព និងអ្នកទទួលផលរបស់ពួកគេ ឲ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព ដើម្បីរួមចំណែក ដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ វាជារឿងគួរឲ្យលើកទឹកចិត្ត ដែលអង្គការមួយចំនួន កំពុងប្រើប្រាស់ទិន្នន័យដែលអាចរកបាន (ពីរាជរដ្ឋាភិបាល និងទីភ្នាក់ងារដទៃទៀត) ដើម្បីជះឥទ្ធិពលលើសេចក្តីសម្រេចរបស់ពួកគេ អំពីទីតាំងដែលត្រូវអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាព។ អង្គការសង្គមស៊ីវិលមួយ បាននិយាយថា ពួកគេប្រើប្រាស់របាយការណ៍របស់ក្រសួងផែនការដើម្បីជ្រើសរើសទីតាំងអនុវត្តគម្រោង។

### ការចូលរួមចំណែកដល់ការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា

ចំណាប់អារម្មណ៍ជាទូទៅ អំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា គឺមានភាពវិជ្ជមាន ក្នុងចំណោមអ្នកដែលត្រូវបានធ្វើសម្ភាសន៍។ ពួកគេបាននិយាយថា បច្ចុប្បន្ននេះ ប្រជាជន មានឱកាសច្រើនជាងមុន ក្នុងការលើកកម្ពស់ជីវភាព ដោយមានហេដ្ឋារចនាសម្ព័ន្ធប្រសើរឡើង (ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ។ល។) បច្ចេកវិទ្យា (បច្ចេកវិទ្យាព័ត៌មាន ឬគមនាគមន៍) និងការងារអង្គការសង្គមស៊ីវិលក្នុងវិស័យសុខាភិបាល អប់រំ ទឹក និងអនាម័យ។ ទីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល បានឆ្លើយថា វិស័យនេះ បានចូលរួមចំណែកគួរឲ្យកត់សម្គាល់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ពួកគេជឿជាក់ថា ភាពប្រសើរឡើងទាំងនេះ សម្រេចបាន តាមរយៈសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល សហគ្រាសឯកជន និងរាជរដ្ឋាភិបាល។

អង្គការសង្គមស៊ីវិល សង្ឃឹមថានឹងបន្តធ្វើដំណើរទៅមុខ ដើម្បីលើកកម្ពស់ជីវិតរបស់ប្រជាជនកម្ពុជា តាមរយៈការអនុវត្តន៍គម្រោងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងការកើនឡើងនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ពួកគេក៏សង្ឃឹមផងដែរថា អំពើពុករលួយ នឹងថយចុះ ហើយការអភិវឌ្ឍន៍ នឹងកើតឡើងលើគ្រប់វិស័យ។

## បញ្ហាប្រឈម

ការសម្រេចបានគោលដៅអភិវឌ្ឍន៍ មិនមែនជារឿងងាយស្រួលសម្រាប់ប្រទេសកម្ពុជាឡើយ ដោយសារតែក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត មានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។ អង្គការសង្គមស៊ីវិលមួយ បានលើកឡើងកង្វល់អំពីស្ថានភាពបរិស្ថានដែលកាន់តែអាក្រក់ឡើង និងជឿជាក់ថា នេះគឺជាបញ្ហាប្រឈមមួយ ដែលប្រទេសកម្ពុជាត្រូវដោះស្រាយ ក្នុងប៉ុន្មានឆ្នាំក្រោយនេះ។ ការធ្វើឲ្យហិនហោចធនធានធម្មជាតិ អាកាសធាតុប្រែប្រួល និងការកើនឡើងនូវបរិយាកាសអាប់អួរ គឺស្ថិតក្នុងចំណោមបញ្ហាប្រឈមផ្នែកបរិស្ថាន ដែលប្រទេសកម្ពុជា ត្រូវដោះស្រាយ។ លើសពីនេះទៅទៀត អង្គការសង្គមស៊ីវិលដែលមានបេសកកម្មមួយចំនួន (ដូចជាក្នុងវិស័យសិទ្ធិមនុស្ស) អាចនឹងជួបប្រទះបញ្ហា ក្នុងការសហការជាមួយរាជរដ្ឋាភិបាល អាចនឹងមានភាពលំបាក ក្នុងការបំពេញការងាររបស់ពួកគេឲ្យមានប្រសិទ្ធភាព។

អង្គការសង្គមស៊ីវិល ក៏មើលឃើញពីកង្វះជំនាញសមស្របផងដែរ ពាក់ព័ន្ធនឹងកម្លាំងពលកម្ម ក្នុងចំណោមប្រជាជនកម្ពុជា។ នេះជាបញ្ហាប្រឈមមួយទៀត ដែលអាចពន្យឺត និងរារាំងការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ក្នុងការប្រកួតប្រជែងជាមួយប្រទេសសេដ្ឋកិច្ចអាស៊ានដទៃទៀត សម្រាប់ឱកាសវិនិយោគ។ អនុសាសន៍មួយដើម្បីជម្នះបញ្ហាប្រឈមទាំងនេះ គឺតាមរយៈការអប់រំប្រជាជន បណ្តុះបណ្តាលនូវជំនាញសមស្រប និងកសាងសមត្ថភាព ដើម្បីក្លាយជាកម្មករជំនាញដែលមានសមត្ថភាពប្រកួតប្រជែង។

# *ការលើកកម្ពស់ប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិល*

## ការផ្តល់មូលនិធិ

ក្នុងប្រទេសកម្ពុជា មូលនិធិអភិវឌ្ឍន៍ នៅតែទទួលសម្ពាធច្រើនពីម្ចាស់ជំនួយ។ ម្ចាស់ជំនួយ ចងភ្ជាប់ការផ្តល់មូលនិធិទៅនឹងសកម្មភាព ជាជាងការផ្តល់មូលនិធិជាកញ្ចប់ ពីព្រោះម្ចាស់ជំនួយ ចង់ឲ្យប្រាកដថា លុយនោះនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់គម្រោង និង

អ្នកទទួលផលដែលបានគ្រោងទុក ព្រមទាំងធានាថា បេសកកម្មទាំងមូលរបស់ម្ចាស់ជំនួយ ត្រូវបានអនុលោមតាម។ អង្គការសង្គមស៊ីវិលមួយចំនួន បានមានប្រសាសន៍ថា ម្ចាស់ជំនួយ អាចនឹងមិនទុកចិត្តសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការ ដូច្នេះហើយ ការផ្តល់មូលនិធិទៅលើគម្រោង គឺជាវិធីមួយ ក្នុងការរក្សាការគ្រប់គ្រងមូលនិធិឲ្យបានតឹងរ៉ឹង។

អង្គការសង្គមស៊ីវិលមួយចំនួន បានបង្ហាញថា មូលនិធិ អាចនឹងត្រូវបានផ្តោតគោលដៅប្រកបដោយប្រសិទ្ធភាព ប្រសិនបើមានអំពើពុករលួយតិចតួច (ក្នុងប្រទេសកម្ពុជាជាទូទៅ)។ ម្ចាស់ជំនួយ ចង់ឲ្យអង្គការសង្គមស៊ីវិល មានភាពច្បាស់លាស់អំពីគោលដៅរបស់ខ្លួន និងអ្វីដែលពួកគេចង់សម្រេចបាន និងប្រាកដថា ពួកគេអនុលោមទៅតាមនោះ។ លើសពីនេះទៅទៀត អង្គការសង្គមស៊ីវិល យល់ឃើញថា ម្ចាស់ជំនួយ គួរតែមានសកម្មភាពតាមដាន និងវាយតម្លៃដោយផ្ទាល់បន្ថែមទៀត ទៅលើគម្រោងដែលពួកគេផ្តល់មូលនិធិ។ អង្គការសង្គមស៊ីវិល ស្វាគមន៍ឲ្យមានការចូលរួមបន្ថែមពីម្ចាស់ជំនួយ ក្នុងសកម្មភាពរបស់ពួកគេ ដើម្បីក្លាយជាដៃគូសកម្មក្នុងដំណើរការនេះ ហើយពួកគេរីករាយក្នុងការធ្វើការងារជាមួយគ្នា ដើម្បីលើកកម្ពស់ការតាមដានគម្រោង។

## ការលើកកម្ពស់ប្រសិទ្ធភាព

កត្តាទាំងអស់ដែលអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ បានព្រមព្រៀងថានឹងជួយវិស័យនេះ ឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការសម្រេចបានគោលដៅរបស់ពួកគេ គឺការកើនឡើងនូវតម្លាភាព និងគណនេយ្យភាពក្នុងចំណោមអង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល ព្រមទាំងការសម្របគម្រោងរបស់អង្គការសង្គមស៊ីវិល ជាមួយនឹងគោលដៅផែនការយុទ្ធសាស្ត្រ។

# *សហប្រតិបត្តិការ*

## សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល

ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា មានភាពប្រសើរឡើង តាមអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ដែលត្រូវបានធ្វើសម្ភាសន៍។ សព្វថ្ងៃនេះ កាន់តែមានភាពងាយស្រួល ក្នុងការចែករំលែក និងទទួលបានព័ត៌មានអំពីសកម្មភាពគម្រោង មេរៀនទទួលបាន និងការប្រតិបត្តិល្អៗបំផុតក្នុងចំណោមអង្គការសង្គមស៊ីវិល ហើយនឹងជួយអង្គការសង្គមស៊ីវិល អនុវត្តគម្រោងផ្ទាល់ខ្លួនរបស់ពួកគេ ឲ្យមានប្រសិទ្ធភាព។ ទំនាក់ទំនងរវាង

អង្គការអន្តរជាតិ និងក្នុងស្រុក មានភាពប្រសើរឡើង ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយអង្គការអន្តរជាតិ ទទួលយកមតិយោបល់ច្រើន ពីអង្គការក្នុងស្រុក ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ហើយអង្គការក្នុងស្រុក មានសំឡេងកាន់តែខ្លាំងក្នុងវិស័យនេះ។ បច្ចេកវិទ្យាព័ត៌មាន និងសិក្ខាសាលា/សន្និសីទជាទៀងទាត់ ធ្វើឲ្យអង្គការសង្គមស៊ីវិល មានភាពកាន់តែងាយស្រួល ក្នុងការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការជាមួយគ្នា។

## សហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារអភិវឌ្ឍន៍

អង្គការសង្គមស៊ីវិលមួយ បានមើលឃើញពីបន្លាស់ប្តូរជាវិជ្ជមានមួយ ពាក់ព័ន្ធនឹងវិធីដែលម្ចាស់ជំនួយ ផ្តល់មូលនិធិ ដោយមានប្រសាសន៍ថា បច្ចុប្បន្ននេះ ម្ចាស់ជំនួយមួយចំនួនគាំទ្រអង្គការសង្គមស៊ីវិលតូចៗ ដើម្បីអនុវត្តគម្រោង នៅថ្នាក់មូលដ្ឋាន។ ការប្រាស្រ័យទាក់ទងគ្នារវាងទីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល កំពុងមានភាពប្រសើរឡើងផងដែរ។

បន្លាស់ប្តូរមួយក្នុងចំណោមបន្លាស់ប្តូរជាច្រើន ដែលអង្គការសង្គមស៊ីវិល បានផ្តល់ជាយោបល់ ដើម្បីលើកកម្ពស់សហប្រតិបត្តិការរវាងពួកគេ និងទីភ្នាក់ងារអភិវឌ្ឍន៍ គឺសហប្រតិបត្តិការជិតស្និទ្ធ ដែលទាំងទីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល អាចចែករំលែកព័ត៌មានគ្នាដោយងាយស្រួល។ ម្តងទៀត អង្គការសង្គមស៊ីវិល ស្វាគមន៍ការកើនឡើងនូវការចូលរួមរបស់ម្ចាស់ជំនួយ ក្នុងគម្រោងរបស់ពួកគេ ប៉ុន្តែត្រូវស្ថិតក្នុងស្មារតីនៃការគោរពគ្នាទៅវិញទៅមក និងភាពជាដៃគូ។

## សហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

មានភាពប្រសើរឡើង ក្នុងការចែករំលែកព័ត៌មានរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បើប្រៀបធៀបទៅនឹងអតីតកាល។ ភាពប្រសើរនេះ ដោយសារតែរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល សហការគ្នាក្នុងសិក្ខាសាលា និងសន្និសីទ ដើម្បីពិភាក្សាអំពីបញ្ហា និងការប្រឈមដែលត្រូវដោះស្រាយ ដើម្បីលើកម្ពស់ជីវភាពរបស់ប្រជាជនកម្ពុជា។ ទោះបីជាមានអង្គការសង្គមស៊ីវិលតិចតួច នៅតែជួបប្រទះភាពលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នា និងការចែករំលែកព័ត៌មានជាមួយរាជរដ្ឋាភិបាលក៏ដោយ ប៉ុន្តែពួកគេនៅតែជឿជាក់ថា បញ្ហានេះអាចនឹងមានភាពប្រសើរឡើង ប្រសិនបើភាគីទាំងពីរ មានការបើកចំហ និងមានឆន្ទៈក្នុងការធ្វើការងារជាមួយគ្នា។ អង្គការសង្គមស៊ីវិល ផ្តល់ជាយោបល់ថា រាជរដ្ឋាភិបាល គួរតែចែករំលែកព័ត៌មានបន្ថែមទៀត ទោះបីជាមួយអង្គការសង្គមស៊ីវិលតូចៗក៏ដោយ។ ចំណែកឯដៃគូអភិវឌ្ឍន៍វិញ ផ្តល់ជាយោបល់ថា អង្គការសង្គមស៊ីវិល គួរតែផ្តល់ព័ត៌មានបន្ថែមទៀត ដល់រាជរដ្ឋាភិបាល ជាពិសេសការសម្រេចបានរបស់គម្រោងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់

ការយល់ដឹងរបស់រាជរដ្ឋាភិបាល អំពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ជាតិ។ អង្គការមួយចំនួន ក៏ផ្តល់ជាយោបល់ផងដែរថា ពួកគេគួរតែបើកចំហាបន្ថែមទៀត ទទួលយកការរិះគន់ និងមានឆន្ទៈ ក្នុងការធ្វើឲ្យប្រសើរឡើង និងរៀនសូត្រពីកំហុសឆ្គងរបស់ខ្លួន។ ហើយរាជរដ្ឋាភិបាល ក៏គួរតែបើកចំហាបន្ថែមទៀតផងដែរ ទទួលស្គាល់ចំណុចខ្សោយ និងបញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិល ដោយមិនចាំបាច់ដាក់ទណ្ឌកម្ម និងជួយអង្គការសង្គមស៊ីវិល ឲ្យបានរៀនសូត្រ និងកែលម្អ នាពេលអនាគត។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

របកគំហើញចេញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ អំពីការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា មានឥទ្ធិពលសំខាន់មួយចំនួន សម្រាប់វិស័យអង្គការសង្គមស៊ីវិលទាំងមូល។ ទីមួយ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ បង្ហាញច្បាស់ថា អង្គការសង្គមស៊ីវិលបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។

ការប៉ាន់ប្រមាណដោយប្រុងប្រយ័ត្ន ចេញពីលទ្ធផលនៃការអង្កេតនេះ បង្ហាញថា អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា បានអនុវត្តគម្រោងប្រហែល ៤ ០០០ ក្នុងឆ្នាំ២០១២ ដែលគ្របដណ្តប់ទាំង២៤ខេត្ត/ក្រុងនៅកម្ពុជា។ ការប៉ាន់ប្រមាណប្រហាក់ប្រហែល ចេញពីទិន្នន័យស្រាវជ្រាវនេះ អំពីអ្នកទទួលផល បង្ហាញថា ក្នុងឆ្នាំ២០១២ អង្គការសង្គមស៊ីវិល បានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ដល់ជីវិតរបស់ប្រជាជនប្រហែល ១,៣ លាននាក់ នៅកម្ពុជា។ ទោះបីវាគឺជាការប៉ាន់ប្រមាណទាបក៏ដោយ ប៉ុន្តែចំនួននេះជិតស្មើនឹង ១០% នៃចំនួនប្រជាជនទូទាំងប្រទេស ហើយគឺជាតួលេខគួរឲ្យកត់សម្គាល់មួយ សម្រាប់វិស័យតូចៗនៃសេដ្ឋកិច្ចកម្ពុជា។

អង្គការសង្គមស៊ីវិល ផ្តល់ការងារដល់មនុស្សជាច្រើន ដែលធ្វើការក្នុងលក្ខខណ្ឌសមរម្យ និងទទួលបានប្រាក់បៀវត្សរ៍សមរម្យ ដែលចូលរួមចំណែកផងដែរ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូល។ អង្គការសង្គមស៊ីវិល ក៏ផ្តល់ឱកាសដល់មនុស្សជាច្រើន តាមរយៈការហាត់ការងារ និងការស្ម័គ្រចិត្ត ដែលអនុញ្ញាតឲ្យអ្នកទាំងនេះ ទទួលបានបទពិសោធន៍ដែលអាចជួយពួកគេ ក្នុងការស្វែងរកការងារទទួលបានបៀវត្សរ៍ នាពេលអនាគត។ ជារួម អង្គការសង្គមស៊ីវិល មានកំណត់ត្រាល្អ ជានិយោជកដែលផ្តល់ឱកាសស្មើភាពគ្នា។ អង្គការសង្គមស៊ីវិល ផ្តល់ការងារដល់បុគ្គលិកស្ត្រីជាង ៤២% ដែលនេះជាចំនួនល្អ បើប្រៀបធៀបជាមួយវិស័យការងារដទៃទៀត ហើយ ៣,២% នៃបុគ្គលិកអង្គការសង្គមស៊ីវិល គឺជាជនពិការ ដែលចំនួននេះ គឺជាចំនួនដ៏ល្អ បើប្រៀបធៀបជាមួយអត្រាពិការភាពនៃប្រជាជនទូទៅ (១,៤% វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩)។

**តារាងទី២៧ វិស័យសំខាន់ជាងគេទាំង៧ អ្នកទទួលផល និងក្រសួង (ការអង្កេត និងជំរឿនឆ្នាំ២០១២)**

| | វិស័យសកម្មភាពសំខាន់ៗ [1] | | អ្នកទទួលផលសំខាន់ៗ [1] | | កិច្ចព្រមព្រៀងសង្គមស៊ីវិល និង រាជរដ្ឋាភិបាល [2] | |
|---|---|---|---|---|---|---|
| | វិស័យគោលដៅ | n | ក្រុមគោលដៅ | n | ក្រសួង/មន្ទីរ | n |
| 1 | អប់រំ និងបណ្តុះបណ្តាល | 87 | កុមារ | 63 | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 172 |
| 2 | កសិកម្ម និង សុខភាពសត្វ | 26 | ប្រជាជនទូទៅ | 44 | អប់រំ យុវជន និងកីឡា | 143 |
| 3 | សុខភាព អាហាររូបត្ថម្ភ និង អេដស៍ | 26 | ប្រជាជនក្រីក្រ | 40 | សុខាភិបាល | 142 |
| 4 | សុខុមាលភាព និង សិទ្ធិកុមារ | 18 | ក្រុមស្ត្រី | 25 | កសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | 56 |
| 5 | អភិវឌ្ឍន៍សហគមន៍ | 14 | ក្រុមនិស្សិត/យុវជន | 20 | អភិវឌ្ឍជនបទ | 41 |
| 6 | ពិការភាព និង ស្តារនីតិសម្បទា | 12 | ជនពិការ | 13 | ការងារនិងបណ្តុះ បណ្តាលវិជ្ជាជីវៈ | 35 |
| 7 | បរិស្ថាន និងធនធាន ធម្មជាតិ | 11 | ក្រុមអ្នកជំនួញ | 13 | វប្បធម៌និងវិចិត្រសិល្បៈ | 28 |

[1] ប្រភព: ការអង្កេតអង្គការសង្គមស៊ីវិលឆ្នាំ២០១២

[2] ប្រភព: ការជំរឿនឆ្នាំ២០១២ ការចុះអនុស្សរណៈជាមួយក្រសួងមហាផ្ទៃនិងក្រសួងការបរទេសមិនបាន បញ្ចូលក្នុងតារាង។

## ភាពស្របគ្នារវាងគម្រោង អ្នកទទួលផល និងក្រសួងរបស់រាជរដ្ឋាភិបាល

របកគំហើញជាវិជ្ជមានមួយក្នុងចំណោមរបកគំហើញជាច្រើន ចេញពីការអង្កេតនេះ គឺថា អង្គការសង្គមស៊ីវិល កំពុងសម្របសម្រួលគម្រោង ជាមួយអ្នកទទួលផលគោលដៅ និងក្រសួងពាក់ព័ន្ធ។ ទោះបីជាផ្នែកនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានសួរដាច់ដោយឡែកពីគ្នាក៏ដោយ ប៉ុន្តែ នៅពេលត្រូវបានវិភាគរួមគ្នា លទ្ធផលបង្ហាញថា អង្គការសង្គមស៊ីវិល មានសមត្ថភាពដោយឯករាជ្យ ដើម្បីសម្របការងារជាមួយរាជរដ្ឋាភិបាលនិងប្រជាជនតាមមូលដ្ឋាន ដើម្បីសម្រេចឲ្យបាន ប្រកបដោយប្រសិទ្ធភាព នូវគោលដៅរបស់អង្គការសង្គមស៊ីវិល និងការអភិវឌ្ឍន៍ជាតិបន្ថែមទៀត (សូមមើលតារាងទី២៧ខាងលើ)។

## ស្វ័យអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព

សេចក្តីសន្និដ្ឋានគួរឲ្យកត់សម្គាល់មួយទៀត ចេញពីការវិភាគទិន្នន័យនៃការអង្កេតឆ្នាំ ២០១២នេះ គឺអង្គការសង្គមស៊ីវិលភាគច្រើនលើសលុប កំពុងប្រតិបត្តិស្វ័យអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ អង្គការសង្គមស៊ីវិលស្ទើរតែទាំងអស់ ដែលបានចូលរួមក្នុងការអង្កេតនេះ យ៉ាងហោចណាស់មានធម្មនុញ្ញមួយ ឬឯកសារដទៃទៀត ពិពណ៌នាអំពីមុខងារអភិបាលកិច្ចរបស់អង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលភាគច្រើន ក៏មានក្រុមប្រឹក្សាភិបាល ដើម្បីបង្កើនការត្រួតពិនិត្យ និងបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ ដែលលម្អិតពីការគ្រប់គ្រង គម្រោង និងប្រវត្តិហិរញ្ញវត្ថុ។ អង្គការសង្គមស៊ីវិលភាគច្រើន ក៏បានធ្វើសវនកម្មឯករាជ្យដោយតតិយជនផងដែរ ដែលនេះគឺជាវិធីតឹងរ៉ឹងមួយ ក្នុងការបង្ហាញពីលក្ខណៈតម្លាភាពរបស់ខ្លួន។ វិស័យអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ថ្មីៗនេះ ក៏បានបង្កើតក្រុមសីលធម៌ និងប្រព័ន្ធវិញ្ញាបនបត្រត្រួតពិនិត្យដោយតតិយជន ដែលប្រព័ន្ធទាំងពីរនេះ ត្រូវបានបង្កើតឡើងដោយអង្គការ CCC។ ប្រព័ន្ធទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណ និងផ្តល់រង្វាន់ដល់អង្គការសង្គមស៊ីវិលទាំងឡាយណា ដែលបង្ហាញក្រមសីលធម៌នៃគណនេយ្យភាព និងស្តង់ដារអភិបាលកិច្ចល្អកម្រិតខ្ពស់បំផុត បង្កើនសមត្ថភាពរបស់អង្គការ សង្គមស៊ីវិលតូចៗ ដើម្បីឈានដល់កម្រិតដូចគ្នា ព្រមទាំងបង្កើតយន្តការមួយ ដើម្បីដោះស្រាយបណ្តឹង និងដាក់ពិន័យសកម្មភាពជាអវិជ្ជមាន ដល់អង្គការសង្គមស៊ីវិលមួយចំនួនតូច ដែលប្រព្រឹត្តមិនសមស្រប ។

ជាទូទៅ វិស័យអង្គការសង្គមស៊ីវិល ហាក់ដូចជាកំពុងឆ្ពោះទៅកាន់គំរូនៃស្វ័យអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ ដោយសារតែនិន្នាការទាំងក្នុងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ និងគំនិតផ្តួចផ្តើម ដែលបានចាប់ផ្តើមនៅថ្នាក់ជាតិ ថ្មីៗនេះ យើងរំពឹងថា វិធានការអភិបាលកិច្ចទាំងនេះ នឹងបន្តកើនឡើង និងប្រសើរឡើងក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ។

## សហប្រតិបត្តិការក្នុងវិស័យអង្គការសង្គមស៊ីវិល

ជាទូទៅ សហប្រតិបត្តិការក្នុងវិស័យអង្គការសង្គមស៊ីវិល មានភាពវិជ្ជមាន និងផ្តល់ផលច្រើន។ អង្គការសង្គមស៊ីវិលភាគច្រើន រក្សាអនុស្សរណៈយោគយល់ ជាមួយភាគីរាជរដ្ឋាភិបាល និងធ្វើការដើម្បីសម្របគម្រោង ជាមួយតម្រូវការសហគមន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្នុងកិច្ចសម្ភាសន៍បែបគុណភាព អង្គការសង្គមស៊ីវិលមួយចំនួន បានលើកឡើងថា ពួកគេបានចាប់ផ្តើមប្រើប្រាស់រួចទៅហើយ នូវទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីផ្តោតគោលដៅគម្រោងឲ្យចំប្រជាជនក្រីក្រ និងអ្នកមានហានិភ័យខ្ពស់បំផុត។ នេះជានិន្នាការ

មួយ ដែលសង្ឃឹមថានឹងបន្ត ដោយសារតែព័ត៌មានអំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រាប់ខេត្តទាំងអស់ ចាប់ផ្តើមអាចរកបាន។

សហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល គឺមានកម្រិតខ្ពស់ ដោយ ៦៩% នៃអង្គការ បានចូលរួមក្នុងបណ្តាញអង្គការសង្គមស៊ីវិល ឬជាសមាជិកនៃអង្គការមេដូចជាអង្គការ CCC។ ជាងពាក់កណ្តាលនៃអង្គការសង្គមស៊ីវិល ក៏មានកិច្ចព្រមព្រៀងដោយផ្ទាល់ ជាមួយអង្គការសង្គមស៊ីវិល ឬអង្គការនៅតាមសហគមន៍ផ្សេងទៀតផងដែរ ។ កិច្ចព្រមព្រៀងទាំងនេះ អាចជួយសម្រួលការអនុវត្តន៍គម្រោង កសាងសមត្ថភាពបុគ្គលិក និងកាត់បន្ថយការចំណាយចាំបាច់ជាទៀងទាត់របស់អង្គការ តាមរយៈការចែករំលែកព័ត៌មាន បុគ្គលិក និងធនធាន។ ជាងមួយភាគបួននៃអង្គការសង្គមស៊ីវិល បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់អង្គការ ផ្សេងទៀត ក្នុងឆ្នាំ២០១២។ ទំនាក់ទំនងទាំងនេះ ទំនងជានឹងប្រសើរឡើង នាពេលអនាគត ដោយសារតែមានការគាំទ្រខ្លាំង ក្នុងចំណោមនាយកអង្គការសង្គមស៊ីវិល និងបុគ្គលិកជាន់ខ្ពស់ ចំពោះគម្រោងថ្មីៗ និងគម្រោងសហប្រតិបត្តិការគ្នា ដូចជាមជ្ឈមណ្ឌលអង្គការសង្គមស៊ីវិល និង មូលនិធិជាតិសម្រាប់អង្គការសង្គមស៊ីវិល។

